# ថ្ងៃទី ០៣ ខែ មករា ឆ្នាំ២០២២

## អាជ្ញាធរស្រុកសំពៅលូន នៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពី ប្រទេសថៃ និងប្រគល់នៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣

https://gdlf-kh.com/ 2021/12/30/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃព្រហស្បតិ៍ ១១រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនទាំង៦ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធាចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងបានទទួលប្រជាពលរដ្ឋវិលត្រឡប់ពីប្រទេសថៃវិញ ត្រង់ចំណុចភូមិសាស្ត្រ ក្នុងឃុំសន្តិភាព និងឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង សរុបបានចំនួន១៤នាក់ ស្រី ០៥នាក់ ក្មេង០៥នាក់ ក្មេងស្រី០៣នាក់។ ក្រោយពីទទួលបានកម្លាំងយើងបានកត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំ រួចក៏បានប្រគល់បងប្អូនទាំងអស់អោយទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ ១៣។

## បង្ក្រាបទីតាំងជួញដូរផ្លូវភេទឃាត់ខ្លួនម្ចាស់ទីតាំងម្នាក់និងសង្គ្រោះនារីរងគ្រោះ១០នាក់

https://www.kampucheathmey.com/ ថ្ងៃសុក្រ ៣១ ធ្នូ ២០២១ដោយ Sokhom Khon

កម្លាំងនគរបាលខេត្តកំពង់ធំ បានចុះបង្ក្រាបទីតាំងរកស៊ីជួញដូរផ្លូវភេទខុសច្បាប់មួយកន្លែង ធ្វើការឃាត់ខ្លួនជនសង្ស័យជាម្ចាស់ទីតាំងម្នាក់ និងសង្គ្រោះនារីរងគ្រោះសរុប១០នាក់ ក្នុងនោះមានអនីតិជន៧នាក់។ ប្រតិបត្តិការបង្ក្រាបនេះ បានធ្វើឡើងកាលពីវេលាម៉ោង១៩និង២០នាទី ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ ស្ថិតក្នុងភូមិសូយោង ឃុំ សូយោង ស្រុកតាំងគោក ខេត្តកំពង់ធំ ដោយមានការសម្របសម្រួលនីតិវិធីពីឯកឧត្តម ស៊ិន វិរៈ ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកំពង់ធំ និងក្រោមការដឹកនាំបញ្ជាផ្ទាល់ពីលោកឧត្តមសេនីយ៍ទោ ម៉ែន លី ស្នងការនគរបាលខេត្ត និងលោកស្រីឧត្តមសេនីយ៍ត្រី កង កូយ ស្នងការរងផែនការងារប្រឆាំងការជួញដូរមនុស្ស ។

ក្នុងប្រតិបត្តិការបង្ក្រាបនេះ កម្លាំងសមត្ថកិច្ចបានឃាត់ខ្លួនបានជនសង្ស័យម្នាក់ឈ្មោះ អ៊ូ សុខហៀង ហៅ ប៉ក់ ភេទប្រុស អាយុ៤១ឆ្នាំ រស់នៅទីកន្លែងកើតហេតុ និងសង្គ្រោះជនរងគ្រោះចំនួន១០នាក់ ក្នុងនោះអនីតិជនចំនួន០៧នាក់ បញ្ជូនទៅការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីកសាងនីតិវិធីចាត់ការបន្ត ៕ អត្ថបទ៖ សុខុម

## ក្នុងឆ្នាំ ២០២១ មានពលករខ្មែរប្រមាណជាង ៨ម៉ឺននាក់ ត្រូវបាន
## ភាគីថៃចាប់បញ្ជូនមកប្រទេសកម្ពុជាវិញ តាមច្រកព្រំដែនក្នុងខេត្តបន្ទាយមានជ័យ

https://gntimes.com/ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១

បន្ទាយមានជ័យ៖ យោងតាមរបាយការណ៍ចុងឆ្នាំ ២០២១ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តបន្ទាយមានជ័យ ចំនួនពលករកម្ពុជា ដែលបញ្ជូនមកពីប្រទេសថៃមាន ៨០.៦៩២នាក់ ស្រី ៣១.៩៤៧នាក់ កុមារ ៨.៧៨៨នាក់ ។ របាយការណ៍ខាងលើនេះ បានបង្ហាញនៅក្នុងកិច្ចប្រជុំត្រួតពិនិត្យសមាសភាព គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តបន្ទាយមានជ័យ កាលពីរសៀលថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០២១ ដែលដឹកនាំដោយ លោក អ៊ុ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត ។

លោក អ៊ុ រាត្រី ក៏បានជំរុញដល់គ្រប់អ្នកពាក់ព័ន្ធ ពិសេសកម្លាំងសមត្ថកិច្ច ដែលឈរជើងតាមបន្ទាត់ព្រំដែន ត្រូវបន្តរួមគ្នាទប់ស្កាត់មិនឱ្យកើតមានសកម្មភាពលួចឆ្លងដែនដោយខុសច្បាប់ នៅតាមបន្ទាត់ព្រំដែន ដោយការអូសទាញពីសំណាក់មេខ្យល់ ពិសេសអំពើជួញដូរមនុស្ស (ស្ត្រី និងកុមារ) ។ លោកបានបញ្ជាក់ថា៖ បច្ចុប្បន្ន មានបងប្អូនពលរដ្ឋពីគ្រប់បណ្តាខេត្ត ក៏ដូចជាក្នុងខេត្ត បានលួចឆ្លងដែនដោយខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃ តែត្រូវសមត្ថកិច្ចយើងធ្វើការឃាត់ខ្លួន និងធ្វើការអប់រំណែនាំជាបន្តបន្ទាប់ ។ ចំណែក មេខ្យល់ដែលបានអូសទាញពលរដ្ឋលួចឆ្លងដែន ក៏ត្រូវបានបញ្ជូនទៅតុលាការចាត់ការតាមច្បាប់ជាបន្តបន្ទាប់ផងដែរ ។ ដោយឡែក ក្រោយពីមានការផ្ទុះរីករាលដាលជំងឺកូវីដ-១៩ ទូទាំងពិភពលោក ប្រទេសថៃបានបញ្ជូនបងប្អូនពលករកម្ពុជា មកប្រទេសកម្ពុជាវិញរាប់ម៉ឺននាក់ ផងដែរ។ ជាមួយគ្នានោះលោក អ៊ុ រាត្រី ក៏បានថ្លែងនូវការអរគុណចំពោះគ្រប់ភាគីពាក់ព័ន្ធ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលបានចូលរួមយ៉ាងសកម្មជាមួយរដ្ឋបាលខេត្ត ក្នុងការជួយសម្រួលដឹកជញ្ជូនបងប្អូនពលករកម្ពុជាដែលថៃបញ្ជូនមកវិញ នាពេលកន្លងមក៕ ដោយ ៖ ចន្ទ្រា

## មេខ្យល់នាំពលករខុសច្បាប់ត្រូវបានសមត្ថកិច្ចឃាត់ខ្លួននិងបញ្ជូនទៅតុលាការ

https://kohsantepheapdaily.com.kh/ សៀមរាប ០១ ខែ មករា ឆ្នាំ ២០២២ ម៉ោង ១៩:៥១

ខេត្តសៀមរាប ៖ កម្លាំងនគរបាលចរាចរណ៍ស្រុកអង្គរជុំ បានធ្វើការផាកពិន័យអ្នកបើកបរល្មើសច្បាប់ចរាចរ ក្រោយពីបានស្គាល់ឈ្មោះអ្នកបើកបរ និងស្លាកលេខឡាន ប៉ះចំមុខសញ្ញាជួញដូរមនុស្ស ដែលស្ថិតក្នុងការស៊ើបអង្កេតរបស់ការិយាល័យជំនាញក៏បានរាយការណ៍មកការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន ហើយបានរាយការណ៍ជូន លោក ព្រះរាជអាជ្ញា និងបានការអនុញ្ញាតិ ឱ្យនាំមុខសញ្ញា និងរថយន្តមកធ្វើការសាកសួរ នៅការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប ។ ហេតុការណ៍ឃាត់រថយន្ត និងមនុស្សនោះបានធ្វើនៅថ្ងៃទី៣០ ខែធ្នូ ២០២១ ស្ថិតនៅក្នុងភូមិសាស្រ្ត ស្រុកអង្គរជុំ ។

សូមរំលឹកដែរថា កាលពីដើមខែមិថុនា ឆ្នាំ២០២១ ប្រទេសកម្ពុជាក៏ដូច ខេត្តសៀមរាប គឺជាអំឡុងពេលដែលបានជួបនូវការឆ្លងរីករាលដាលនៃជម្ងឺ កូវីដ១៩យ៉ាងខ្លាំងក្លា ការបិទខ្ទប់ដំណើរពីខេត្ត១ ទៅខេត្ត១ ឬបិទខ្ទប់តាមតំបន់ក្នុងខេត្តទៀតផង នៅតាមបន្ទាត់ព្រំដែនកម្ពុជា ថៃ ត្រូវបានបិទមិនឱ្យប្រជាពលរដ្ឋឆ្លងដែនចេញទៅប្រទេសថៃឡើយ ។ ចំណែកពលករ ដែលត្រលប់ចូលពីប្រទេសថៃវិញក៏ត្រូវបានអាជ្ញាធរ និងសមត្ថកិច្ចទៅទទួលដើម្បីយកមកដាក់ឱ្យធ្វើចត្តាឡីស័កគ្រប់ចំនួនថ្ងៃ ដែលរដ្ឋាភិបាល និងក្រសួងសុខាភិបាលបានកំណត់ ។

លោកឧត្តមសេ នីយ៍ត្រី ដួង ថាវ រី ស្នងការរងនគរបាលទទួលបន្ទុក ការិយាល័យប្រឆាំងការជួញ ដូរនិងការពារអនិតិជននៃស្នងការដ្ឋាននគរ បាលខេត្តសៀមរាប បានប្រាប់ឱ្យដឹងថា ករណីនេះសមត្ថកិច្ចព្រំដែននៃខេត្ត

បន្ទាយមានជ័យបានឃាត់ដំណើរពលករដែលចាញ់បោកមេខ្យល់អូស ទាញបម្រុងឆ្លងដែនដោយខុសច្បាប់ចំនួន ១២ នាក់ និងបញ្ជូនតាមក្រុមការ ងារទទួលពលករមកឱ្យធ្វើចត្តាឡីស័កនៅវិទ្យាល័យសម្តេចឪ ខេត្តសៀមរាប ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ និងបញ្ជាផ្ទាល់ពីលោកអភិបាលខេត្ត និងបញ្ជាដឹកនាំផ្ទាល់ពីលោក ស្នងការនគរ បាលខេត្តបានចាត់កម្លាំងជំនាញប្រឆាំងការជួញដូរមនុស្ស ជាសមត្ថកិច្ច ដើម្បីស៊ើបអង្កេតរកមេខ្យល់ដែលបោក បញ្ឆោតពលករឱ្យឆ្លងដែនដោយខុសច្បាប់ ។

សូមបញ្ជាក់ដែរថា ករណីនេះមិនមែនជាលើកទី១ទេ ពីព្រោះសមត្ថកិច្ចជំនាញបានធ្វើការស៊ើបអង្កេត និងឃាត់ខ្លួនជនមុខសញ្ញាមេខ្យល់របៀបនេះ បញ្ជូនទៅតុលាការជាច្រើនករណីរួចមកហើយ ។ លោកស្រីបានបន្ថែមថា លោកស្រីបានឱ្យកម្លាំងជំនាញសាកសួរពលករទាំង១២នាក់នោះ រួចមក ពួកគេបានប្រាប់ថា ត្រូវបានមេខ្យល់ និងជា ម្ចាស់ឡាននាំទៅព្រំដែន ដើម្បីប្រគល់ឱ្យមេខ្យល់ផ្សេងទៀតដែលជាក្រុមតែ១នាំឆ្លងដែន ហើយដែលកម្រៃនៃការបង់សេវា គឺមេខ្យល់យកសរុបតែម្តងគឺ១នាក់ ៦០០០ បាត ហើយពលករនឹងធ្វើការកាត់ប្រាក់ខែឱ្យថៅកែថៃដើម្បីសងថ្លៃការធ្វើដំណើរ ។ លោកស្រីបានបញ្ជាក់ថា ពលករបានរៀនរាប់សមត្ថកិច្ចយើងថា មេខ្យល់ដែលនាំពួកគេចាកចេញនេះមានឈ្មោះ វ៉ាន រិក ភេទប្រុស អាយុ៣៨ឆ្នាំ រសនៅភូមិគោកស្នួល ឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប ដោយរថយន្តសាំយ៉ុង១៥កៅអី ពណ៌ស ពាក់ស្លាកលេខភ្នំពេញ 2U 5236 ជារថយន្តរបស់ឈ្មោះ វ៉ាន រិក តែម្តង ។

ក្នុងការស៊ើបអង្កតនេះ ជនសង្ស័យគេចខ្លួនពីមូលដ្ឋានរហូតដល់ថ្ងៃ ៣០ ធ្នូ ២០២១ ទើបលេចមុខ ហើយត្រូវនាំខ្លួនមកសួរនាំក្រោមការសម្របសម្រួលពីលោកព្រះរាជអាជ្ញា ។ ក្នុងចម្លើយសារ ភាពរបស់មេខ្យល់ដែលចាស់វស្សា និងមិនរាងចាលម្នាក់នេះបានឆ្លើយយ៉ាងខ្លីៗថា ខ្លួនមិនដែលបានដឹកមនុស្សឆ្លងដែនទេ ទើបតែម្តងនេះគត់ដែលក្នុងករណីនៃការស៊ើបអង្កេតរបស់សមត្ថកិច្ចនេះឯង ហើយខ្លួននាំតែ៥ នាក់ប៉ុណ្ណោះ ។ លោកស្រីបានបញ្ជាក់បន្ថែមទៀតថា ក្រោយឃាត់ខ្លួន តាមបទបញ្ជាពីលោកព្រះរាជអាជ្ញា អមសាលាដំបូងខេត្តសៀមរាបកម្លាំងការិយ៉ាយជំនាញប្រឆាំងការជួញដូរមនុស្សបានកសាងសំណុំរឿង បញ្ជូនទៅតុលារការ នៅរសៀលថ្ងៃទី ៣១ ធ្នូ ២០២១នេះ ដើម្បីចាត់ការទៅតាមនីតិវិធីច្បាប់៕

## ថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០២២

### សម្តេចតេជោ ៖ បច្ចុប្បន្នពលករខ្មែរជាង៥ម៉ឺននាក់ កំពុងធ្វើការនៅកូរ៉េខាងត្បូង

https://dap-news.com/national/ ByTR110Posted on January 3, 2022

ភ្នំពេញ ៖ ក្នុងពិធីបើកការដ្ឋានសាងសង់ និងលើកកម្រិតគុណភាពផ្លូវជាតិលេខ៤៨ តភ្ជាប់ខេត្តព្រះសីហនុទៅកាន់ខេត្តកោះកុងប្រវែង១៤៨គីឡូម៉ែត្រដែលជាជំនួយរបស់កូរ៉េ នៅព្រឹកថ្ងៃ៣ ខែមករា ឆ្នាំ២០២២ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានមានប្រសាសន៍ថា បច្ចុប្បន្ននេះ មានពលករខ្មែរជាង៥ម៉ឺននាក់ កំពុងធ្វើការនៅកូរ៉េដែលបានបញ្ជូនថវិកាមកឲ្យក្រុមគ្រួសារ៕

## គិតត្រឹមថ្ងៃទី២ ខែមករានេះ មានពលករ
## ១,៥០៣នាក់ កំពុងធ្វើចត្តាឡីស័កក្នុងមណ្ឌលចត្តាឡីស័ក ទូទាំងប្រទេស

http://freshnewsasia.com/ 2022-01-02 11:03pm

**(ភ្នំពេញ)៖** គិតត្រឹមថ្ងៃទី២ ខែមករា ឆ្នាំ២០២២នេះ កម្ពុជាមានពលករ១,៥០៣នាក់ កំពុងធ្វើចត្តាឡីស័កក្នុងមណ្ឌលចត្តាឡីស័កទូទាំងប្រទេស។ នេះបើតាមរបាយការណ៍ ដែលបណ្តាញព័ត៌មាន Fresh News ទទួលបាននៅយប់ថ្ងៃនេះ។ **របាយការណ៍នៅថ្ងៃនេះបានបញ្ជាក់ដូចតទៅ៖**

១៖ ខេត្តជាប់ព្រំដែនថៃ៧ខេត្ត៖ ចូលមណ្ឌល១៤១នាក់, ចេញពីមណ្ឌល១៤១នាក់ និងនៅក្នុងមណ្ឌល១,៥០០នាក់។

២៖ ខេត្តមិនជាប់ព្រំដែនថៃ ១៧ខេត្ត៖ ចូលមណ្ឌល០នាក់, ចេញពីមណ្ឌល០នាក់ និងនៅក្នុងមណ្ឌល៣នាក់។

៣៖ សរុប២៤ខេត្ត៖ ចូលមណ្ឌល ១៤១នាក់, ចេញពីមណ្ឌល១៤១ និងនៅក្នុងមណ្ឌល១,៥០៣នាក់៕

## អាជ្ញាធរស្រុកសំពៅលូន នៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់
## ពីប្រទេសថៃ និងប្រគល់ទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣

https://gdlf-kh.com/ 2022/01/02/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃអាទិត្យ ១៤រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី០២ ខែមករា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនទាំង៦ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធាចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្រ្តប៉ុស្តិ៍គ្រប់គ្រង និងបានទទួលប្រជាពលរដ្ឋវិលត្រឡប់ពីប្រទេសថៃវិញ ត្រង់ចំណុចភូមិសាស្រ្ត ក្នុងឃុំសន្តិភាព និងឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង សរុបបានចំនួន០៧នាក់ (ស្រី ០៣នាក់ ក្មេង០១នាក់)។

ក្រោយពីទទួលបាន កម្លាំងយើងកត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំ រួចក៏បានប្រគល់បងប្អូនទាំងអស់អោយទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣។

## អាជ្ញាធរស្រុកសំពៅលូន បន្តទទួល
## ប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង០៧និង០០នាទីព្រឹក នាថ្ងៃអាទិត្យ ១៤រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២ ខែមករា ឆ្នាំ២០២២ ដោយអនុវត្តន៍តាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោក៨១៧ បាន

ចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក មុឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន ចំនួន០៣នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០២នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក-អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន៤៨នាក់ (ស្រី២២នាក់ ក្មេង០៥នាក់ ក្មេងស្រី០១នាក់)។

ក្រោយពីទទួល កម្លាំងយើងបានកត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំរួចកម្លាំងយើងបានប្រគល់បងប្អូនទាំងអស់ឱយទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍ ជាលទ្ធផលអវិជ្ជមានទាំងអស់ រួចទើបអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរាងៗខ្លួនចំនួន២៣នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ) ចំណែកអ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្តេនអត់ចេញចំនួន២៥នាក់ ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កពេងចក្រម្សៅមីស្ថិតក្នុងភូមិអូរល្វា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

## ថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០២២

### ពលករ ១ ៥០០ នាក់ កំពុងធ្វើចត្តាឡីស័កតាមខេត្តជាប់ព្រំដែនថៃ

https://www.postkhmer.com/ ឡាយ សាមាន | Publication date 04 January 2022 | 09:29 ICT

**បន្ទាយមានជ័យៈ** គិតត្រឹមថ្ងៃទី ២ ខែមករា ឆ្នាំ ២០២២ កម្ពុជានៅមានពលករសរុបចំនួន ១ ៥០០ នាក់ ដែលកំពុងធ្វើចត្តាឡីស័កក្នុងមណ្ឌលចត្តាឡីស័កតាមខេត្តជាប់ព្រំដែនប្រទេសថៃ ខណៈពលករដែលវិលត្រឡប់មកពីថៃ មានការថយចុះ។ នេះបើយោងតាមស្ថិតិពលករក្នុងមណ្ឌលចត្តាឡីស័កនៅតាមបណ្ដាខេត្តមួយចំនួន។

ក្នុងរបាយការណ៍ស្ថិតិពលករ គិតត្រឹមថ្ងៃទី ២ ខែមករាឱ្យដឹងថា ខេត្តជាប់ព្រំដែន-ថៃ មានពលករកំពុងធ្វើចត្តាឡីស័កចំនួន ១ ៥០០ នាក់ និងខេត្តមិនជាប់ព្រំដែន មានពលករចំនួន ៣ នាក់។ ក្នុងនោះខេត្តកោះកុងមានពលករកំពុងធ្វើចត្តាឡីស័ក ១៤ នាក់ ខេត្តបាត់ដំបង ៥១៥ នាក់ ខេត្តប៉ៃលិន ២១០ នាក់ ខេត្តបន្ទាយមានជ័យ ៥២៣ នាក់ និងខេត្តឧត្តរមានជ័យ ២៣៨ នាក់។ រីឯខេត្តកំពង់ស្ពឺ មានពលករកំពុងធ្វើចត្តាឡីស័ក ៣ នាក់ ខណៈខេត្តផ្សេងៗទៀតពុំមានពលករធ្វើចត្តាឡីស័កនោះទេ។

អ្នកនាំពាក្យរដ្ឋបាលខេត្តបន្ទាយមានជ័យលោក សេក សុខុម ថ្លែងនៅថ្ងៃទី ៣ មករាថា ពលករត្រឡប់ពីប្រទេសថៃមានការថយចុះជាបន្តបន្ទាប់ បើប្រៀបធៀបនឹងកាលពីប៉ុន្មានខែមុន។ «ឥឡូវនេះពលករត្រឡប់មកវិញក្នុង ១ ថ្ងៃជាមធ្យម ១០០ នាក់ មានការថយចុះ បើពីមុនកាលពីថៃផ្ទុះកូវីដខ្លាំង ពលករត្រឡប់មកវិញខ្ទង់ ៣០០ ទៅ ៥០០ នាក់ ក្នុង ១ ថ្ងៃ»។ បើទោះបីស្ថានភាពកូវីដ ១៩ នៅកម្ពុជាមានភាពធូរស្រាល ប៉ុន្តែការធ្វើតេស្តរកមេរោគកូវីដ ១៩ និងការធ្វើចត្តាឡីស័ក នៅតែបន្តរឹតបន្តឹង ដើម្បីទប់ស្កាត់ការចម្លងចូលសហគមន៍។ លោកថាៈ «ពេលពលករចូលមក គឺតម្រូវឱ្យធ្វើតេស្តរហ័សដដែល ហើយដាក់គាត់ធ្វើចត្តាឡីស័ក ១៤ ថ្ងៃ បន្ទាប់មកបញ្ជូនគាត់ទៅតាមទីតាំងរៀងៗខ្លួន ហើយយើងក៏បានផ្ដល់ម្ហូបអាហារ ប្រចាំថ្ងៃដល់ពលករដោយឥតគិតថ្លៃផងដែរ»។ ទន្ទឹមនឹងនេះដែរ លោកសុខុមបញ្ជាក់ថា បច្ចុប្បន្នប្រជាពលរដ្ឋខ្មែរមួយចំនួន ក៏បានត្រឡប់ទៅធ្វើការនៅថៃវិញជាបណ្ដើរៗដែរតាមរយៈរូបភាពប្រើលិខិតឆ្លងដែនទេសចរណ៍ ខណៈពលរដ្ឋមួយចំនួនទៀតនៅបន្តលួចទៅតាមច្រករបៀង។ លោកថាៈ «នៅខេត្តយើង មានច្រកព្រំដែនទៅថៃចំនួន ៤ ដែលកំពុងដំណើរការហើយប្រជាពលរដ្ឋដែលទៅធ្វើការនៅថៃ មានពលរដ្ឋមួយចំនួន ប្រើលិខិតឆ្លងដែនទេសចរណ៍បើគាត់ទៅតាមច្រក ៤ នេះ មិនខុសច្បាប់ទេ ប៉ុន្តែបើគាត់ទៅតាមច្រករបៀង គឺខុសច្បាប់»។

ចំណែកក្នុងរបាយការណ៍ពលករចំណាកស្រុកមកពីប្រទេសថៃ តាមច្រកព្រំដែនអន្តរជាតិ ខេត្តឧត្តរមានជ័យឱ្យដឹងថា នៅថ្ងៃទី ២ ខែមករា មានពលករចំនួន ១៨៦ នាក់បានត្រឡប់ចូលស្រុកវិញ ខណៈថ្ងៃទី ១ មករា មាន ១៩៥ នាក់ ក្នុងនោះ ការធ្វើតេស្តហ័សអវិជ្ជមានទាំងអស់។

លោក មឿន តុលា នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ដែលធ្វើការពាក់ព័ន្ធពលករចំណាកស្រុក ធ្លាប់ប្រាប់ភ្នំពេញប៉ុស្តិ៍ដោយគាំទ្រចំណាត់ការរបស់រាជរដ្ឋាភិបាល នាពេលកន្លងមកដែលបានបើកច្រកព្រំដែនទទួលពលករ និងផ្តល់ការចាក់វ៉ាក់សាំងកូវីដ ១៩ ដោយឥតគិតថ្លៃ។ លោកថ្លែងថា បញ្ហាចម្បងដែលជំរុញឱ្យពលករខ្មែរ សម្រុកមកស្រុកកំណើតវិញយ៉ាងគំហុកនាពេលកន្លងមក គឺដោយសារមានការឆ្លងរាលដាលនៃជំងឺកូវីដ ១៩ កាន់តែខ្លាំងនៅប្រទេសថៃ។

អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) លោកស្រី ជូ ប៊ុនអេង ធ្លាប់ឱ្យដឹងថា ចាប់តាំងពីផ្ទុះជំងឺកូវីដរាតត្បាតរហូតដល់ចុងឆ្នាំ ២០២១ មានពលករខ្មែរត្រឡប់ពីក្រៅប្រទេសចូលមកស្រុកវិញ ជាង ២៦ ម៉ឺននាក់ ក្នុងនោះភាគច្រើនត្រឡប់មកពីប្រទេសថៃ៕

## មេខ្យល់នាំពលករឆ្លងដែនខុសច្បាប់ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន និងបញ្ជូនទៅតុលាការ

https://www.khmertimeskh.com/ កែវ វចនា / Khmer Times January 4, 2022

សមត្ថកិច្ចកំពុងអនុវត្តច្បាប់ក្នុងការពិនិត្យ និងផាកពិន័យបទល្មើសច្បាប់ចរាចរ កម្លាំងនគរបាលអនុវត្តច្បាប់ចរាចរនៅស្រុកអង្គរជុំ បានកំណត់ស្គាល់ឈ្មោះអ្នកបើកបរ និងស្លាកលេខរថយន្តដែលជាមុខសញ្ញាជួញដូរមនុស្ស ដែលស្ថិតក្នុងការស៊ើបអង្កេតរបស់ការិយាល័យជំនាញ ក៏បានរាយការណ៍មកការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងបានឃាត់ខ្លួនមេខ្យល់មួយរូប ដែលនាំពលករឆ្លងដែនខុសច្បាប់។

ករណីនេះកើតឡើងនៅចុងខែធ្នូ ឆ្នាំ២០២១ ដោយសមត្ថកិច្ចព្រំដែននៃខេត្តបន្ទាយមានជ័យ បានឃាត់ដំណើរពលករ ដែលចាញ់បោកមេខ្យល់អូសទាញបម្រុងឆ្លងដែនដោយខុសច្បាប់ចំនួន ១២នាក់ និងបញ្ជូនតាមក្រុមការងារទទួលពលករមកឱ្យធ្វើចត្តាឡីសក័នៅវិទ្យាល័យសម្តេចឪខេត្តសៀមរាប ។ ក្រោមការដឹកនាំនិងបញ្ជាផ្ទាល់ពីលោកអភិបាលខេត្ត និងក្រោមបញ្ជាដឹកនាំផ្ទាល់ពីលោកស្នងការបានចាត់កម្លាំងជំនាញប្រឆាំងការជួញដូរមនុស្ស ជាសមត្ថកិច្ចដើម្បីស៊ើបអង្កេតរកមេខ្យល់ ដែលបោកបញ្ឆោតពលករអោយឆ្លងដែនដោយខុសច្បាប់ ហើយនេះមិនមែនជាលើកទី១ទេ ពីព្រោះសមត្ថកិច្ចជំនាញបានធ្វើការស៊ើអង្កេត និងឃាត់ខ្លួនជនមុខសញ្ញាមេខ្យល់បញ្ជូនទៅតុលាការជាច្រើនករណីរួចមកហើយ ។

លោកស្រី ដួង ថាវរី ស្នងការរង និងលោក ជា ហេង នាយការិយាល័យ បានសាកសួរពលករទាំង ១២ នាក់នោះរួចមក បានឱ្យដឹងថា ពួកគេត្រូវបានមេខ្យល់ដែលជាម្ចាស់ឡានជូនទៅព្រំដែន ដើម្បីប្រគល់ឱ្យមេខ្យល់ផ្សេងទៀត ដែលជាក្រុមតែ១នាំឆ្លងដែន ហើយកម្រៃការបង់សេវា គឺមេខ្យល់យកសរុបក្នុង១នាក់ ៦០០០បាត ហើយពលករនឹងធ្វើការកាត់ប្រាក់ឱ្យថៅកែថៃដើម្បីសងថ្លៃការធ្វើដំណើរ។

តាមការបញ្ជាក់ពីពលករ មេខ្យល់ឈ្មោះ វ៉ាន រិក ភេទ ប្រុស អាយុ ៣៨ ឆ្នាំ រស់នៅភូមិគោកស្ដូល ឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប ដោយរថយន្ត ១៥ កៅអី ពណ៌ស ពាក់ ស្លាកលេខ ភ្នំពេញ 2U 5236 ។ ក្នុងការស៊ើបអង្កតនេះ ជនសង្ស័យ គេចខ្លួនពីមូលដ្ឋានរហូត ដល់ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ទើបលេចមុខហើយត្រូវនាំខ្លួនមកសួរនាំក្រោមការសម្របសម្រួលពីព្រះរាជអាជ្ញា។ ជនសង្ស័យឆ្លើយថា ខ្លួនមិនដែលបានដឹកមនុស្សឆ្លងដែនទេ ទើបតែម្តងគត់ដែលក្នុងករណីនៃការស៊ើបអង្កេតរបស់សមត្ថកិច្ចនេះឯង ហើយខ្លួននាំតែ ៥ នាក់ប៉ុណ្ណោះ។

បន្ទាប់ពីព្រះរាជអាជ្ញាអោយឃាត់ខ្លួន ការិយាល័យជំនាញប្រឆាំការជួញដូរមនុស្ស បានកសាងសំណុំរឿង តាមនីតិវិធីច្បាប់បញ្ជូនទៅតុលាការ៕

## អាជ្ញាធរ បន្តទទួលពលករវិល
## ត្រឡប់មកស្រុកវិញ ដែលភាគីថៃ បញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្រុកកំរៀង

https://gdlf-kh.com/ 2022/01/05/ Seng Chanmonirith ខេត្តបាត់ដំបង D819

នៅថ្ងៃទី០៥ ខែ មករា ឆ្នាំ២០២២ ដោយអនុវត្តន៍តាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវរកមុខសញ្ញា មេខ្យល់នាំពលករចេញដោយមិនស្របច្បាប់ក្នុងភូមិសាស្រ្ត ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរ:៨១៩ បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់សហការជាមួយកម្លាំងកងឃោធពលខេរភូមិន្ទ និងក្រុមគ្រូពេទ្យ បានទទួលពលករវិលត្រឡប់មកស្រុកវិញដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង។

ពលករដែលវិលត្រលប់មកកម្ពុជាវិញ សរុបចំនួន២០៤នាក់, ស្រី៨៤នាក់ និងក្មេង២៩នាក់ បន្ទាប់ពីសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩រួចរាល់ ក្រុមគ្រូពេទ្យបានធ្វើតេស្តរហ័ស និងជាលទ្ធផល គឺអវិជ្ជមានកូវីដ-១៩ ទាំងអស់។ ក្នុងនោះពលករដែលមានកាតចាក់វ៉ាក់សាំងចំនួន១៥០នាក់ (ស្រី៦១នាក់, ក្មេង២៥នាក់) ចំណែកពលករចំនួន៥៤នាក់, ស្រី២៣នាក់ និងក្មេង៤នាក់ ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន។ ដោយបានចាក់វ៉ាក់សាំងអោយក្មេងចាប់ពីអាយុ៦ឆ្នាំដល់១២ឆ្នាំ ចំនួន១០នាក់(ស្រី៦នាក់)ហើយក្រុមគ្រូពេទ្យអនុញ្ញាតអោយត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ។

## ពលករខ្មែរនៅតែបន្តត្រឡប់ពីថៃក្នុង១ថ្ងៃៗមិនតិចជាង២០០នាក់ទេ

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ ០៥ ខែ មករា ឆ្នាំ ២០២២ ម៉ោង ០៩:១៨

ខេត្តបន្ទាយមានជ័យ៖ ពលករខ្មែរនៅតែបន្តត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាវិញ ដោយក្នុងមួយថ្ងៃៗមិនតិចជាង២០០នាក់ទេ គិតនៅថ្ងៃទី០៤ មករា ឆ្នាំ២០២២ នេះ ស្ថិតតាមច្រកអូរបីជាន់ ស្រុកអូរជ្រៅ ។

លោកវរសេនីយ៍ទោ ម៉ាន់ ធី អធិការរងនគរបាលស្រុកអូរជ្រៅ និងជាក្រុមការងារទទួលពលករខ្មែរច្រកអូរបីជាន់បានប្រាប់ឱ្យដឹងថា ពលករខ្មែរនៅតែបន្តត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាតាមច្រកអូរបីជាន់ស្រុកអូរជ្រៅមានចំនួន២៥៥នាក់ (ស្រី១២៨នាក់) កុមារចំនួន៤២នាក់ (ស្រី២២នាក់) ហើយរកឃើញអ្នកឆ្លងកូវីដ.១៩មានចំនួន១នាក់ផងដែរ ។ លោកបានបញ្ជាក់ទៀតថា ពលករខ្មែរដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាវិញចំនួន២៥៥នាក់នេះ គឺមានឯកសារចាក់វ៉ាក់សាំងដូសទី២ មានចំនួន២៣៣នាក់ (ស្រី១១៥នាក់) ហើយបានអោយពួកគាត់អាចត្រឡប់ទៅផ្ទះវិញបាន ។ ដោយឡែក ពលករដែលបានចាក់វ៉ាក់សាំងដូសទី១ និងមិនទាន់បានចាក់វ៉ាក់សាំង ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃសិន ។ លោកវរៈសេនីយ៍ទោបញ្ជាក់ថា ចំពោះពលករខ្មែរដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាវិញ តាមច្រកអូរបីជាន់ ស្រុកអូរជ្រៅ ក្រុមការងារដែលទទួលពលករទាំងនោះបានធ្វើការណែអប់រំបញ្ឈប់សកម្មភាពចាញ់បោកមេខ្យល់ទៅរកការងារធ្វើដោយខុសច្បាប់នៅប្រទេសថៃទៀតទៅ ។

# ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០២២

## កម្ពុជា-ឡាវ-វៀតណាម
## ប្ដេជ្ញារួមគ្នាបន្ដបង្ក្រាបបទល្មើស គ្រឿងញៀន ជួញដូរមនុស្ស អំពើភេរវកម្ម និងបច្ចេកវិទ្យា

https://dap-news.com/national/ BySS107Posted on January 5, 2022

ភ្នំពេញ ៖ កម្ពុជា-ឡាវ-វៀតណាម បន្តពង្រឹងបន្ថែមទៀត ក្នុងការបង្ក្រាបបទល្មើសគ្រប់ប្រភេទឆ្លងកាត់ព្រំដែន ជាពិសេស បទល្មើសគ្រឿងញៀន ជួញដូរមនុស្ស រត់ពន្ធមនុស្ស អំពើភេរវកម្ម និងបទល្មើសបច្ចេកវិទ្យា ដើម្បីបុព្វហេតុ នៃសន្តិសុខសណ្ដាប់ធ្នាប់។

យោងតាមសេចក្ដីប្រកាសព័ត៌មានអំពី លទ្ធផលកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី កម្ពុជា-ឡាវ-វៀតណាម លើកទី៣ ស្ដីពីកិច្ចសហប្រតិបត្តិការបង្ការ និងបង្ក្រាបបទល្មើសរវាង ក្រសួងមហាផ្ទៃកម្ពុជា, ក្រសួងសន្តិសុខឡាវ និងក្រសួងនគរបាលវៀតណាម នារសៀលថ្ងៃទី៥ ខែមករា ឆ្នាំ២០២២ តាមប្រព័ន្ធវីដេអូ ចេញផ្សាយដោយ ក្រសួងមហាផ្ទៃ បានឲ្យដឹងថា សម្ដេច ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃកម្ពុជា, នាយឧត្តមសេនីយ៍ វិស័យ ឡាខាំហ្វុង រដ្ឋមន្ត្រីក្រសួងសន្តិសុខឡាវ និងឧត្តមសេនីយ៍ឯក តូ ឡឹម សមាជិកការិយាល័យនយោបាយ និងជារដ្ឋមន្ត្រីក្រសួងនគរបាលវៀតណាម បន្តពង្រឹងកិច្ចសហប្រតិបត្តិការសន្តិសុខទ្វេភាគី និងត្រីភាគី ស្របតាមខ្លឹមសារដែលមានចែង ក្នុងផែនការសហប្រតិបត្តិការទ្វេភាគីប្រចាំឆ្នាំ និងកំណត់ហេតុនៃកិច្ចសហប្រតិបត្តិការ ដែលបានចុះហត្ថលេខារវាង និងក្នុងចំណោមក្រសួងទាំងបី។

ក្រសួងមហាផ្ទៃ បញ្ជាក់ថា «បន្តពង្រឹងបន្ថែមទៀតកិច្ចសហប្រតិបត្តិការបង្ការ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទឆ្លងកាត់ព្រំដែន ជាពិសេស បទល្មើសពាក់ព័ន្ធគ្រឿងញៀន ការជួញដូរមនុស្ស ការរត់ពន្ធមនុស្ស អំពើភេរវកម្ម និងបទល្មើស បច្ចេកវិទ្យា ដើម្បីបុព្វហេតុនៃសន្តិសុខ សណ្ដាប់ធ្នាប់ និងសុវត្ថិភាពសង្គម បម្រើដល់ផលប្រយោជន៍ទៅវិញទៅមក នៃការអភិវឌ្ឍ និងវិបុលភាពនៃប្រទេសទាំងបី»។ ក្រសួង បន្ថែមថា បន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលក្នុងការដោះស្រាយ បង្ការ និងប្រយុទ្ធប្រឆាំងនូវការរាតត្បាតនៃជំងឺកូវីដ-១៩ ជំងឺឆ្លងរាតត្បាតផ្សេងៗ និងគ្រោះធម្មជាតិនានា បានទាន់ពេលវេលា នៅតាមបណ្ដាខេត្តជាប់ព្រំដែន ដើម្បីការពារសុខុមាលភាព សុវត្ថិភាព និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ នៅក្នុងតំបន់រងផលប៉ះពាល់។ ក្រសួង បញ្ជាក់ទៀតថា បន្តពង្រឹងកិច្ចសហប្រតិបត្តិការនៅក្នុងវេទិកាថ្នាក់តំបន់ និងអន្តរជាតិ រួមទាំងនៅក្នុងឱកាសដែល កម្ពុជាទទួលតួនាទីជាប្រធានអាស៊ានឆ្នាំ២០២២ និងព្រឹត្តិការណ៍ពាក់ព័ន្ធនានានៅក្រោមក្របខណ្ឌអាស៊ាន ព្រមទាំងបន្តកិច្ចសហប្រតិបត្តិការជិតស្និទ្ធ ក្នុងការថែរក្សាសន្តិសុខ ដើម្បីរៀបចំព្រឹត្តិការណ៍ជាតិ និងអន្តរជាតិធំៗ ដែលប្រទេសនីមួយៗត្រូវរៀបចំ និងធ្វើជាម្ចាស់ផ្ទះ។

លើសពីនេះទៀត ក្រសួងមហាផ្ទៃ លើកឡើងថា កម្ពុជា-ឡាវ-វៀតណាម ក៏ជំរុញដល់អាជ្ញាធរខេត្តជាប់ព្រំដែន ឲ្យបន្តរក្សាការជួបប្រជុំជាទៀងទាត់ ដើម្បីផ្លាស់ប្ដូរព័ត៌មាន និងដោះស្រាយដោយសន្តិវិធីចំពោះឧប្បត្តិហេតុនានា ដែលកើតឡើងនៅតាមតំបន់ព្រំដែន ក៏ដូចជាជំរុញ ការផ្លាស់ប្ដូរទស្សនកិច្ច និងសកម្មភាពមិត្តភាពផ្សេងៗក្នុងចំណោមអាជ្ញាធរមូលដ្ឋាននៅតាមតំបន់ព្រំដែននៃប្រទេសទាំងបី។ សូមបញ្ជាក់ថា កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី កម្ពុជា-ឡាវ-វៀតណាម ត្រូវបានប្រារព្ធធ្វើឡើងដោយប្ដូរវេនរៀងរាល់ ០២ឆ្នាំម្ដង រវាងក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងសន្តិសុខសាធារណៈ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងក្រសួងនគរបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម៕

## ចាប់បានបុរសមួយក្រុម ជួញដូរស្ត្រីវៀតណាម មករកស៊ីផ្លូវភេទនៅ កម្ពុជា

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ៦ មករា ២០២២ដោយ Sok Sovann

ប៉ូលិសបានជួយសង្គ្រោះស្ត្រីវៀតណាម ចំនួន៧នាក់ ដែលត្រូវគេជួញដូរមកកម្ពុជា ដើម្បីរកស៊ីផ្លូវភេទ និងចាប់ខ្លួនជនសង្ស័យ៣នាក់។ ប៉ូលិសខេត្ត Dong Nai បានឃាត់ខ្លួនបុរស៣នាក់ឈ្មោះ Nguyen Tien Dung អាយុ២៥ឆ្នាំ, Loc Thi Luan អាយុ២១ឆ្នាំនិង Ngo Nguyen Dong Khoa អាយុ៥៤ឆ្នាំពីបទ "ជួញដូរមនុស្ស" និង "រៀបចំការធ្វើចំណាកស្រុកខុសច្បាប់"។

យោងតាមការស៊ើបអង្កេត លោក Dung និង Luan បានសហការគ្នា ផ្សព្វផ្សាយព័ត៌មានអំពីស្ត្រីដែលត្រូវបានជ្រើសរើសឲ្យធ្វើការនៅក្នុងហាងខារ៉ាអូខេ និងកាស៊ីណូនៅកម្ពុជា ជាមួយប្រាក់ខែខ្ពស់។ សម្រាប់នារីម្នាក់ៗដែលជ្រើសរើសបាន លោក Dung ត្រូវផ្តល់ប្រាក់ចំនួន១០លានដុង (៤៤០ ដុល្លារ) ឲ្យលោក Luan។ បន្ទាប់មក Dung និង Khoa បាននាំនារីឆ្លងកាត់ខេត្តភាគខាងត្បូង Long An, Tay Ninh និង Binh Phuoc មុនពេលចូលមក កម្ពុជាតាមផ្លូវគ្មានមនុស្ស។ ដោយសារស្ត្រីដែលមិនបញ្ចេញអត្តសញ្ញាណ បានបដិសេធធ្វើការតាមការលួងលោមឈ្មួញបានឲ្យពួកគេទូរសព្ទទៅក្រុមគ្រួសារ និងទាមទារប្រាក់ពីគ្រួសារនីមួយៗពី១០០ទៅ១៥០លានដុង (៤,៤០០ ទៅ ៦,៥០០ដុល្លារ) ដើម្បីដោះលែងពួកគេឲ្យត្រឡប់ទៅផ្ទះវិញ។

ប៉ូលិសនិយាយថា ក្នុងអំឡុងខែធ្នូកន្លងទៅ ក្រុមនេះបានបោកបញ្ឆោត និងបញ្ជូនស្ត្រីជាង ១០ នាក់មកប្រទេសកម្ពុជា ដើម្បីធ្វើជានារីរកស៊ីផ្លូវភេទ។ បន្ទាប់ពីតាមដានពួកគេអស់រយៈពេលជាច្រើនថ្ងៃ ប៉ូលិសនៅក្នុងខេត្ត Dong Nai ដែលមានព្រំប្រទល់ជាប់ទីក្រុង ហូជីមិញ បានចាប់ខ្លួន Dung និងបក្ខពួករបស់គាត់ ខណៈពួកគេកំពុងជួញដូរស្ត្រីប្រាំពីរនាក់មកប្រទេសកម្ពុជាតាមផ្លូវផ្សេងៗគ្នា៕ *ប្រែសម្រួល៖ Vann Vann ប្រភព៖* VN Express

## និស្សិតម្នាក់ត្រូវចាប់ខ្លួនពាក់ព័ន្ធនឹងកម្មវិធីល.ក់នារីៗតាមអ៊ីនធើណេត

https://kohsantepheapdaily.com.kh/ ០៥ ខែ មករា ឆ្នាំ ២០២២ ម៉ោង ១០:០៧

ឥណ្ឌា ៖ ប៉ូលីសឥណ្ឌាបានធ្វើការចាប់ខ្លួនយុវជនវ័យ ២១ឆ្នាំម្នាក់ពាក់ព័ន្ធនឹងកម្មវិធីមួយ (App) ដែលចែករំលែករូបថត និងប្រកាសល.ក់នារីមូស្លីមជាង១០០នាក់។ នេះបើយោងតាមការចុះផ្សាយរបស់ BBC នៅព្រឹកថ្ងៃពុធ ទី ៥ ខែមករានេះ។ យុវជនមួយរូបនោះគឺជានិស្សិតផ្នែកវិស្វកម្មមកពីទីក្រុង Bangalore ប៉ុន្តែអត្តសញ្ញាណរបស់គាត់មិនត្រូវបានគេប្រកាសឲ្យដឹងឡើយ។ ចំណែកការចោទប្រកាន់ប្រឆាំងគាត់ក៏មិនទាន់ច្បាស់ផងដែរ ប៉ុន្តែគាត់គឺជាគាំទ្រកម្មវិធីមួយឈ្មោះ Bulli Bai។ នេះបើយោងតាមការបញ្ជាក់របស់ប៉ូលីសប្រាប់សារព័ត៌មាន BBC។ កម្មវិធី Bulli Bai មាននៅលើវេបសាយ GitHub និងត្រូវបានគេលុបចោល ក្រោយពេលមានការខឹងសម្បារយ៉ាងខ្លាំង។ រូបភាពជាច្រើនរបស់អ្នកកាសែត និងសកម្មជនមូស្លីមជាច្រើនត្រូវបានគេប្រើប្រាស់ដោយគ្មានការអនុញ្ញាតពីពួកគេនៅលើកម្មវិធីនោះ និងត្រូវបានដាក់លក់ក្នុងការដេញថ្លៃក្លែងក្លាយ។

នេះជាការប៉ុនប៉ងលើកទី ២ហើយដើម្បីយាយីដល់ស្ត្រីមូស្លីម តាមរយៈការល.ក់ដេញថ្លៃពួកគេតាមអ៊ីនធឺណេត។ កាលពីខែកក្កដា ឆ្នាំមុន កម្មវិធី (App) និងគេហទំព័រមួយឈ្មោះ 'Sulli Deals) បានបង្កើតកម្រងព័ត៌មានរបស់ស្ត្រីមូស្លីមជាង ៨០នាក់ ដោយប្រើប្រាស់រូបភាពដែលស្ត្រីទាំងនោះបង្ហោះរាល់ថ្ងៃ យកទៅបង្ហោះបន្ត និងធ្វើការដេញថ្លៃ។ ក្នុងករណីទាំងពីរនេះ ពុំមានការល.ក់ពិតប្រាកដឡើយ ប៉ុន្តែគោលបំណងនៃការប្រព្រឹត្តិបែបនេះគឺដើម្បីបង្ខូចកេរ្តិ៍ឈ្មោះ និងបន្ថោកតម្លៃរបស់ស្ត្រីមូស្លីម។ ទោះបីជាប៉ូលីសឥណ្ឌាបានធ្វើការស៊ើបអង្កេតលើករណី Sulli Deals ក្តី គ្មាននរណាម្នាក់ត្រូវបានចោទប្រកាន់ឡើយ។ នៅពេលព័ត៌មាននៃកម្មវិធី Bulli Bai បែក

ផ្លាយ អ្នកនិពន្ធម្នាក់ឈ្មោះ Nabiya Khan បានធ្វើការបង្ហោះក្នុងបណ្ដាញសង្គម Twitter ថាប៉ូលីសទីក្រុង Delhi មិនទាន់បានចាត់វិធានការលើបណ្ដឹងរបស់នាងកាលពីឆ្នាំ ២០២១ឡើយ៕ (យោងតាមប្រភព៖ BBC)

## ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០២២

## ជនជាតិថៃចំនួន៥០០ នាក់ត្រូវបានសង្គ្រោះ ពីក្រុមបោកប្រាស់ ដោយផ្ដល់ការងារ ក្នុងប្រតិបត្តិការរួមគ្នារវាងនគរបាលកម្ពុជា និងថៃ ក្នុងខែធ្នូតែមួយ

https://www.khmertimeskh.com/ ខ្មែរថាមស៍ January 7, 2022

ជំនួយការអគ្គស្នងការនគរបាលជាតិ លោក Surachate Hakparn បានមានប្រសាសន៍ កាលពីថ្ងៃព្រហស្បតិ៍ថា អាជ្ញាធរថៃបាន និងកំពុងសម្របសម្រួលជាមួយមន្ត្រីកម្ពុជា ក្នុងការជួយសង្គ្រោះពលករថៃ ដែលត្រូវបានគេបោកប្រាស់។ មនុស្សជាច្រើនត្រូវបានបង្ខំឱ្យធ្វើការនៅជិតព្រំដែនជាមួយខេត្តត្រាត និងកន្លែងផ្សេងទៀតក្នុងខេត្តពោធិ៍សាត់ កោះកុង ខេត្តព្រះសីហនុ និងក្រុងប៉ោយប៉ែត។ លោកឧត្តមសេនីយ៍ទោ Surachat បានមានប្រសាសន៍ថា អ្នកវិនិយោគចិនមួយចំនួននៅកម្ពុជា ដែលជាប់ពាក់ព័ន្ធក្នុងរឿងនេះ មិនទាន់ចំណាត់ការអំពីការអនុវត្តន៍ច្បាប់របស់ប្រទេសកម្ពុជា និងមិនទាន់បានដោះលែងពលករថៃ ពីសណ្ឋាគារ និងភោជនីយដ្ឋាននៅឡើយទេ។ គាត់មានប្រសាសន៍ថា មនុស្សចំនួន៥០២នាក់ ត្រូវបានបញ្ជូនត្រឡប់ពីប្រទេសកម្ពុជាវិញ។ ជនជាតិថៃប្រហែល ១,០០០ នាក់ទៀតជាប់នៅទីនោះ ដែលត្រូវបានបង្ខិតបង្ខំកម្លាំងពលកម្ម ហើយកំពុងត្រូវការការជួយសង្គ្រោះ។ លោកបានព្រមានអ្នកស្វែងរកការងារឱ្យប្រុងប្រយ័ត្ន និងកុំចាញ់បោកតាមការផ្ញើសារ និងការបង្ហោះតាមហ្វេសប៊ុកអញ្ជើញពួកគេឱ្យមកធ្វើការជាមួយនឹងប្រាក់ខែពី២ម៉ឺន ទៅ៣ម៉ឺនបាត ក្នុងប្រទេសកម្ពុជា។ លោកបន្តថា ពួកគេគួរស្វែងរកការបញ្ជាក់ពីនាយកដ្ឋានការងារជាមុនសិន។

កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ក្រុមការងារចម្រុះកម្ពុជា-ថៃ បានជួយសង្គ្រោះពលករថៃចំនួន ៩៩នាក់ ដែលត្រូវបានបោកបញ្ឆោត និងបង្ខំឱ្យធ្វើការដោយខុសច្បាប់នៅក្នុងរាជធានីភ្នំពេញ ដែលពួកគេត្រូវបានឃុំខ្លួនក្នុងអគារមួយដោយក្រុមជនជាតិចិន។ ប្រតិបត្តិការជួយសង្គ្រោះនេះ ត្រូវបានធ្វើឡើងដោយអាជ្ញាធរកម្ពុជា នគរបាលថៃ និងមន្ត្រីស្ថានទូតថៃ។ ក្រុមមន្ត្រីបានឡោមព័ទ្ធអគារដែលត្រូវបានយាមដោយជនជាតិចិនជិត ៥០នាក់។ មន្ត្រីចាប់បានជិត ៤០ នាក់ក្នុងចំណោមពួកគេ និងបានជួយសង្គ្រោះជនជាតិថៃទាំងអស់ចេញពីអគារនោះ។ ប៉ូលិសថៃបាននិយាយថា ចាប់តាំងពីខែមករា ដល់ចុងខែវិច្ឆិកា ជនរងគ្រោះដែលជាប់សង្ស័យពីការជួញដូរមនុស្សចំនួន ៣៦១នាក់ ត្រូវបាននាំត្រឡប់ពីប្រទេសកម្ពុជាវិញកាលពីឆ្នាំមុន ហើយគិតត្រឹមខែធ្នូ ចំនួនអ្នកដែលត្រូវបានជួយសង្គ្រោះបានកើនឡើងដល់ជិត ៩០០នាក់ ខណៈដែលជនជាតិថៃមួយចំនួនត្រូវបានគេជឿថាបានរត់គេចខ្លួន ឬមួយត្រូវបានបោះបង់ចោល ដោយអ្នកបង្ខាំងរបស់ពួកគេ។

កាលពីខែកញ្ញាឆ្នាំមុន ខ្មែរថាមស៍ នៅក្នុងការបង្ហាញជាបន្តបន្ទាប់អំពីក្រុមល្បែងស៊ីសងតាមអ៊ីនធឺណិតដែលប្រតិបត្តិការក្នុងសហគមន៍ដែលមានអគារខ្ពស់ៗក្នុងខេត្តព្រះសីហនុ ត្រូវបានលាតត្រដាងពីវត្តមានរបស់ក្រុមនេះ។ ចាប់តាំងពីពេលនោះមក ខ្មែរថាមស៍ បានសិក្សាយ៉ាងប្រាកដថា ក្រុមទាំងនេះបានរីករាលដាលពាសពេញប្រទេស។ កាលពីខែតុលាឆ្នាំមុន ជនជាតិឥណ្ឌូណេស៊ីចំនួន ៤១នាក់ក៏ត្រូវបានជួយសង្គ្រោះចេញពីក្រុមទាំងនោះនៅខេត្តព្រះសីហនុផងដែរ ខណៈដែលស្ថានទូតផ្សេងទៀតដែលជនជាតិរបស់ពួកគេក៏ត្រូវបានឃុំខ្លួននៅទីនោះដែរនោះ នៅតែស្ងាត់ស្ងៀម ដូចជាស្ថានទូតហ្វីលីពីន ស្ថានទូតអាហ្វ្រិកខាងត្បូងដែលមិនមានបេសកកម្មនៅកម្ពុជា ស្ថានទូតឥណ្ឌា បង់ក្លាដែស ក្នុងចំណោមស្ថានទូតផ្សេងទៀត។ ក្រុមទាំងនេះចាប់តាំងពីកាសែតខ្មែរថាមស៍បាន

លាតត្រដាង បានផ្លាស់ប្តូរទៅកន្លែងផ្សេងទៀតនៃប្រទេសកម្ពុជា ដើម្បីបង្វែរដាន ទៅពាសពេញប្រទេស ហើយមន្ត្រីនគរបាលចិនបានប្រាប់ខ្មែរថាមស័ថាជនជាតិផ្សេងៗគ្នា ត្រូវបានគ្រប់គ្រងតំបន់ផ្សេងៗគ្នា ទាក់ទងនឹងល្បែងអនឡាញ ដូចជា Macao Scam ការក្លែងបន្លំ ការក្លូនកាតឥណទាន និងការបោកប្រាស់តាមអ៊ីនធឺណិត។

## ស្ត្រីវៀតណាម ៧នាក់ ដែលគេជួញដូរ មកកម្ពុជា ធ្វើជាស្ត្រីបម្រើផ្លូវភេទ នៅខារ៉ាអូខេ និងហាងម៉ាសា ត្រូវបានជួយសង្គ្រោះ

https://dap-news.com/international/ BySS107Posted on January 6, 2022

បរទេស៖ ប៉ូលិសបានជួយសង្គ្រោះស្ត្រីវៀតណាម៧នាក់ ដែលត្រូវគេរត់ពន្ធមកប្រទេសកម្ពុជា ដើម្បីធ្វើពេស្យាចារ ហើយប៉ូលីសក៏បានចាប់ខ្លួនជនសង្ស័យជួញដូរមនុស្ស៣នាក់ផងដែរ។

យោងតាមសារព័ត៌មាន VN Express ចេញផ្សាយនៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២២ បានឱ្យដឹងថា ប៉ូលីសខេត្ត Dong Nai បានឃាត់ខ្លួន ឈ្មោះ Nguyen Tien Dung អាយុ២៥ ឆ្នាំ, Loc Thi Luan អាយុ ២១ ឆ្នាំ និងឈ្មោះ Ngo Nguyen Dong Khoa អាយុ ៥៤ ឆ្នាំពីបទ "ជួញដូរមនុស្ស" និង "រៀបចំការធ្វើចំណាកស្រុកខុសច្បាប់" ។ បើតាមអ្នកស៊ើបអង្កេត គឺឈ្មោះ Dung និងឈ្មោះ Luan បានសហការផ្សព្វផ្សាយព័ត៌មានអំពីស្ត្រីដែលត្រូវបានជ្រើសរើសឱ្យធ្វើការនៅក្នុងហាងខារ៉ាអូខេ និងកាស៊ីណូនៅកម្ពុជា ដែលមានប្រាក់ខែខ្ពស់។ សម្រាប់បុគ្គលិកម្នាក់ៗដែលត្រូវបានជ្រើសរើស Dung បានចំណាយប្រាក់ចំនួន ១០ លានដុង (៤៤០ ដុល្លារ)។ បន្ទាប់មក ឈ្មោះ Dung និង Khoa បាននាំស្ត្រីទាំងនោះឆ្លងកាត់ខេត្តភាគខាងត្បូងនៃខេត្ត Long An, Tay Ninh និង ខេត្ត Binh Phuoc មុនពេលរត់ពន្ធពួកគេចូលមកប្រទេសកម្ពុជា។

នៅប្រទេសកម្ពុជា ស្ត្រីទាំងនោះត្រូវបានបង្ខំឱ្យធ្វើជាស្រីពេស្យាក្នុងផ្ទះបន ដែលក្រោមរូបភាពជាហាងខារ៉ាអូខេ និងហាងម៉ាស្សា៕ ប្រែសម្រួលៈ ណៃ តុលា

## វៀតណាម ចាប់ខ្លួនមេជួញដូរក្រលៀនខុសច្បាប់ ត្រៀមផ្តន្ទាទោសជាប់គុកមួយជីវិត

https://www.kampucheathmey.com/ ថ្ងៃសុក្រ ៧ មករា ២០២២ដោយ Sok Chivon

ប៉ូលិសនៅសង្កាត់ Ha Dong ទីក្រុងហាណូយបានចាប់ខ្លួនបុរសអាយុ ៣២ ឆ្នាំម្នាក់ពីបទជួញដូរក្រលៀនសម្រាប់អ្នកជំងឺដែលត្រូវការ ។ បន្ទាប់ពីការចាប់ខ្លួន លោក Tran Van Truong ត្រូវបានស៊ើបអង្កេតពីបទ "ជួញដូរសរីរាង្គមនុស្ស"ជាបទល្មើសដែលអាចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតយោងតាមក្រមព្រហ្មទណ្ឌវៀតណាម ។ លទ្ធផលស៊ើបអង្កេតបឋមបានឲ្យដឹងថា នៅក្នុងខែកក្កដា ឆ្នាំ ២០២១ លោក Truong បានទាក់ទងគ្នាជាមួយស្ត្រីម្នាក់ឈ្មោះ PTV អាយុ ២៧ ឆ្នាមកពីខេត្ត Thanh Hoa ភាគខាងជើង ដែលចង់លក់ក្រលៀនរបស់នាង និងម្នាក់ទៀតឈ្មោះ MTP អាយុ ៤៧ ឆ្នាំជាអ្នកសង្កាត់ Ha Dong ដែលត្រូវការការប្តូរក្រលៀន ។ ភាគីទាំងបីបានឈានដល់កិច្ចព្រមព្រៀងចំនួន ៥៦០ លានដុង (២៤,៦០០ ដុល្លារអាមេរិក) រួមទាំងប្រាក់បន្ថែមប្រហែល ៣០០ លានដុង (១៣,១៨៣ ដុល្លារ) សម្រាប់លោក Van Truong ។ ក្រោយមកនាង PTV បានទទួលការវះកាត់ប្តូរក្រលៀនដោយជោគជ័យនៅមន្ទីរពេទ្យកាលពីថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០២១ បន្ទាប់មកគ្រួសាររបស់នាងបានចំណាយប្រាក់ចំនួន ១៨០ លានដុង (៧,៩៩០ ដុល្លារ) ឲ្យលោក Van Truong ។ មនុស្សមួយចំនួនបានរាយការណ៍ពីសេវាឈ្មួញជើងសារបស់លោក Van Truong ទៅកាន់ប៉ូលិស ហើយបន្ទាប់ពីនោះពួកគេជំរុញឲ្យមានការចាប់ខ្លួនបុរសរូបនេះ ខណៈនៅប៉ុស្តិ៍ប៉ូលិសលោក Van Truong បានសារភាពថាពិតជាបានធ្វើអាជីវកម្មខុសច្បាប់នេះមែន ៕

## ពលរដ្ឋខ្មែរ២៤នាក់ និងពលរដ្ឋថៃ៥នាក់ ត្រូវយោធាថៃឃាត់ខ្លួន

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ០៩ ខែ មករា ឆ្នាំ ២០២២ ម៉ោង ១៣:៥៣

ខេត្តបន្ទាយមានជ័យ ៖ សមត្ថកិច្ចតាមបន្ទាត់ព្រំដែនបានឲ្យដឹងថា ៖ នៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០២២នេះ យោធាកងវរយប្រាណទី១,៣០៥ បានចុះដើរល្បាតក្នុងភូមិសាស្ត្រដែលខ្លួនទទួលខុសត្រូវ ហើយក៏ប្រទះឃើញមនុស្សគួរឲ្យសង្ស័យមួយក្រុមដើរមកតាមច្រករបៀង រួចសំដៅចូលមកប្រទេសថៃ ក្នុងបរិវេណភូមិកុតហ៊ីន ឃុំផានសឹក ស្រុកអារញ្ញ ខេត្តស្រះកែវ ចំនួន១៣នាក់ ក្នុងនោះប្រុស០៦នាក់ ស្រី០៦នាក់ និងក្មេងស្រីម្នាក់ ទើបនាំខ្លួនមកសួរនាំបន្ថែម។

ក្រោយពីសមត្ថកិច្ចថៃសួរនាំ ទើបបានឲ្យដឹងថា ពលរដ្ឋខ្មែរមួយក្រុមនេះទៅធ្វើការខាងសំណង់នៅស្រុកបាងកះពិ ក្រុងបាងកក ដោយចំណាយប្រាក់ថ្លៃមេខ្យល់ជូនមក និងធ្វើដំណើរនេះ ក្នុងម្នាក់១៧,០០០បាត។ បន្ទាប់ក៏មានកម្លាំងយោធាអង្គភាពចំពោះកិច្ចទី១២ ក៏បានឃាត់ខ្លួនពលរដ្ឋខ្មែរបន្ថែម២នាក់ទៀត ក្នុងនោះប្រុសម្នាក់ នៅបរិវេណជិតច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត ហើយក្រោយពីសួរនាំ ពួកគេបានឆ្លើយថា ធ្វើដំណើរមកពីខេត្តបន្ទាយមានជ័យ ដោយចំណាយប្រាក់ឲ្យមេខ្យល់ជនជាតិខ្មែរមិនស្គាល់ឈ្មោះ ក្នុងម្នាក់១៥,០០០បាត ក្នុងបំណងទៅធ្វើការខាងសំណង់នៅខេត្តស្រះកែវ។

សមត្ថកិច្ចថៃតាមបន្ទាត់ព្រំដែន ក៏បានបញ្ជាក់ថា៖ កម្លាំងទាហានថៃប្រចាំស្រុកតាប្រាយ៉ា ខណៈកំពុងដើរល្បាត ក៏ប្រទះឃើញពលរដ្ឋខ្មែរចំនួន០៩នាក់បន្ថែមទៀត ដែលក្នុងនោះប្រុស០៤នាក់ និងស្រី០៥នាក់នាក់ នៅបរិវេណភូមិប៉ារ៉ៃថ្មី ឃុំប៉ារ៉ៃ ស្រុកអារញ្ញ ខេត្តស្រះកែវ ដែលពួកគាត់ទាំងនោះ ធ្វើដំណើរមកពីខេត្តបន្ទាយមានជ័យ ប្រទេសកម្ពុជា ហើយមានបំណងទៅធ្វើការនៅស្រុកអារញ្ញ ខេត្តស្រះកែវ ។ ដូច្នេះសរុបទាំង០៣ករណីខាងលើនេះ គឺមានពលរដ្ឋខ្មែរចំនួន២៤នាក់ ក្នុងនោះស្រី១៣នាក់ (ក្មេងស្រីម្នាក់)។

សមត្ថកិច្ចថៃតាមបន្ទាត់ព្រំដែន បានបញ្ជាក់ទៀតថា បន្ទាប់មកទៀត ទាហានថៃក៏បានឃាត់ខ្លួនស្ត្រីជនជាតិថៃ៣នាក់ និងមេខ្យល់ជនជាតិថៃ២នាក់ ដែលកំពុងលួចឆ្លងដែនចូលមកប្រទេសកម្ពុជាវិញផងដែរ នៅត្រង់បរិវេណភូមិទព់សៀម ឃុំ/ស្រុកតាប្រាយ៉ា ខេត្តស្រះកែវ។ ហើយក្រោយពេលសមត្ថកិច្ចថៃ សួរនាំពលករខ្មែរទាំង២៤នាក់ និងពលរដ្ឋថៃទាំង៥នាក់រួចរាល់ ក៏បានបញ្ជូនទៅឲ្យជំនាញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់បន្តទៀត៕

# ថ្ងៃទី ១១ ខែ មករា ឆ្នាំ២០២២

## អាជ្ញាធរស្រុកសំពៅលូន បន្តទទួល
## ប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ព្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/01/09/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង១៧ និង៥០នាទី នាថ្ងៃសៅរ៍ ៦កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៨ ខែមករា ឆ្នាំ២០២២ ដោយអនុវត្តន៍តាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក មឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន ចំនួន០២នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុ

សេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០២នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក-អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្ត បាត់ដំបង សរុបចំនួន១៤នាក់ ស្រី០៧នាក់ ។

ក្រោយពីទទួល កម្លាំងយើងបានកត់ឈ្មោះ ចុះកំណត់ហេតុដកហូតកាំបិតចំនួន០៤ដើម និងអប់រំណែនាំ រួចកម្លាំងយើងបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍ ដែលជាលទ្ធផលអវិជ្ជមានទាំងអស់ រួចទើបអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួនចំនួន០៨នាក់ ស្រី០៣នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ) ចំណែកអ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្កេនអត់ចេញចំនួន ០៦នាក់ ស្រី០៤នាក់ ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័ក រោងចក្រម្សៅមី ស្ថិតក្នុងភូមិអូរល្វា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

## កងកម្លាំងអាជ្ញាធរ បន្តទទួលពលករ
## វិលត្រឡប់មកស្រុកវិញ ដែលភាគីថៃ បញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្រុកកំរៀង

https://gdlf-kh.com/ 2022/01/09/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃទី០៩ ខែ មករា ឆ្នាំ២០២២ ដោយអនុវត្តន៍តាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវរកមុខសញ្ញា មេខ្យល់នាំពលករចេញដោយមិនស្របច្បាប់ក្នុងភូមិសាស្ត្រ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរ:៨១៩ បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់សហការជាមួយកម្លាំងកងយោធពលខេរភូមិន្ទ និងក្រុមគ្រូពេទ្យ បានទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង។

ពលករដែលវិលត្រលប់មកកម្ពុជាវិញ សរុបចំនួន១៦១នាក់, ស្រី៦២នាក់ និងក្មេង៣១នាក់ បន្ទាប់ពីសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩រួចរាល់ ក្រុមគ្រូពេទ្យបានធ្វើតេស្តរហ័ស និងជាលទ្ធផល គឺអវិជ្ជមានកូវីដ-១៩ ទាំងអស់។ ក្នុងនោះពលករដែលមានកាតចាក់វ៉ាក់សាំងចំនួន១១៤នាក់ (ស្រី៤១នាក់, ក្មេង២២នាក់) ចំណែកពលករចំនួន៤៧នាក់, ស្រី២១នាក់ និងក្មេង៩នាក់ ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន។ ដោយបានចាក់វ៉ាក់សាំងអោយក្មេងចាប់ពីអាយុ៥ឆ្នាំដល់១៨ឆ្នាំ ចំនួន៨នាក់ (ស្រី៦នាក់) ហើយក្រុមគ្រូពេទ្យអនុញ្ញាតអោយត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ។

## អ្នកជួញដូរមនុស្សប្រើបណ្តាញសង្គមដើម្បីល្បួងអ្នកស្វែងរកការងារធ្វើមកកម្ពុជា

https://www.khmertimeskh.com/ 11/01/2022

អ្នកជួញដូរមនុស្សក្នុងប្រទេសវៀតណាមកំពុងស្វែងរកវិធីច្នៃប្រឌិតបន្ថែមទៀត ដើម្បីល្បួងជនរងគ្រោះនៅក្រៅប្រទេសដើម្បីធ្វើការកេងប្រវ័ញ្ច។ តាមរយៈបណ្តាញសង្គមដូចជា Facebook ឬ Zalo ពួកគេផ្តល់ការងារដែលមានប្រាក់ខែល្អនៅកាស៊ីណូ ឬហ្គេមអនឡាញក្នុងប្រទេសកម្ពុជា មុនពេលចាប់ផ្តើមការដាក់អន្ទាក់របស់ពួកគេ។ ក្រោយមកដល់ប្រទេសកម្ពុជា ការងារទាំងនេះប្រែទៅជាការងារមិនពិត។ ផ្ទុយទៅវិញ ពួកគេត្រូវបានបង្ខំឱ្យសងបំណុលរបស់ពួកគេ ជាញឹកញាប់តាមរយៈការជួញដូរផ្លូវភេទ។ ត្រឹមតែមួយសប្តាហ៍កន្លងទៅនេះ ប៉ូលីសខេត្ត Đồng Nai បានចាប់ខ្លួនមនុស្សបីនាក់ ដែលសង្ស័យថា ជាប់ពាក់ព័ន្ធក្នុងការរៀបចំការជួញដូរមនុស្សមកប្រទេសកម្ពុជា សម្រាប់សកម្មភាពពេស្យាចារ។ ជនសង្ស័យមានឈ្មោះ Nguyễn Tiến Dũng អាយុ ២៤ ឆ្នាំ មកពីខេត្ត Hà Tĩnh Lộc Thi Luân អាយុ ២១ ឆ្នាំមកពីខេត្ត Nghệ An និង Ngô Nguyễn Đông Khoa អាយុ ៥៣ ឆ្នាំមកពីទី

ក្រុងហូជីមិញ ។ Dũng បានសារភាពចំពោះប៉ូលីសថា គាត់បានទទួលប្រាក់ចំនួន ១០ លានដុង ($448) សម្រាប់មនុស្សម្នាក់ៗដែលគាត់បានបញ្ជូនមកប្រទេសកម្ពុជាដើម្បីធ្វើការ។ Khoa បានយកជនរងគ្រោះរបស់គាត់នៅទីក្រុងហូជីមិញ ហើយនាំពួកគេទៅព្រំដែនកម្ពុជា។ បន្ទាប់មក គាត់បានប្រាប់ជនរងគ្រោះឲ្យឆ្លងដែនដោយខុសច្បាប់ចូលមកកម្ពុជា។ ក្នុងរយៈពេលមួយខែចុងក្រោយនេះ អ្នកទាំងបីត្រូវបានគេសង្ស័យថាបានជួញដូរស្ត្រីវៀតណាមរាប់សិបនាក់ឲ្យធ្វើការពេស្យាចារនៅហាងខារ៉ាអូខេ និងម៉ាស្សាក្នុងប្រទេសកម្ពុជា។ បើតាមលោកវរសេនីយ៍ទោ Võ Nhật Hồng Phúc លោក Dũng ជាមេក្រុមជួញដូរមនុស្ស។ ក្រុមនេះបានផ្សព្វផ្សាយការងារជាសាធារណៈនៅលើបណ្តាញទំនាក់ទំនងសង្គមដូចជា Facebook ឬ Zalo ដើម្បីល្បួងយុវជនដែលកំពុងស្វែងរកការងារ។

ពួកគេបានល្បួងជនរងគ្រោះមកប្រទេសកម្ពុជាដោយសន្យាអោយការងារដែលមានភាពសប្បាយៗនិងបានប្រាក់ខែខ្ពស់ចាប់ពីរាប់សិបលានដល់រាប់រយលានដុង។ ពួកគេបានប្រើរថយន្តទៅយកជនរងគ្រោះ រួចយកទៅតាមច្រកព្រំដែនក្នុងខេត្ត Long An និងខេត្ត Tây Ninh ។ ជនរងគ្រោះត្រូវបាននាំមកប្រទេសកម្ពុជាដោយខុសច្បាប់។ នៅថ្ងៃទី២៨ ខែធ្នូ ប៉ូលីសខេត្ត Đồng Nai ក៏បានចាប់ខ្លួនបុរស ៣ នាក់ និងស្ត្រីម្នាក់ផងដែរ ពីបទជាប់ពាក់ព័ន្ធការជួញដូរមនុស្ស រៀបចំការធ្វើចំណាកស្រុកខុសច្បាប់ និងនាំមនុស្សទៅក្រៅប្រទេសដើម្បីពេស្យាចារ។ ជនរងគ្រោះម្នាក់ឈ្មោះ D បានរាយការណ៍ថា នៅដើមខែមេសា ឆ្នាំ២០២១ នាងត្រូវបានផ្តល់ការងារនៅហាងខារ៉ាអូខេ និងភោជនីយដ្ឋានមួយកន្លែង ដែលមានប្រាក់បៀវត្សរ៍ប្រចាំខែពី ៨០-១០០ លានដុង (៣៤០០-៤.៣០០ ដុល្លារអាមេរិក)។ ពេលមកដល់ស្រុកខ្មែរ ការងារមិនបានដូចការរំពឹងទុកនោះទេ។ នៅពាក់កណ្តាលខែមិថុនា D និងជនរងគ្រោះមួយចំនួនទៀតបានរត់គេចខ្លួនហើយពួកគេបានទាក់ទងទៅស្ថានទូតវៀតណាមប្រចាំនៅកម្ពុជាដើម្បីសុំជំនួយ។ ការស៊ើបអង្កេតរបស់ប៉ូលីសបានរកឃើញភស្តុតាងដែលថា ជនសង្ស័យទាំងបួននាក់បាននាំស្ត្រីវៀតណាមជិតដប់នាក់ដែលមានអាយុពី ១៨-២៥ ឆ្នាំមកប្រទេសកម្ពុជាក្នុងចន្លោះខែមករាដល់ខែមិថុនាឆ្នាំ ២០២១ ដោយបង្ខំពួកគេឱ្យបម្រើផ្លូវភេទដល់ភ្ញៀវតាមហាង ហាងខារ៉ាអូខេ និងហាងម៉ាស្សា។ បើតាមតំណាងប៉ុស្តិ៍ព្រំដែន Hà Tiên ចាប់ពីដើមឆ្នាំ២០២១ រហូតមកដល់ពេលនេះ មន្ត្រីប៉ុស្តិ៍បានជួយសង្គ្រោះពលរដ្ឋវៀតណាមជាង ២០០នាក់ ពីកម្ពុជា។ ជនរងគ្រោះត្រូវបានគេល្បួងមកកម្ពុជាឱ្យធ្វើការនៅតាមក្រុមហ៊ុន គ្រឹះស្ថានហ្គេម សេវាកម្សាន្ត និងក្រុមហ៊ុននៅកំពង់សោម។

លោកវរសេនីយ៍ឯក Nguyen Nguyễn Đức Việt អនុប្រធានប៉ុស្តិ៍ការពារព្រំដែននៃច្រកទ្វារព្រំដែនអន្តរជាតិ Hà Tiên បាននិយាយថា ក្នុងករណីជាច្រើនជនរងគ្រោះត្រូវបានគេបោកបញ្ឆោត។ លោក Việt បាននិយាយថាជនរងគ្រោះខ្លះចង់រត់គេចពីថៅកែរបស់ពួកគេប៉ុន្តែមិនបានសម្រេច។ អ្នកខ្លះបានរងរបួសដោយលោតពីលើអគារដើម្បីចង់បានសេរីភាពមកវិញ។ លោក Việt បានបន្តទៀតថា "ស្ត្រីទាំងនោះត្រូវបានសន្យាអោយធ្វើការនៅក្នុងគ្រឹះស្ថានហ្គេម និងក្រុមហ៊ុន ប៉ុន្តែត្រូវបានគេលក់ទៅកន្លែងពេស្យាចារ"។ លោកបានបន្ថែមថា៖ «ប្រសិនបើសុខភាពជនរងគ្រោះមិនល្អគ្រប់គ្រាន់ក្នុងការធ្វើការ ថៅកែបង្ខំពួកគេឲ្យប្រើថ្នាំមេតំហ្វេតាមីន»។

កម្មករប្រុសម្នាក់អាយុ៣០ឆ្នាំដែលត្រូវបានគេជួយសង្គ្រោះពីគ្រឹះស្ថានមួយនៅខេត្តព្រះសីហនុបាននិយាយថាគាត់មិនអាចជឿថាគាត់នៅមានជីវិតដើម្បីត្រឡប់ទៅប្រទេសវៀតណាមវិញទេ។ បុរសអាយុ៣០ឆ្នាំ ជាជនរងគ្រោះដោយការកេងប្រវ័ញ្ចកម្លាំងពលកម្ម ។ គាត់មកកម្ពុជាដើម្បីរកការងារធ្វើ ប៉ុន្តែត្រូវបានឃុំខ្លួន និងជាប់ខ្នោះគ្រប់ពេល។ គាត់បានដេកព្យួរពីលើដំបូល ព្រោះគាត់មិនត្រូវបានអនុញ្ញាតឱ្យអង្គុយ ឬឈរឡើយ ។ គាត់បាននិយាយថា "ខ្ញុំមិនដឹងថាត្រូវហៅអ្នកណាឱ្យជួយទេ" គាត់បន្ថែមថានៅពេលនោះគាត់គ្រាន់តែគិតអំពីវិធីរស់រានមានជីវិតជាជាងវិធីត្រលប់ទៅប្រទេសវៀតណាមវិញ។ គាត់ត្រូវបានគេជួយសង្គ្រោះជាមួយយុវជនវៀតណាម ៨ នាក់ផ្សេងទៀត។ ពួកគេមកពីខេត្ត Hà Nam, Nam Dinh និង Hải Dương។ ពួកគេបាននិយាយថាពួកគេជាមិត្តភក្តិ

នឹងគ្នានៅជនបទ ហើយបានទៅប្រទេសកម្ពុជាដើម្បីស្វែងរកការងារតាមរយៈការផ្សាយពាណិជ្ជកម្មជ្រើសរើសបុគ្គលិកតាមបណ្ដាញសង្គម។ ពួកគេបានសន្យាផ្ដល់ប្រាក់បៀវត្សរ៍ប្រចាំខែពី ៣០ ទៅ ៤០ លានដុង ក្រៅពីកន្លែងស្នាក់នៅ។ ប៉ុន្តែ ពួកគេធ្វើការអស់រយៈពេលយូរដោយមិនបានប្រាក់ខែ។ ពេលពួកគេសុំលុយគេចាប់ដាក់ខ្នោះ ហើយបង្អត់បាយ។ ហើយអរគុណចំពោះភាពចិត្តល្អរបស់អ្នកយាមម្នាក់ដែលពួកគេអាចទាក់ទងពិភពខាងក្រៅ ហើយត្រូវបានជួយសង្គ្រោះ។ *VNS*

## ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០២២

### បញ្ឈប់ការចាញ់បោកមេខ្យល់ដែលចង់ទៅថៃ ជាក់ស្តែងនេះត្រូវយោធាចាប់ទាំងរស់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ១១ ខែ មករា ឆ្នាំ ២០២២ ម៉ោង ០៨:៣៦

ខេត្តបន្ទាយមានជ័យ ៖ ទាហានថៃបានបន្តចាប់ខ្លួនពលរដ្ឋខ្មែរកំពុងលួចឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃដោយខុសច្បាប់ ដោយលើកនេះចាប់បានចំនួន២៤នាក់ទៀតនៅតាម៣គោលដៅផ្សេងៗគ្នា គិតត្រឹមថ្ងៃទី០៨ មករា ឆ្នាំ២០២២ នៅបន្ទាត់ព្រំដែន ក្នុងភូមិសាស្ត្រស្រុកអារញ្ញ ខេត្តស្រះកែវ ។

មន្ត្រីទំនាក់ទំនងកម្ពុជា-ថៃបានប្រាប់ឱ្យដឹងដោយបានទទួលព័ត៌មានថា មានពលរដ្ឋខ្មែរជាពលករបានលួចឆ្លងដែនទៅរកការងារនៅប្រទេសថៃ ហើយក៏ត្រូវបានទាហានថៃឃាត់សរុបមានចំនួន២៤នាក់ (ស្រី១៣នាក់ ប្រុស៦នាក់ ក្មេង១នាក់)តាមបន្ទាត់ព្រំដែនភូមិសាស្ត្រភូមិកុតហ៊ីន ឃុំផាត់សឹក ស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ ។ មន្ត្រីរូបនោះបានបញ្ជាក់ទៀតថា ក្រោយពេលដែលទាហានឈុតខ្មៅថៃការពារព្រំដែនឃាត់ពលរដ្ឋខ្មែរចំនួន២៤នាក់ និងមេខ្យល់ជនជាតិថៃ៥នាក់ នាំយកទៅសាកសួរពួកគេប្រាប់ថា ពួកគាត់បានឆ្លងដែនដោយខុសច្បាប់ ដើម្បីទៅរកការងារធ្វើជាពលករនៅប្រទេសថៃ តាមរយៈមេខ្យល់ម្នាក់ក្នុងតម្លៃ៨.០០០បាត ដោយជូនទៅរកការងារធ្វើ ។ ប្រភពបន្តថា នៅពេលដែលមេខ្យល់កម្ពុជាទទួលលុយបានហើយក៏ជូនឆ្លងចូលដល់ទឹកដីថៃ ហើយប្រាប់ថាឱ្យអង្គុយចាំរថយន្តខាងថៃមកទទួលនៅព្រំដែន(ទឹកដីថៃ) ។ ប៉ុន្តែបែរជាត្រូវកម្លាំងយោធាឈុតខ្មៅចុះមកឃាត់ និងបញ្ជូនទៅអធិការនគរបាលស្រុកអារញ្ញ ដើម្បីអនុវត្តតាមច្បាប់តែម្តង ។

គួរបញ្ជាក់ថា នៅថ្ងៃទី១០ មករា ឆ្នាំ២០២២ នៅច្រកអូរបើជាន់ស្រុកអូរជ្រៅក្រុមការងារទទួលពលករខ្មែរដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាមានចំនួន២១៥នាក់ ស្រី១១៨នាក់ កុមារ៤១នាក់ ស្រី១៩នាក់ និងវិជ្ជមានកូវីដ.១៩ មានចំនួន១នាក់ អ្នកដែលចាក់វ៉ាក់សាំងដូសទី២រួចរាល់ មានឯកសារមានចំនួន១៩៤នាក់ ស្រី១០៧នាក់ ។

### ពលរដ្ឋខ្មែរ១០នាក់ត្រូវយោធាថៃ ឃាត់ខ្លួនព្រោះលួចឆ្លងដែនខុសច្បាប់

http://nokorwatnews.com/ 11/01/2022

ប្រទេសថៃ ៖ តាមសេចក្តីរាយការណ៍ពីសមត្ថកិច្ចនៅបន្ទាត់ព្រំដែនកម្ពុជា-ថៃបានឱ្យដឹងថា កាលពីថ្ងៃទី១០ខែមករាឆ្នាំ២០២២ ទាហានកងរយទី១២ របស់ថៃបានចុះល្បាតក្នុងភូមិសាស្ត្រទទួលខុសត្រូវរបស់ខ្លួនស្រាប់តែប្រទះឃើញក្រុមគួរឱ្យសង្ស័យធ្វើដំណើរតាមច្រករបៀងសំដៅចូលមកក្នុងទឹកដីថៃ ត្រង់បរិវេណភូមិណូន ផាត់ថះនា ឃុំផានសឹក ស្រុកអារញ្ញ ខេត្តស្រះកែវមាន ចំនួន១០នាក់ក៏ធ្វើការឃាត់ខ្លួនតែម្តង។ សូមបញ្ជាក់ថា នៅពេលសមត្ថកិច្ចថៃសួរនាំពលរដ្ឋខ្មែរទាំងអស់ខាងលើ ពួកគេបានឱ្យដឹងថា ពួកគេមកពីខេត្តបន្ទាយមានជ័យ ប្រទេសកម្ពុជា លួចឆ្លងចូលមក ដើម្បីទៅធ្វើការខាងសំណង់ក្នុងខេត្តឈុនបុរី ដោយថៅកែជនជាតិថៃជាអ្នកចំណាយលុយ

ចំនួន៦,៥០០បាតក្នុងការធ្វើដំណើរ រួចកាត់កងគ្នានៅពេលធ្វើការ ទើបសមត្ថកិច្ចថៃចាប់ឃុំអ្នកទាំងនោះ និងអនុវត្តតាមវិធានរបស់សុខាភិបាល រួចក៏បញ្ជូនទៅឱ្យសមត្ថកិច្ចប៉ូលិសស្រុកអារញ្ញ ដើម្បីចាត់ការតាមច្បាប់បន្ត៕

## អាជ្ញាធរស្រុកសំពៅលូន បន្តទទួល
## ប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/01/11/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង១៩និង៤០នាទី នាថ្ងៃចន្ទ ៨កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ ដោយអនុវត្តន៍តាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក មុឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន ចំនួន០២នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការកងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ឯក-អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្រ្ត ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្ត បាត់ដំបង សរុបចំនួន២៧នាក់ (ស្រី១៦នាក់ ក្មេង០៣នាក់ ក្មេងស្រី០១នាក់)។

ក្រោយពីទទួល កម្លាំងយើងបានកត់ឈ្មោះ ចុះកំណត់ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីពិនិត្យសម្ភារៈហាមឃាត់ និងធ្វើការដកហូតកាំបិតចំនួន០៦ដើម ញញួរ០២ដើម និងអប់រំណែនាំរួចកម្លាំងយើងបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍។ ជាលទ្ធផលអវិជ្ជមានទាំងអស់ រួចទើបអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន ចំនួន១៤នាក់ ស្រី០៧នាក់ ក្មេង០២នាក់ ក្មេងស្រី០១នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ) ចំណែកអ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្តេនអត់ចេញចំនួន ១៣នាក់ (ស្រី០៩នាក់ ក្មេងប្រុស០១នាក់) ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័ក រោងចក្រម្សៅមី ស្ថិតក្នុងភូមិអូរល្វា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

## កងកម្លាំងអាជ្ញាធរ បន្តទទួលពលករ
## វិលត្រឡប់មកស្រុកវិញ ដែលភាគីថៃ បញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្រុកកំរៀង

https://gdlf-kh.com/ 2022/01/11/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ ដោយអនុវត្តន៍តាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវរកមុខសញ្ញា មេខ្យល់នាំពលករចេញដោយមិនស្របច្បាប់ក្នុងភូមិសាស្រ្ត ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរៈ៨១៩ បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់សហការជាមួយកម្លាំងកងយោធពលខេមរភូមិន្ទ និងក្រុមគ្រូពេទ្យ បានទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង។ ពលករដែលវិលត្រលប់មកកម្ពុជាវិញ សរុបចំនួន១២៤នាក់, ស្រី៤៩នាក់ និងក្មេង២២នាក់ បន្ទាប់ពីសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩រួចរាល់ ក្រុមគ្រូពេទ្យបានធ្វើតេស្តហ័ស និងជា

លទ្ធផល គឺអវិជ្ជមានកូវីដ-១៩ ទាំងអស់។ ក្នុងនោះពលករដែលមានកាតចាក់វ៉ាក់សាំង ចំនួន៩២នាក់ (ស្រី៣៦នាក់, ក្មេង១៦នាក់) ចំណែកពលករចំនួន៣២នាក់, ស្រី១៣នាក់ និងក្មេង៦នាក់ ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន។ ដោយបានចាក់វ៉ាក់សាំងអោយក្មេងចាប់ពីអាយុ៥ឆ្នាំ ដល់១៨ឆ្នាំ ចំនួន៩នាក់ (ស្រី៣នាក់) ហេីយក្រុមគ្រូពេទ្យអនុញ្ញាតអោយត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ។

## ពលករខ្មែរជាង១២០នាក់ទៀត
## ត្រូវបានអាជ្ញាធរថៃបញ្ជូនត្រឡប់មកវិញតាមច្រកអូរអន្លក់ ខេត្តបាត់ដំបង

https://www.kampucheathmey.com/ ថ្ងៃអង្គារ ១១ មករា ២០២២ដោយ Sokhom Khon

ពលករខ្មែរចំនួន១២៤នាក់ទៀត ត្រូវបានថៃចាប់បានបញ្ជូនឲ្យត្រឡប់មកកម្ពុជាតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២២ នេះបើតាមការឲ្យដឹងរបស់ការិយាល័យផ្សព្វផ្សាយអប់រំនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង។ យោងតាមការឱ្យដឹងពីកម្លាំងសមត្ថកិច្ចប្រចាំមាត់ច្រក់ព្រំដែនបានបញ្ជាក់ថា ពលករដែលអាជ្ញាធរថៃបញ្ជូនមកកម្ពុជាវិញសរុបមានចំនួន១២៤នាក់(ស្រី៤៩នាក់ និងក្មេង២២នាក់)។ ពួកគេត្រូវបានកម្លាំងសមត្ថកិច្ចធ្វើការសួរនាំបន្ទាប់ពីមកដល់ដោយកត់ឈ្មោះចុះកំណត់ហេតុនិងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវីដ១៩ រួចក្រុមគ្រូពេទ្យធ្វើតេស្តរហ័សរកមេរោគកូវីដ-១៩ តែអវិជ្ជមានទាំងអស់។

ក្នុងចំណោមពលករទាំង១២៤នាក់បានចាក់វ៉ាក់សាំងចំនួន៩២នាក់(ស្រី៣៦នាក់និងក្មេង១៦នាក់) ចំណែកពលករចំនួន៣២នាក់ដែលមិនបានចាក់វ៉ាក់សាំង(ស្រី១៣នាក់និងក្មេង៦នាក់)ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ស្រុកសំពៅលូន ។ ពលករចំណាកស្រុកទាំងនោះបានឲ្យដឹងថា ការធ្វើចំណាកស្រុកខុសច្បាប់ពេលនេះ គឺធ្វើឡើងនៅតាមច្រករបៀងតូចៗនៃព្រំដែនប្រទេសទាំងពីរហើយភាគច្រើនគឺពលករត្រូវបានមេខ្យល់បញ្ចុះបញ្ចូលឲ្យទៅរកការងារធ្វើវិញ ។ បើតាមអាជ្ញាធរខេត្តព្រំដែនជាប់ប្រទេសថៃ បើទោះបីជាពលករអាចឆ្លងដែនទៅដល់ទឹកដីប្រទេសថៃ ក៏ត្រូវបានអាជ្ញាធរថៃចាប់ខ្លួនបញ្ជូនមកកម្ពុជាវិញជាបន្តបន្ទាប់ដែរ៕ អត្ថបទ៖ ណារី

## ១១ថ្ងៃ អគ្គកុងស៊ុលកម្ពុជា
## ជួយសម្របសម្រួលបញ្ជូនពលករខ្មែរមកពីប្រទេសថៃវិញ បានចំនួន១៧០ នាក់

https://www.kampucheathmey.com/ ថ្ងៃអង្គារ ១១ មករា ២០២២ដោយ Kang Tola

គិតចាប់ពីថ្ងៃទី១ ដល់ទី១១ ខែមករា ឆ្នាំ២០២១ អគ្គកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំខេត្តស្រះកែវ ប្រទេសថៃ បានអន្តរាគមន៍ជួយសម្របសម្រួលបញ្ជូនពលករខ្មែរ មកពីខេត្តនានា នៃប្រទេសថៃបានចំនួន ១៧០ នាក់ បានត្រឡប់មកកម្ពុជាវិញដោយសុវត្ថិភាព នេះបើតាមការឲ្យដឹងពីអ្នកនាំពាក្យ។

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជាបានឲ្យដឹងនារសៀលថ្ងៃទី១១ ខែមករា នេះថា ពលករខ្មែរទាំងនអស់នោះ ភាគច្រើនចូលតាមច្រកប៉ោយប៉ែត។ លោកថា ការដែលពួកគាត់ត្រឡប់មកវិញ ដោយសារតែពួកគាត់ជួបការលំបាក ក្នុងការរកការងារធ្វើ ដោយសារការរីករាលដាលជម្ងឺ Covid19 ហើយក៏បានសុំឲ្យអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវ ជួយអន្តរាគមន៍ បញ្ជូនមកកម្ពុជាវិញ។

ដោយឡែក រយៈពេលដូចគ្នានេះ អគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវប្រទេសថៃ ក៏បានជួយអន្តរាគមន៍បញ្ជូនពលរដ្ឋខ្មែរ ដែលលួចឆ្លងដែនខុសច្បាប់ ហើយត្រូវសមត្ថកិច្ចថៃឃាត់ខ្លួនចំនួន៤០ នាក់ ឲ្យបានត្រឡប់មកកម្ពុជាវិញផងដែរ៕ *ដោយ ៖ កោះកែវ*

## ថ្ងៃទី១៣ ខែ មករា ឆ្នាំ២០២២

### សាលាឧទ្ធរណ៍ជំនុំជម្រះជនជាតិចិនម្នាក់ ជួលស្ត្រីខ្មែរពពោះបង្កើតកូន

https://www.postkhmer.com/national/ គីម សារុំ | Publication date 11 January 2022 | 13:24 ICT

**ភ្នំពេញៈ** បុរសជនជាតិចិនម្នាក់ ត្រូវបានសាលាឧទ្ធរណ៍ភ្នំពេញ ជំនុំជម្រះនៅថ្ងៃទី ១០ មករា ក្នុងសំណុំរឿងជួលស្ត្រីខ្មែរម្នាក់ ឱ្យពពោះជំនួសបង្កើតកូន ដែលប្រព្រឹត្តក្នុងអំឡុងខែមិថុនាឆ្នាំ ២០១៧ នៅប្រទេសចិន និងនៅរាជធានីភ្នំពេញ បន្ទាប់ពីត្រូវសាលាដំបូងរាជធានីភ្នំពេញ ផ្តន្ទាទោសដាក់ពន្ធនាគារ ១៥ ឆ្នាំ។

ក្នុងបន្ទប់សវនាការនៅថ្ងៃទី ១០ មករា ដែលមានសមាសភាពចៅក្រម ៣ រូប និងមានលោកចៅក្រមស៊ីន វិសាល ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះនោះ បុរសជាប់ចោទឈ្មោះ XU WENJUN អាយុ ៣៥ ឆ្នាំ ជាជនជាតិចិនដីគោកនិយាយប្រាប់ចៅក្រមថា គាត់បានរៀបការជាមួយស្ត្រីជនជាតិចិនម្នាក់ នៅប្រទេសចិន ប៉ុន្តែគាត់បានលែងលះគ្នា ព្រោះរៀបការច្រើនឆ្នាំតែគ្មានកូន។ ជនជាប់ចោទបន្តថា មុនមកប្រទេសកម្ពុជា ក្នុងអំឡុងឆ្នាំ ២០១៧ គាត់បានទាក់ទងក្រុមហ៊ុនមួយដែលគាត់មិនចាំឈ្មោះនៅក្នុងប្រទេសចិន ឱ្យជួយរកស្ត្រីពពោះ ដើម្បីយកកូន។ រីឯភាគីខាងក្រុមហ៊ុននោះបានប្រាប់គាត់ថា ប្រទេសដែលអាចជ្រើសរើសនារីពពោះជំនួសបានមានប្រទេសថៃ ហុងកុង ប្រទេសរុស្ស៊ី ប្រទេសម៉ាឡេស៊ី និងប្រទេសកម្ពុជា ដែលតម្លៃជួលស្ត្រីពពោះមានពី ៨ ម៉ឺនដល់ ១០ ម៉ឺនដុល្លារអាមេរិក។

ជនជាប់ចោទថា៖ «ខ្ញុំមិនបានចាប់យកប្រទេសកម្ពុជាទេ តែខាងក្រុមហ៊ុនឱ្យខ្ញុំចាប់យកប្រទេសកម្ពុជា ហើយតម្រូវឱ្យខ្ញុំបង់លុយ ៥ ម៉ឺនដុល្លារ។ គ្រូពេទ្យបានយកទឹកកាមខ្ញុំមកប្រទេសកម្ពុជា ហើយថតរូបស្ត្រីម្នាក់ឈ្មោះ ហ៊ិន ដាណែត គឺជាមនុស្សដែលត្រូវបញ្ចូលមេជីវិតខ្ញុំ ដើម្បីឱ្យនាងពពោះឱ្យ»។ ជនជាប់ចោទឱ្យដឹងទៀតថា គាត់បានធ្វើដំណើរពីប្រទេសចិនមកកម្ពុជា ដើម្បីមើលស្ត្រីឈ្មោះ ហ៊ិន ដាណែត ដែលពពោះជិតគ្រប់ខែ រហូតដល់នាងបង្កើតបានកូនប្រុសម្នាក់។ ក្រោយមកកូនប្រុសនោះមានអាយុជាង ១ ឆ្នាំ (២០១៨) គាត់ក៏ធ្វើដំណើរមកប្រទេសកម្ពុជា ដើម្បីរត់ការយកក្មេងប្រុសនោះ ទៅនៅប្រទេសចិនជាមួយគាត់។ នៅពេលនោះ គាត់បានទៅពឹងពាក់អង្គការក្រៅរដ្ឋាភិបាលមួយធ្វើការខាងគាំពារកុមារ ដើម្បីពិគ្រោះយោបល់ តែបុគ្គលិកអង្គការនោះបាននាំគាត់ទៅជួបនគរបាលប្រឆាំងការជួញដូរមនុស្សហើយនគរបាលបានឃាត់ខ្លួនគាត់តែម្តង ប៉ុន្តែស្ត្រីឈ្មោះ ហ៊ិន ដាណែត ដោះលែងវិញ។ គាត់បានឱ្យគ្រូពេទ្យនៅកម្ពុជា និងនៅវៀតណាម ពិនិត្យ DNA រវាងគាត់ និងក្មេងប្រុសម្នាក់នោះហើយគ្រូពេទ្យបានបង្ហាញលទ្ធផលថា គាត់ និងក្មេងប្រុសនោះមាន DNA ដូចគ្នា។

សំណុំរឿងនេះត្រូវបានសាលាដំបូងរាជធានីភ្នំពេញផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារ ១៥ ឆ្នាំ ចោទពីបទអំពើលក់ដូរមនុស្ស សម្រាប់នាំឆ្លងដែនតាមមាត្រា ១៦ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ។ ប៉ុន្តែដោយមិនសុខចិត្តនឹងសាលក្រមនេះទើបគាត់ប្តឹងឧទ្ធរណ៍។

ជនជាប់ចោទ ប្រាប់ចៅក្រមក្នុងបន្ទប់សវនាការថ្ងៃទី ១០ មករា ថា៖ «ស្ត្រីឈ្មោះ ហ៊ិន ដាណែត ប្រាប់ខ្ញុំថាក្មេងប្រុសនោះពិតជាកូនរបស់ខ្ញុំមែនហើយ។ ក្មេងនោះខ្ញុំមានបំណងយកទៅប្រទេសចិន ចិញ្ចឹមថែរក្សាព្រោះជាកូនរបស់ខ្ញុំ។ ខ្ញុំសូមតុលាការដោះលែងខ្ញុំឱ្យមានសេរីភាពវិញ»។

លោក ជុំ សែនសុទ្ធា តំណាងមហាអយ្យការ សន្និដ្ឋានថា ជនជាប់ចោទប្រាប់តុលាការថា គាត់បានធ្វើលិខិតឆ្លងដែន និងសំបុត្រកំណើតឱ្យក្មេងប្រុសនោះ តែមិនឃើញមានដាក់បញ្ចូលក្នុងសំណុំរឿងទេ។ រីឯស្ត្រីឈ្មោះ ហ៊ិន

ដាណែត ក៏មិនទាន់បានសាកសួរផងទេ។ លោក សែនសុទ្ធា ថ្លែងថា៖ «ខ្ញុំស្នើសុំចៅក្រមប្រឹក្សា កោះហៅស្ត្រីរូបនេះ ចូលអះអាងជាសាក្សី ដើម្បីបញ្ជាក់ក្នុងរឿងនេះ»។

លោក ម៉ៃ វណ្ណាឌី ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ XU WENJUN សន្និដ្ឋានថា តុលាការបានចោទកូនក្តីលោកពាក់ព័ន្ធអំពើលក់ដូរមនុស្ស។ ប៉ុន្តែបើតាមការអះអាងថា ក្មេងម្នាក់នោះមាន DNA ដូចកូនក្តីលោកដែរ។ ហេតុដូច្នេះ គ្មានហេតុផលណា ដែលឪពុកយកកូនខ្លួនឯងទៅលក់ដូរនោះទេ ខណៈដែលគាត់ជាម្ចាស់រោងចក្រមួយដែរនោះ។ លោកថ្លែងថា៖ «បើគាត់មានចេតនាប្រព្រឹត្តបទល្មើសគឺគាត់មិនចាំបាច់ទៅពឹងពាក់អង្គការហើយឱ្យអង្គការនោះនាំទៅឱ្យសមត្ថកិច្ចចាប់ខ្លួនទេ។ ខ្ញុំស្នើសុំតុលាការដោះលែងកូនក្តីខ្ញុំវិញផង»។

ក្រោយជំនុំជម្រះរយៈពេលជិត ១ ម៉ោងមក លោកចៅក្រម ស៊ិន វិសាល ថ្លែងថា សាលដីកានៃសំណុំរឿងនេះនឹងប្រកាសនៅថ្ងៃទី ២៤ មករា៕

## កម្ពុជា-ហ្វីលីពីន ជំរុញកិច្ចសហប្រតិបត្តិការ វិស័យសន្តិសុខ ប្រយុទ្ធប្រឆាំងបទល្មើសឆ្លងដែន គ្រឿងញៀន បទល្មើសបច្ចេកវិទ្យា អំពើជួញដូរមនុស្ស និងការងារពង្រឹកសម្ព័ន្ធមេត្រីភាព

https://cen.com.kh/ Posted ByPen Srey NeatJanuary 12, 2022

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង បានសម្តែងការឯកភាព ចំពោះការលើកឡើងរបស់លោកជំទាវ Maria Amelita C.Aquino ឯកអគ្គរដ្ឋទូតថ្មីហ្វីលីពីន នៅក្នុងការជំរុញកិច្ចសហប្រតិបត្តិការ ក្របខណ្ឌក្រោមសមត្ថកិច្ចក្រសួងមហាផ្ទៃ ជាពិសេសវិស័យសន្តិសុខ ដែលមានកិច្ចសហប្រតិបត្តិការលើការងារ ប្រយុទ្ធប្រឆាំងបទល្មើសឆ្លងដែន បញ្ហាគ្រឿងញៀន បញ្ហាបទល្មើសបច្ចេកវិទ្យា និងអំពើជួញដូរមនុស្ស និងការងារពង្រឹកសម្ព័ន្ធមេត្រីភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនៃប្រទេសទាំងពីរ(កម្ពុជា-ហ្វីលីពីន)។

នារសៀលថ្ងៃពុធទី១២ ខែមករា ឆ្នាំ២០២២នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអនុញ្ញាតជូនលោកជំទាវ Maria Amelita C.Aquino ឯកអគ្គរដ្ឋទូតថ្មីហ្វីលីពីនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី សង្ឃឹមយ៉ាងមុតមាំថា នៅក្នុងអាណត្តិការទូតរបស់លោកជំទាវ កិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងរវាងកម្ពុជា និងហ្វីលីពីន នឹងកាន់តែបន្តរីកចម្រើនថែមទៀត រួមទាំងកិច្ចសហប្រតិបត្តិការក្របខណ្ឌគ្រួសារអាស៊ានផងដែរ។ ខណៈនៅក្នុងឆ្នាំ២០២២ ព្រះរាជាណាចក្រកម្ពុជាទទួលធ្វើជាប្រធានអាស៊ាន សម្តេចក្រឡាហោម បានជម្រាបជូនលោកជំទាវឯកអគ្គរដ្ឋទូតថា សម្តេចក៏សង្ឃឹមថា ប្រទេសហ្វីលីពីន នឹងបន្តចូលរួមគាំទ្រ ដល់ការបំពេញតួនាទីនេះរបស់កម្ពុជា ដើម្បីបម្រើផលប្រយោជន៍រួមរបស់អាស៊ានទាំងមូល ក៏ដូចជារួមចំណែកដល់ការពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងហ្វីលីពីន ឲ្យកាន់តែខ្លាំងក្លាថែមទៀតផងដែរ។

ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការ លើវិស័យ ដែលស្ថិតក្រោមសមត្ថកិច្ចក្រសួងមហាផ្ទៃ ដែលរួមមានទីមួយគឺវិស័យសន្តិសុខ និងទីពីរ គឺពាក់ព័ន្ធនឹងកំណែទម្រង់ រដ្ឋបាលថ្នាក់ក្រោមជាតិជាតិនោះ សម្តេចក្រឡាហោម បានសម្តែងក្តីសង្ឃឹមថា ភាគីទាំងពីរ នឹងបន្តពង្រីកកិច្ចសហប្រតិបត្តិការនេះ ឲ្យកាន់តែទូលំទូលាយថែមទៀត ជាពិសេសទៅលើការងារប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន និងការចែករំលែកបទពិសោធន៍ទៅវិញទៅមក ពាក់ព័ន្ធទៅនឹងការងារកំណែទម្រង់ រដ្ឋបាលថ្នាក់ក្រោមជាតិ។ សម្តេចក្រឡាក៏បានយកឱកាសនេះ ជម្រាបជូនលោកជំទាវ ពាក់ព័ន្ធទៅនឹងដំណើរការកំណែទម្រង់ រដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជាដែរ ដែលមកដល់ពេលនេះ រាជរដ្ឋាភិបាលកំពុងអនុវត្តផែនការជាតិរយៈពេល១០ឆ្នាំ ដំណាក់កាលទី២របស់ខ្លួន។ សម្តេចក៏បានជម្រាបជូនទៀតថា សម្តេចពិតជាមានមោទនភាព ដែលបានមើលឃើញនូវលទ្ធផល នៃកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅកម្ពុជា នា

ពេលកន្លងមក និងថានៅដំណាក់កាលទី២នេះ ក៏ជាដំណាក់កាលដ៏មានសារៈសំខាន់ ក្នុងការផ្ទេរនូវធនធាន និងអំណាច ទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែរ។

ជាការឆ្លើយតបលោកជំទាវ Maria Amelita C.Aquino បានជម្រាបសម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី នូវការចូលរួមសម្តែង ការអបអរសាទរ ចំពោះជោគជ័យ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការគ្រប់គ្រងបញ្ហាជំងឺកូវីដ ១៩ និងបានសម្តែងការវាយតម្លៃខ្ពស់ ចំពោះការចូលរួមចំណែកយ៉ាងសកម្ម របស់ក្រសួងមហាផ្ទៃ ក្នុងការសម្រេចបាននូវជោគជ័យ ទៅលើការងារគ្រប់គ្រង ក៏ដូចជាយុទ្ធនាការចាក់វ៉ាក់សាំង ប្រឆាំងនឹងជំងឺកូវីដ១៩។ លោកជំទាវក៏បានជម្រាបជូនសម្តេចក្រឡាហោមទៀតថា ហ្វីលីពីននៅតែបន្តគាំទ្រកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា ជាពិសេសក្នុងឱកាសដែលកម្ពុជាធ្វើជាប្រធានអាស៊ាន ព្រមទាំងនឹងបន្តចូលរួមគាំទ្រ រាល់ព្រឹត្តិការណ៍ដែលក្រសួងមហាផ្ទៃត្រូវធ្វើជាប្រធានដឹកនាំ នៅក្រោមក្របខណ្ឌនៃអាស៊ាននេះផងដែរ។ ក្រៅពីកិច្ចសហប្រតិបត្តិការពហុភាគី ក្នុងក្របខណ្ឌអាស៊ាន លោកជំទាវឯកអគ្គរដ្ឋទូត ក៏បានសម្តែងនូវចំណាប់អារម្មណ៍យ៉ាងខ្លាំង ក្នុងការពង្រីកនូវកិច្ចសហប្រតិបត្តិការទ្វេភាគី ឱ្យកាន់តែខ្លាំងឡើងថែមទៀត ជាពិសេសនៅក្នុងវិស័យសន្តិសុខ ដែលមានកិច្ចសហប្រតិបត្តិការលើការងារ ប្រយុទ្ធប្រឆាំងបទល្មើសឆ្លងដែន បញ្ហាគ្រឿងញៀន បញ្ហាបទល្មើសបច្ចេកវិទ្យា និងអំពើជួញដូរមនុស្សជាដើម ដែលកិច្ចការទាំងនេះ មួយផ្នែកធំស្ថិតក្រោមសមត្ថកិច្ចក្រសួងមហាផ្ទៃកម្ពុជា។

ទន្ទឹមនេះដែរលោកជំទាវ ក៏បានសម្តែងនូវបំណង ក្នុងការពង្រីកទំនាក់ទំនង រវាងរដ្ឋបាលថ្នាក់ក្រោមជាតិរបស់ហ្វីលីពីន និងកម្ពុជា តាមរយៈការបង្កើតឲ្យមានការផ្លាស់ប្តូរទស្សនកិច្ច និងការចងសម្ព័ន្ធមេត្រីភាព រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ នៃប្រទេសទាំងពីរផងដែរ។ លោកជំទាវក៏យកឱកាសនេះ ថ្លែងអំណរគុណសម្តេចក្រឡាហោម និងក្រសួងមហាផ្ទៃ ដែលកន្លងមក និងជាពិសេសនៅក្នុងវិបត្តិកូវីដ-១៩ បានជួយសម្រួលការងារពាក់ព័ន្ធ នឹងអន្តោប្រវេសន៍ ចំពោះពលរដ្ឋហ្វីលីពីនមួយចំនួន ដែលជួបការលំបាក ក្នុងកាលទេសៈនៃជំងឺកូវីដ-១៩នេះ។

ជាការឆ្លើយតប សម្តេចក្រឡាហោម បានថ្លែងអំណរគុណ ចំពោះការវាយតម្លៃទៅលើលទ្ធផលជាវិជ្ជមាននៃការងារគ្រប់គ្រងជំងឺកូវីដ-១៩ នៅព្រះរាជាណាចក្រកម្ពុជា និងអរគុណចំពោះការវាយតម្លៃ ទៅលើកិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងពីរកម្ពុជានិងហ្វីលីពីន។ សម្តេចក៏បានសម្តែងការឯកភាព ចំពោះការលើកឡើងរបស់លោកជំទាវ នៅក្នុងការជំរុញកិច្ចសហប្រតិបត្តិការ ក្របខណ្ឌក្រោមសមត្ថកិច្ចក្រសួងមហាផ្ទៃ ពិសេសការងារប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន និងការងារពង្រីកសម្ព័ន្ធមេត្រីភាព រវាងរដ្ឋបាលថ្នាក់ក្រោមជាតិនៃប្រទេសទាំងពីរ៕ រក្សាសិទ្ធិដោយ ៖ សុទ្ធ លី

## ថ្ងៃទី១៤ ខែ មករា ឆ្នាំ២០២២

### កងកម្លាំងអាជ្ញាធរ បន្តទទួលពលករ
### វិលត្រឡប់មកស្រុកវិញ ដែលភាគីថៃ បញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្រុកកំរៀង

https://gdlf-kh.com/ 2022/01/13/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃទី១៣ ខែ មករា ឆ្នាំ២០២២ ដោយអនុវត្តន៍តាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវរកមុខសញ្ញា មេខ្យល់នាំពលករចេញដោយមិនស្របច្បាប់ក្នុងភូមិសាស្ត្រ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរៈ៨១៩ បានចាត់កម្លាំងប៉ុស្តិ៍អូរ

អន្តក់សហការជាមួយកម្លាំងកងយោធពលខេរភូមិន្ទ និងក្រុមគ្រូពេទ្យ បានទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង។

ពលករដែលវិលត្រលប់មកកម្ពុជាវិញ សរុបចំនួន១៦០នាក់, ស្រី៥២នាក់ និងក្មេង២៩នាក់ បន្ទាប់ពីសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩រួចរាល់ ក្រុមគ្រូពេទ្យបានធ្វើតេស្តហ័ស និងជាលទ្ធផល គឺអវិជ្ជមានកូវីដ-១៩ ទាំងអស់។ ក្នុងនោះពលករដែលមានកាតចាក់វ៉ាក់សាំងចំនួន១១៣នាក់ (ស្រី៣៦នាក់, ក្មេង១៥នាក់) ចំណែកពលករចំនួន៤៧នាក់, ស្រី១៦នាក់ និងក្មេង១៤នាក់ ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន។ ដោយបានចាក់វ៉ាក់សាំងអោយក្មេងចាប់ពីអាយុ៥ឆ្នាំដល់១៨ឆ្នាំចំនួន១០នាក់ (ស្រី៣នាក់) ហើយក្រុមគ្រូពេទ្យអនុញ្ញាតអោយត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ។

## ថ្ងៃទី១៧ ខែ មករា ឆ្នាំ២០២២

### ថៃចាប់ពលករខ្មែរ ៥១ នាក់ ដែលលបឆ្លងដែនខុសច្បាប់

https://www.kampucheathmey.com/ ថ្ងៃសុក្រ ១៤ មករា ២០២២ដោយ Sorn Phanith

ពលករខ្មែរចំនួន ៥១ នាក់ ត្រូវបានកម្លាំងយោធាថៃ ដែលឈរជើងតាមខ្សែបន្ទាត់ព្រំដែនធ្វើការឃាត់ខ្លួនលើ ៣ គោលដៅ ក្នុងថ្ងៃតែមួយ ខណៈដែលពលករខ្មែរទាំងនេះ កំពុងលបឆ្លងដែនខុសច្បាប់ចូលក្នុងកិច្ចប្រតិបត្តិការរបស់កម្លាំងយោធាថៃ សហការជាមួយតម្រួតការពារព្រំដែនថៃ បានធ្វើឡើងនៅព្រឹកថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០២២ ដោយបានឃាត់ពលករខ្មែរសរុបមានចំនួន ៥១ នាក់ លើ៣គោលដៅក្នុងខេត្តស្រះកែវ។

គោលដៅទី ១ នៅត្រង់ចំណុចភូមិ ៤ ឃុំថាប់ក្រិក ស្រុកអារញ្ញប្រាថេត ដោយបានឃាត់ខ្លួនបានចំនួន ៣៥ នាក់ ក្នុងនោះស្រី ១៩ នាក់ ដែលពួកគេមកពីខេត្តបន្ទាយមានជ័យ ខេត្តព្រៃវែង ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តកំពង់ធំ និងខេត្តតាកែវ។

គោលដៅទី ២ ត្រង់ចំណុចភូមិ ១៣ ឃុំផានសឹក ស្រុកអារញ្ញប្រាថេត ដោយឃាត់ខ្លួនពលករខ្មែរបានចំនួន ១០ នាក់ ក្នុងនោះស្រី ១ នាក់ និងគោលដៅទី ៣ ត្រង់ចំណុចភូមិ ១០ ឃុំតាប្រាក់យ៉ា ស្រុកតាប្រាក់យ៉ា ខេត្តស្រះកែវ ដោយឃាត់ខ្លួនបានចំនួន ៦ នាក់ ក្នុងនោះមានស្រី ២ នាក់ និងក្មេងស្រី ១ នាក់ សរុបមានចំនួន ៥១ នាក់។ បច្ចុប្បន្នពលករខ្មែរទាំងអស់ ត្រូវបានបញ្ជូនទៅកាន់អធិការដ្ឋានខេត្តស្រះកែវហើយ៕

### កម្ពុជានឹងនៅបន្តធ្វើការសន្ទនាគ្នាជាមួយនឹងខាងភាគីប្រទេសថៃ ក្នុងការផ្ដល់វ៉ាក់សាំងកូវីដ ១៩ សម្រាប់ចាក់ជូនពលករខ្មែរដែលធ្វើការនិងស្នាក់នៅប្រទេសនេះ

https://www.postkhmer.com/national/ មុំ គន្ធា | Publication date 15 January 2022 | 09:23 ICT

មន្ត្រីជាន់ខ្ពស់នៃក្រសួងសុខាភិបាល បានប្រាប់ឱ្យដឹងថា ប្រទេសកម្ពុជានឹងនៅបន្តធ្វើការសន្ទនាគ្នាជាមួយនឹងខាងភាគីប្រទេសថៃ ក្នុងការផ្ដល់វ៉ាក់សាំងកូវីដ១៩ សម្រាប់ចាក់ជូនពលករខ្មែរដែលធ្វើការនិងស្នាក់នៅប្រទេសនេះ ខណៈដែលកម្ពុជាបានធ្វើការត្រៀមរួចរាល់ហើយ។

ទាក់ទងនឹងចំណុចនេះ លោកស្រី ឱ វណ្ណឌីន រដ្ឋលេខាធិការនៃក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ១៩ក្នុងក្របខ័ណ្ឌទូទាំងប្រទេស បានថ្លែងឱ្យដឹងក្នុងពេលលោកស្រីចុះពិនិត្យការងារចាក់វ៉ាក់សាំងកូវីដ១៩ ក្នុងខេត្តពោធិ៍សាត់កាលពីថ្ងៃទី១៣ ខែមករា ថា ការយកវ៉ាក់សាំងទៅចាក់បាន លុះត្រាតែមានកិច្ចសហប្រតិបត្តិការ ពិសេសត្រូវមានការឯកភាព យល់ព្រមពីសាម៉ីប្រទេសដែលបងប្អូនពលករខ្មែររស់នៅផងដែរ។ លោកស្រី ឱ វណ្ណឌីន មានប្រសាសន៍ថា ៖ «យើងមិនអាចកាន់វ៉ាក់សាំងយកទៅចាក់នៅស្រុកគេបាន

ទេ ដែលវាជារឿងមួយរំលោភនូវអធិបតេយ្យភាពរបស់ប្រទេសគេ។ ដូចនេះយើងត្រូវតែគោរពនូវច្បាប់អន្តរជាតិ គោរពនូវអធិបតេយ្យភាពរបស់ប្រទេសនីមួយៗ ហើយយើងត្រូវឈរលើសហប្រតិបត្តិការល្អរវាងប្រទេសដែលយើងត្រូវការធ្វើកិច្ចសហប្រតិបត្តិការជាមួយគេ»។

អ្នកនាំពាក្យក្រសួងសុខាភិបាលរូបនេះ បានបញ្ជាក់ទៀតថា កម្ពុជាបានធ្វើការត្រៀមរួចហើយនូវវ៉ាក់សាំងសម្រាប់ចាក់ជូនពលករខ្មែរ ប៉ុន្តែកម្ពុជានៅតែរង់ចាំនូវការអនុញ្ញាតពីប្រទេសនោះនៅឡើយ។ លោកស្រី ឱ វណ្ណឌីន ថា ៖ «រហូតមកដល់ពេលនេះ យើងមិនទាន់ទទួលបានចម្លើយអ្វីទាំងអស់ យើងនៅតែរង់ចាំរហូតមកដល់ពេលនេះ ។ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិកម្ពុជាបានព្យាយាមហើយ ហើយស្ថានទូតកម្ពុជាប្រចាំប្រទេសនោះ ខ្ញុំសុំមិននិយាយចំឈ្មោះប្រទេសនោះចុះ គឺបានខិតខំប្រឹងប្រែងហើយ តែអ្វីដែលសំខាន់គេនៅធ្វើការថ្លឹងថ្លែងសិន»។

គួររំឭកថា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្លាប់បានថ្លែងកាលពីដើមខែវិច្ឆិកា ឆ្នាំ២០២១កន្លងមកថា កម្ពុជាចាំបាច់ត្រូវធ្វើការជាមួយភាគីថៃ ដោយលោកចង់ជូនវ៉ាក់សាំងទៅឱ្យភាគីថៃជួយគ្រប់គ្រង ដឹកជញ្ជូន និងជួយចាក់ជូនពលករខ្មែរនៅក្នុងប្រទេសថៃ។ ក៏ប៉ុន្តែ ការធ្វើបែបនេះទៅបាន លុះត្រាតែមានការអនុញ្ញាតពីរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ។ លោកបានថ្លែងឱ្យដឹងថា ៖ «យើងមិនបានភ្លេចទៅដល់ពលរដ្ឋរបស់យើងដែលកំពុងធ្វើការនៅបរទេស ជាពិសេស នៅក្នុងព្រះរាជាណាចក្រថៃ ប៉ុន្តែបានឬមិនបានយ៉ាងណានោះ ក៏សុំឱ្យបងប្អូនពលករនៅក្នុងប្រទេសថៃមានការយោគយល់។ បើនៅក្នុងដីរបស់យើង អ្នកស្ម័គ្រចិត្តចាក់ គឺត្រូវតែបានចាក់»៕

## នគរបាលការពារព្រំដែន ទទួលពលរដ្ឋ វិលត្រឡប់ចូលប្រទេសកម្ពុជាវិញ ចំនួន២៤នាក់

https://cen.com.kh/ Posted ByPen Srey NeatJanuary 16, 2022

ខេត្តបាត់ដំបង ៖ នៅថ្ងៃសៅរ៍ ទី១៥ ខែមករា ឆ្នាំ២០២២ លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង ម៉េត នាយប៉ុស្តិ៍ សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន ដឹកនាំដោយលោកអនុសេនីយ៍ត្រី កៅ ប៊ុណ្ណា មេបញ្ជាការរងកងអនុសេនាធំ កម្លាំងយោធាវរសេនាតូច៥៣៣ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក អាំផន មេបញ្ជាការកងអនុសេនាធំ បានទទួលប្រជាពលរដ្ឋ ដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្ត បាត់ដំបង សរុបចំនួន២៤នាក់ ស្រី០៧នាក់ ។

ប្រតិបត្តិការនេះ ដោយអនុវត្តន៍តាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ។ ក្រោយពីទទួលកម្លាំងបានកត់ឈ្មោះ ចុះកំណត់ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីពិនិត្យសម្ភារៈហាមឃាត់ កាំបិត ០៦ដើម, កន្ត្រៃ០៣, ទល់ឡីរីស០១ និងបានអប់រំណែនាំរួចកម្លាំង បានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្ត និងពិនិត្យសុខភាពនៅ ប៉ុស្តិ៍ ដែលជាលទ្ធផលបង្ហាញថា « អវិជ្ជមាន» ទាំងអស់ រួចទើបអនុញ្ញាតឲ្យបងប្អូនត្រឡប់ ទៅមូលដ្ឋានរៀងៗខ្លួនចំនួន ១២នាក់ ស្រី០២នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ) ។ ចំណែកអ្នកមានប័ណ្ណចាក់វ៉ាក់សាំង តែស្កេនអត់ចេញចំនួន១២នាក់ ស្រី០៥នាក់ ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័ក រោងចក្រម្សៅមី ស្ថិតក្នុងភូមិអូរល្វា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង ៕ រក្សាសិទ្ធិដោយ ៖ សុទ្ធ លី

## ឈ្មួញរត់ពន្ធមនុស្សរស់លក្ខត្រូវប៉ូលិសចាប់បានក្រោយរត់គេចខ្លួន អស់ជិត ៧ឆ្នាំ

https://kohsantepheapdaily.com.kh/ ១៥ ខែ មករា ឆ្នាំ ២០២២ ម៉ោង ១៧:០៤

បុរសជនជាតិថៃវ័យ ៣៨ឆ្នាំម្នាក់ ដែលប៉ូលិសកំពុងតាមប្រមាញ់ពីបទរត់ពន្ធមនុស្ស ត្រូវបានចាប់ខ្លួននៅថ្ងៃសៅរ៍នេះ ក្នុងប្រទេសថៃ ក្រោយពេលរត់គេខ្លួនទៅធ្វើការនៅម៉ាឡេស៊ីអស់រយៈពេលជិត ៧ឆ្នាំ។ ជនសង្ស័យនេះឈ្មោះ Chamsudin Tordin ជាប្រជាជនមកពីស្រុក Muang នៃខេត្ត Satun ប្រទេសថៃ។ គាត់ត្រូវបានតុលាការចេញដីកាចាប់ខ្លួនកាលពីថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០១៥ពីបទរត់ពន្ធជនជាតិភាគតិចរ៉ូហ៊ីងយ៉ា។ ជនសង្ស័យបានរត់គេចខ្លួនទៅធ្វើកម្មករនេសាទក្នុងប្រទេសម៉ាឡេស៊ី។ ប៉ុន្តែទីបំផុតគាត់ត្រូវបានប៉ូលីសថៃឃាត់ខ្លួននៅថ្ងៃនេះក្រោយពេលវិលត្រឡប់មកថៃវិញតាមច្រកអន្តោប្រវេសន៍ Sadao។ នេះបើយោងតាមការបញ្ជាក់របស់ប៉ូលីសអន្តោប្រវេសន៍។ បុរសរូបនេះត្រូវបានចោទប្រកាន់ពីបទពាក់ព័ន្ធនឹងការរត់ជនអន្តោប្រវេន៍រ៉ូហ៊ីងយ៉ាជាច្រើននាក់តាមច្រកព្រំដែនម៉ាឡេស៊ីថៃ ក្នុងខេត្ត Skongkhla និងខេត្ត Satun កាលពីប៉ុន្មានឆ្នាំមុន។ គាត់ប្រឈមនឹងការចោទប្រកាន់ ៤ករណីរួមមានការឃុបឃិតក្នុងការជួញដូរមនុស្សដោយរំលោភបំពានលើមនុស្សអាយុក្រោម ១៥ឆ្នាំ ជួយអន្តោប្រវេសន៍ឆ្លងដែនចូលទឹកដីថៃដោយខុសច្បាប់ ឃុំខ្លួនមនុស្ស និងបំបិតសេរីភាព និងឃុបឃិតជាមួយក្រុមចាប់ជំរិតដើម្បីទាមទារយកប្រាក់លោះពីជនរងគ្រោះ៕ ( យោងតាមប្រភព៖ Bangkok Post )

## ថ្ងៃទី១៨ ខែ មករា ឆ្នាំ២០២២

## អាជ្ញាធរស្រុកសំពៅលូន បន្តទទួល
## ប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 2022/01/16/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង១៩និង១០នាទី នាថ្ងៃសៅរ៍ ១៣កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១៥ ខែមករា ឆ្នាំ២០២២ ដោយអនុវត្តន៍តាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី កៅ ប៊ុណ្ណា (មេបញ្ជាការរងកងអនុសេនាធំ) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០២នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក-អាំផន (មេបញ្ជាការកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង សរុបចំនួន២៤នាក់ (ស្រី០៧នាក់)។

ក្រោយពីទទួល កម្លាំងយើងបានកត់ឈ្មោះ ចុះកំណត់ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីពិនិត្យសម្ភារៈហាមឃាត់ កាំបិត០៦ដើម, កន្ត្រៃ០៣, ទួណឺវីស០១ និងបានអប់រំណែនាំរួចកម្លាំងយើងបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍។ ជាលទ្ធផល គឺអវិជ្ជមានទាំងអស់ រួចទើបអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួន ចំនួន១២នាក់ ស្រី០២នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ) ចំណែកអ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្តេនអត់ចេញ ចំនួន១២នាក់ (ស្រី០៥នាក់) ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័ក រោងចក្រម្សៅមី ស្ថិតក្នុងភូមិអូរល្វា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

## ពលករខ្មែរជាង ២០០នាក់បានវិលត្រឡប់ពីប្រទេសថៃ ចូលតាមច្រកខេត្តបាត់ដំបង នៅថ្ងៃនេះ

https://news.btv.com.kh/ 01/17/2022 12:01 PM

បាត់ដំបង៖ ពលករខ្មែរចំនួន ២៣០នាក់បានវិលត្រឡប់មកពីប្រទេសថៃចូលតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង នៅថ្ងៃទី១៧ ខែមករា ឆ្នាំ ២០២២នេះ។ ដោយអនុវត្តន៍តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវកមុខសញ្ញា មេខ្យល់នាំពលករចេញដោយមិនស្របច្បាប់ក្នុងភូមិសាស្រ្ត ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរៈ៨១៩ បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់សហការជាមួយកម្លាំងកងឃោធពលខេរភូមិន្ទ និងក្រុមគ្រូពេទ្យ បានទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ។បន្ទាប់ពីសាកសួរ កត់ឈ្មោះចុះកំណត់ហេតុនិងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩ ក្រុមគ្រូពេទ្យធ្វើតេស្តរហ័សលើពលករ ជាលទ្ធផលអវិជ្ជមានកូវីដ១៩ទាំងអស់។ ពលករចំនួន ៤៤នាក់ ស្រី២២នាក់ និងក្មេង ៥នាក់ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន។ ចំណែកពលករដែលមានកាតចាក់វ៉ាក់សាំង ចំនួន ១៨៦នាក់ ក្រុមគ្រូពេទ្យអនុញ្ញាតឱ្យត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ៕

## ជម្រះក្មេងស្រី ជាប់ចោទម្នាក់ ជាប់ពាក់ព័ន្ធបទល្មើស ជួញដូរមនុស្សឆ្លងដែន ទៅរៀបការប្ដីចិន

https://dap-news.com/national/ ByPH104Posted on January 17, 2022

**ភ្នំពេញៈ សាលាដំបូងរាជធានីភ្នំពេញ កាលពីទី១៧ ខែ មករា ឆ្នាំ ២០២២ បានបើកសវនាការ ជំនុំជម្រះកុមារីជាប់ចោទម្នាក់ ពាក់ព័ន្ធនឹងករណីជួញដូរស្ត្រីខ្មែរ ដើម្បីទៅរៀបការប្តីនៅចិន ប្រព្រឹត្តកាលពីអំឡុងឆ្នាំ ២០២០។**

លោក គី ម៉ាណោ៉ ជាប្រធានចៅក្រមប្រឹក្សាជំនុំជម្រះ សាលាដំបូងរាជធានីភ្នំពេញ បានថ្លែងអោយដឹងនៅក្នុងសវនាការថា ជនជាប់ចោទរូបនេះ មានឈ្មោះ ភស់ សុខហេង ភេទស្រី អាយុ១៦ឆ្នាំ មានទីលំនៅខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។ លោកចៅក្រមបានថ្លែងថា ជនជាប់ចោទត្រូវបានជាប់ចោទ ពីបទ«ការនាំយកចេញ ដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន»តាមមាត្រ១១នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស នឹងអំពើអាជីវកម្មផ្លូវភេទ។ ជនជាប់ចោទត្រូវបានចាប់ឃាត់ខ្លួន កាលពីថ្ងៃ ទី ២១ ខែ មីនា ឆ្នាំ ២០២១ តាមបណ្ដឹងរបស់កុមារីរងគ្រោះម្នាក់ អាយុ ១៦ ឆ្នាំ ដែលត្រូវបានជួញដូរ ទៅរៀបការប្តី នៅប្រទេសចិន កាលពីឆ្នាំ ២០២០។

នាពេលសវនាការ កាលពីព្រឹកថ្ងៃច័ន្ទកុមារីជាប់ចោទឈ្មោះ សុហេង បានឆ្លើយសារភាព នឹងទទួលស្គាល់កំហុស។ ក៏ប៉ុន្តែនាងបាននិយាយ នាងក៏ជាជនរងគ្រោះផងដែរ និង ត្រូវបានចាញ់បោក ស្ត្រីខ្មែរម្នាក់ឈ្មោះ «ចាន់» ដែលគេចខ្លួន អោយប្រព្រឹត្តបទល្មើស ខាងលើនេះ។ កុមារីជាប់ចោទ បានសំណូមពរដល់ចៅក្រមប្រឹក្សាជំនុំជម្រះនៃ សាលាដំបូងរាជធានីភ្នំពេញ មេត្តាលើកលែងបទប្រកាន់និង ដោះលែងរូបនាង ពីពន្ធនាគារ ដើម្បីបានជួបជុំនឹងឪពុកម្តាយរបស់នាងវិញ។ សាលាដំបូងរាជធានីភ្នំពេញ នឹងប្រកាសសាលក្រម សំណុំរឿងក្តីនេះ នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ ២០២២ ។ដោយ គា លីហ្សា

## ស្នេនកាតចាក់វ៉ាក់សាំងពលករត្រឡប់ពីថៃជាច្រើននាក់ គ្មានខ្លួនន័យ

https://www.kampucheathmey.com/ ថ្ងៃចន្ទ ១៧ មករា ២០២២ដោយ Dy Bunnara

ពលករខ្មែរចំនួន ៤៤ នាក់ក្នុងចំណោមពលករចំនួន ២៣០ នាក់ដែលត្រូវបានអាជ្ញាធរថៃបញ្ជូនត្រឡប់កម្ពុជាវិញតាមច្រកទ្វារតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតា សែន ស្រុកកំរៀង ខេត្តបាត់ដំបង ត្រូវបានសមត្ថកិច្ចរកឃើញថាកាតចាក់វ៉ាក់សាំងរបស់ពួកគេពេលស្កេនទៅមិនមានទិន្នន័យអ្វីទាំងអស់។

លោកវរសេនីយ៍ឯក សួន ស៊ីវ៉ា នាយការិយាល័យផ្សព្វផ្សាយអប់រំនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង បានឲ្យដឹងនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២២ នេះ ថាថ្ងៃនេះ មានពលករចំនួន ២៣០ នាក់ត្រូវបានអាជ្ញាធរថៃបញ្ជូនចាប់បញ្ជូនមកតាមច្រកទ្វារតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង ។ លោកបានបន្តទៀតថា បន្ទាប់ពីបានធ្វើការអប់រំណែនាំបន្ថែមអំពីវិធានការការពារការឆ្លងជំងឺកូវីទ១៩ រួចមក ក្រុមគ្រូពេទ្យជំនាញរបស់មន្ទីរសុខាភិបាលខេត្តបាត់ដំបង បានយកសំណាកធ្វើតេសរហ័សលើពលករទាំង ២៣០ នាក់ជាលទ្ធផលគឺអវិជ្ជមានកូវីដ១៩ ទាំងអស់។ តែក្នុងនោះមានពលករចំនួន ៤៤ នាក់រកឃើញថាមិនបានចាក់វ៉ាក់សាំងពេញលេញ និងកាតចាក់វ៉ាក់សាំងរបស់ពួកគេមានបញ្ហា នៅពេលដែលស្កេនរកមើលទិន្នន័យគឺមិនមានទិន្នន័យនោះទេ ហើយត្រូវបានបញ្ជូនសមត្ថកិច្ចបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ ៩ ស្រុកសំពៅលូន។ ចំណែកពលករដែលមានកាតចាក់វ៉ាក់សាំងពេញលេញត្រឹមត្រូវចំនួន១៨៦នាក់ ត្រូវបានក្រុមគ្រូពេទ្យអនុញ្ញាតឱ្យវិលត្រឡប់ទៅស្រុកកំណើតវិញរៀងៗខ្លួនវិញ។

គួបញ្ជាក់ថា មានពលករខ្មែរធ្វើការនៅប្រទេសថៃ ត្រូវបានអាជ្ញាធរថៃចាប់បញ្ជូនមកស្រុកកំណើតវិញតាមច្រកព្រំដែនក្នុងភូមិសាស្ត្រនៃខេត្តបាត់ដំបងជារៀងរាល់ថ្ងៃ គ្រាន់តែថ្ងៃខ្លះមានចំនួនតិច និងថ្ងៃខ្លះមានចំនួនច្រើនប៉ុណ្ណោះ។ អាជ្ញាធរស្រុក និងសមត្ថកិច្ចនៅតាមបណ្តោយព្រំដែននៃខេត្តបាត់ដំបង ក៏បានខិតខំធ្វើការទប់ស្កាត់ជំងឺកូវីដ១៩ ពិសេសការហូរចូលមេរោគបំប្លែងថ្មីអូមីក្រុង ដោយបានធ្វើការរឹតបន្តឹងដល់ការហូរចូលរបស់ពលករមកពីប្រទេសថៃលើការយកសំណាកធ្វើតេស្តរហ័ស រកមេរោគកូវីដ១៩ ពីពលករទាំងអស់មិនឱ្យមានការធ្វេសប្រហែសឡើយ៕ អត្ថបទ៖ណារី

## ថ្ងៃទី១៩ ខែ មករា ឆ្នាំ២០២២

## អាជ្ញាធរថៃចាប់បញ្ជូនពលករខ្មែរ
## រាប់រយនាក់ត្រឡប់ទៅកម្ពុជាតាមព្រំដែនខេត្តបាត់ដំបងនិងខេត្តបន្ទាយមានជ័យ

https://www.rfa.org/khmer/ ដោយ សន ចាន់រដ្ឋា2022-01-17

អាជ្ញាធរថៃចាប់បញ្ជូនពលករខ្មែរជាង៣០០នាក់ ត្រឡប់ទៅកម្ពុជាវិញតាមច្រករបៀងព្រំដែនក្នុងខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យនៅព្រឹកថ្ងៃទី១៧ ខែមករា។ ពលករអះអាងថា នៅពេលចូលមកដល់កម្ពុជា អាជ្ញាធរខ្មែរតម្រូវឱ្យពួកគាត់បង់ប្រាក់ម្នាក់ ៥០០ បាត ថ្លៃឡានដឹកពលករពីថៃមកកម្ពុជា។ អាជ្ញាធរថៃបានបញ្ជូនពលករចំនួន ២៣០ នាក់ក្នុងនោះ ៤៩ នាក់ប្រគល់ឱ្យអាជ្ញាធរកម្ពុជាតាមច្រកអូរអន្លក់ក្នុងស្រុកកំរៀង ខេត្តបាត់ដំបង នៅថ្ងៃទី១៧ ខែមករា។ ទំព័រហ្វេសប៊ុកប៉ូលិសការពារព្រំដែនវរៈ៨១៩ ប្រចាំនៅស្រុកកំរៀងចុះផ្សាយនៅថ្ងៃទី១៧ ខែមករាថា មានពលករ ១៨៦ នាក់ចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ បាន២ដូស ត្រូវបានអាជ្ញាធរអនុញ្ញាតឱ្យត្រឡប់ទៅស្រុកកំណើតវិញ ចំណែកពលករ ៤៤ នាក់ទៀត ដែលមិនបានចាក់វ៉ាក់សាំង គឺអាជ្ញាធរបានបញ្ជូនទៅធ្វើចត្តាឡីស័កនៅគីឡូលេខ ៩ ស្រុកសំពៅលូន។

ចំណែកនៅខេត្តបន្ទាយមានជ័យឯណោះវិញ អាជ្ញាធរថៃក៏បានបញ្ជូនពលករខ្មែរចំនួន ៩៤ នាក់ត្រឡប់ទៅកម្ពុជាតាមច្រករបៀងព្រំដែនអូរបីជាន់ ស្រុកអូរជ្រៅដែរ។ ស្នងការរងនគរបាលខេត្តបន្ទាយមានជ័យទទួលបន្ទុក

ការពារព្រំដែនលោក អ៊ុំ សុផល ប្រាប់វិទ្យុអាស៊ីសេរីថា ពលករទាំងនោះឆ្លងដែនទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ ហើយត្រូវបានប៉ូលិសថៃចាប់ខ្លួននៅតំបន់ទីក្រុងបាងកកនិងនៅខេត្តជាប់ព្រំដែនកម្ពុជា។ លោកបញ្ជាក់ថា ក្នុងចំណោមពលករជាង ៩០ នាក់នោះ ពលករមួយចំនួនត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័កនៅក្រុងប៉ោយប៉ែត និងមួយចំនួនទៀត ដែលចាក់វ៉ាក់សាំងបាន២ដូសរួច ត្រូវបានអនុញ្ញាតឱ្យពួកគាត់ត្រឡប់ទៅស្រុកកំណើតវិញនៅព្រឹកថ្ងៃដដែល៖ «ខ្ញុំបានទទួលពលករមកហើយខ្ញុំបានបញ្ជូនទៅអាជ្ញាធរហើយចប់ហើយ។ បាទអត់មាន ឱ្យគាត់ធ្វើកិច្ចសន្យាឈប់ឱ្យឆ្លងដែនខុសច្បាប់ទៀត កុំឱ្យគាត់ចាញ់បោកមេខ្យល់។ ពួកគាត់ខ្វះការងារធ្វើក្នុងស្រុក តែប្រជាពលរដ្ឋយើងពិបាកដែរគាត់ចេះតែឆ្លងដែនទៅអីចឹង»។

ជាមួយគ្នានេះ អ្នករត់តាក់ស៊ី (Taxi) ដឹកពលករនៅតំបន់ព្រំដែនជាប់ប្រទេសថៃម្នាក់សុំមិនបញ្ចេញឈ្មោះឱ្យដឹងថា ពលករមួយចំនួនបានត្អូញត្អែរទាំងក្នុងពេលធ្វើដំណើរនៅលើឡានរបស់លោកថា នៅពេលមកដល់កម្ពុជាអាជ្ញាធរខ្មែរបានយកប្រាក់ពីពួកគាត់ម្នាក់ ៥០០ បាត ឬ ប្រមាណ ១៦ ដុល្លារ ក្រោមលេសថា យកបង់ថ្លៃឡានរបស់សមត្ថកិច្ចថៃដែលបានដឹកពួកគេមកដល់កម្ពុជា។ លើសពីទៅទៀតនេះ អាជ្ញាធរខ្មែរបង្ខំឱ្យពួកគេទិញទឹកអាល់កុលលាងដៃម្នាក់មួយ១ដបតូច តម្លៃ១០០បាតឬ ប្រមាណ ៣ ដុល្លារ ដោយខុសពីទីផ្សារក្នុងស្រុកដែលមានតម្លៃត្រឹមតែ ២ពាន់រៀល ប៉ុណ្ណោះ៖ «បើអ្នកណាទៅយកបងប្អូនអីចឹងគេអត់ទាន់ឱ្យចេញទេ អង្គុយចាំស្ពែន ទាល់តែឡានដាក់វេនអីចេញអស់បានឱ្យឡានបងប្អូនដឹកពលករចេញបាន។ ខាងឡានគេរាប់មនុស្សម្នាក់យក៥ពាន់រៀល ប៉ុន្តែអ្នករត់តាក់ស៊ីអ្នកចេញទេ។ ខ្ញុំអាណិតអាសូរដូចថា វាមើលទៅស្រងេះស្រងោចណាស់ ដូចយើងខ្មែរដូចគ្នាមិនគួរធ្វើបាបគ្នាទេ»។ ទាក់ទងនឹងបញ្ហានេះ ស្នងការរងនគរបាលខេត្តបន្ទាយមានជ័យលោក អ៊ុំ សុផល ថ្លែងថា លោកមិនបានពាក់ព័ន្ធនឹងការយកប្រាក់និងលក់ទំនិញឱ្យពលករថ្លៃខុសពីទីផ្សារនោះឡើយ។

ជុំវិញរឿងនេះ មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) ខេត្តបន្ទាយមានជ័យលោក ស៊ុំ ចន្ទគា យល់ថា ការដែលអាជ្ញាធរធ្វើបែបនេះជាការជំរិតធ្វើបាបពលរដ្ឋក្រីក្រ ដែលកំពុងលំបាកវេទនា។ មន្ត្រីសង្គមស៊ីវិលរូបនេះស្នើឱ្យរដ្ឋាភិបាលចាត់វិធានការ ទៅលើមន្ត្រីខិលខូចទាំងនោះឱ្យបានធ្ងន់ធ្ងរតាមច្បាប់ ដើម្បីកុំឱ្យពួកគេចេះតែឆ្លៀតឱកាសកេងចំណេញលើគំនរទុក្ខរបស់ពលរដ្ឋបន្តទៀត៖ «ម្តងមុនគឺមានការបញ្ជូនហើយឱ្យដេកនៅនៀលក្រាញនៅតាមព្រំដែន ដើម្បីធ្វើចត្តាឡីស័ក។ ប៉ុន្តែម្តងនេះយើងគិតថា កុំឱ្យធ្វើទៅតាមអារម្មណ៍ម្តងម្កាលអីចឹង គួរតែរៀបចំគណៈកម្មការ ដើម្បីពិនិត្យមើលថា បើបញ្ជូនត្រឡប់មកស្រុកវិញថា តើពួកគាត់មានរោគឬអត់? តើត្រូវជួយពួកគាត់នៅកន្លែងណាអីកន្លែងណា ឱ្យសមរម្យដើម្បីកុំឱ្យអស់លុយអស់កាក់អីចឹង។ គាត់នៅក្នុងស្រុកអត់មានលុយកាក់ហើយត្រូវបានគេចាប់បញ្ជូនហើយ បែរទៅគិតលុយពីគាត់ទៀតអាហ្នឹងវា ជាទម្ងន់មួយទុក្ខត្រួតលើទុក្ខដល់ពលករហើយ»។ អាជ្ញាធរកម្ពុជានិងថៃ បានបិទច្រកទ្វារព្រំដែនដែនប្រទេសទាំងពីរចាប់តាំងពីខែមីនា ឆ្នាំ២០២០ ដើម្បីទប់ស្កាត់ការរាលដាលជំងឺកូវីដ-១៩ រហូតមកដល់ពេលនេះមិនទាន់បើកដំណើរការវិញនៅឡើយទេ។

កាលពីថ្ងៃទី២០ ខែធ្នូ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស ខេង បានប្រកាសថា ចាប់តាំងពីអាជ្ញាធរថៃបិទច្រកទ្វារព្រំដែនមកដល់ថ្ងៃទី១៩ ខែធ្នូ មានពលករខ្មែរប្រមាណ ២សែន ៦ម៉ឺននាក់ (២៦០.០០០) ត្រូវបានអាជ្ញាធរថៃចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ។ ក្នុងនោះមានពលករមួយចំនួនបានត្រឡប់ទៅធ្វើការនៅប្រទេសថៃវិញជាបន្តបន្ទាប់។ ក្នុងនោះពលករភាគច្រើនឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់តាមច្រករបៀងព្រំដែនក្នុងខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ៕

## ពលរដ្ឋខ្មែរជាង ៣៦៥.០០០ នាក់នៅប្រទេសថៃ បានចាក់វ៉ាក់សាំងប្រឆាំងជំងឺកូវីដ-១៩

https://www.khmertimeskh.com/ ខ្មែរថាមស៍ January 18, 2022

ប្រទេសថៃបានចាក់វ៉ាក់សាំងកូវីដ-១៩ ចំនួន ៣,៩០០,៩៩៥ ដូស ដល់ជនបរទេសដែលរស់នៅទីនោះ ចន្លោះថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ថ្ងៃទី ៦ ខែមករា ឆ្នាំ ២០២២។ ក្រាហ្វព័ត៌មានដែលទទួលបានដោយខ្មែរថាមស៍ បង្ហាញពីអ្នកដែលបានចាក់វ៉ាក់សាំងសំខាន់ៗចំនួន ១០ប្រទេស តាមសញ្ជាតិដែលកំពុងរស់នៅប្រទេសថៃ។

ប្រជាជនកម្ពុជានៅក្នុងប្រទេសថៃ ជាប្រទេសជិតខាងដែលមានចំនួនពលករចំណាកស្រុកច្រើនជាងគេទីពីរ ក្នុងបញ្ជីជនបរទេសដែលទទួលបានវ៉ាក់សាំងកូវីដ-១៩ នៅទីនោះ។ ប្រជាជនកម្ពុជាសរុបចំនួន ៣៦៥,៧៧៧ នាក់ ស្មើនឹង១៧,៨% បានចាក់វ៉ាក់សាំងនៅក្នុងប្រទេសថៃ។ ជនជាតិមីយ៉ាន់ម៉ាគឺជាអ្នកដែលបានចាក់វ៉ាក់សាំងច្រើនជាងគេ សរុបចំនួន ១,២៣៤,៨៦៣ នាក់ ស្មើនឹង ៦០.៤៣% ។ តាមពីក្រោយប្រទេសកម្ពុជា ប្រទេសឡាវមានប្រជាជន១៨២.៤១៥នាក់ឬ៩.៩៣% ចិនមាន៥៣.៧៦០នាក់ឬ២.៦៣% ជប៉ុនមាន២៤.៩២៥នាក់ឬ ១.២២% ក្រិចមាន២២.៤៨២នាក់ឬ១.១% ឥណ្ឌាមាន១៨.៨៥៧នាក់ឬ0.៩១៨% ហ្វីលីពីន២៨% ចក្រភពអង់គ្លេស មានប្រជាជន ១៧.៦៨៩ នាក់ ឬ 0.៨៧% និងសហរដ្ឋអាមេរិក មាន ១១.៦៦៧ នាក់ ឬ 0.៥៧% ។ ជនបរទេសសរុបចំនួន ២,០១១,២៨៩ នាក់ដែលរស់នៅក្នុងប្រទេសថៃបានទទួលវ៉ាក់សាំងជាលើកដំបូងចាប់តាំងពីខែកុម្ភៈឆ្នាំ ២០២១។

## អាជ្ញាធរស្រុកសំពៅលូន បន្តទទួល
## ប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ

https://gdlf-kh.com/ 17/01/2022 Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃចន្ទ ១៥កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹង ថ្ងៃទី១៧ ខែមករា ឆ្នាំ ២០២២ ដោយអនុវត្តន៍តាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន ០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក មុឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន ចំនួន០២នាក់ ដឹកនាំដោយលោកនាយចំណង់ ជា យ៉ាន (មេបញ្ជាការរងអនុសេនាតូច) កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០២នាក់ ដឹកនាំ ដោយលោកអនុសេនីយ៍ឯក ឯក-អាំផន (មេបញ្ជាការរងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង សរុបចំនួន០៤នាក់ ស្រី០២នាក់។

ក្រោយពីទទួល កម្លាំងយើងបានកត់ឈ្មោះ ចុះកំណត់ និងសុំបងប្អូនសហការជាមួយកម្លាំងយើងដើម្បីពិនិត្យសម្ភារៈហាមឃាត់ និងបានអប់រំណែនាំរួចកម្លាំងយើងបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូន ធ្វើតេស្ត និងពិនិត្យសុខភាពនៅនឹងប៉ុស្តិ៍។ ជាលទ្ធផល គឺអវិជ្ជមានទាំងអស់ ទេីប បានឱ្យត្រឡប់ទៅមូលដ្ឋានវិញចំនួន០២នាក់ (ប្រុសម្នាក់, ស្រីម្នាក់) នឹងចំនួន០២នាក់ (ប្រុសម្នាក់, ស្រីម្នាក់) បានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័ក រោងចក្រម្សៅមី ស្ថិតក្នុងភូមិអូរល្ហា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

## អាជ្ញាធរថៃប្រគល់ពលករខ្មែរ
## ២៥៨ នាក់ឱ្យអាជ្ញាធរកម្ពុជា ដោយសារពួកគេមិនបានចាក់វ៉ាក់សាំងបង្ការកូវីដគ្រប់ចំនួន

https://www.postkhmer.com/ គឹម សារុំ | Publication date 18 January 2022 | 10:42 ICT

**បាត់ដំបង:** ពលករចំនួន ២៥៨ នាក់ ត្រូវបានអាជ្ញាធរថៃប្រគល់ឱ្យនគរបាលព្រំដែនស្រុកសំពៅលូន និងស្រុកកំរៀង ខេត្តបាត់ដំបង នាថ្ងៃទី ១៦-១៧ មករា ក្នុងនោះពលករចំនួន ៥៤ នាក់ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័ក ដោយសារពួកគេមិនបានចាក់វ៉ាក់សាំងការពារជំងឺកូវីដ ១៩។

លោក វេ គឹមចត់ អធិការនគរបាលស្រុកកំរៀងឱ្យដឹងថា នៅថ្ងៃទី ១៧ មករា ពលករចំនួន ២៣០ នាក់ (ស្រី ២២ នាក់ ក្នុងនោះ ក្មេង ៥ នាក់) ត្រូវបានអាជ្ញាធរនៃប្រទេសថៃប្រគល់មកបញ្ជាការដ្ឋានវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៩។ ពលករទាំងនោះមួយចំនួនមានបណ្ណចាក់វ៉ាក់សាំងពីប្រទេសថៃ និងមួយចំនួនទៀតគ្មានបណ្ណចាក់វ៉ាក់សាំងទេ ដែលបញ្ជូនមកតាមច្រកអូរអន្លក់ ក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង។ លោកបន្តថា ចំពោះអ្នកដែលគ្មានបណ្ណចាក់វ៉ាក់សាំង ឬមិនទាន់បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ ១៩ ពីប្រទេសថៃនឹងត្រូវបញ្ជូនទៅមណ្ឌលចត្តាឡីស័ក ដើម្បីធ្វើការចាក់វ៉ាក់សាំងការពារជំងឺកូវីដ ១៩។ ការងារទទួលពលករ នេះជាសមត្ថកិច្ចរបស់នគរបាលជួរមុខវរសេនាតូចលេខ ៨១៩។

លោកប្រាប់ថា៖ «ជាគោលការណ៍ ពលករមកពីប្រទេសថៃ ហើយគាត់បានចាក់វ៉ាក់សាំងរួចចំនួន ២ ដង គឺគ្រូពេទ្យនឹងអនុញ្ញាតឱ្យគាត់ត្រឡប់ទៅស្រុកកំណើតវិញបាន។ តែបើពលករទើបចាក់វ៉ាក់សាំងបានតែម្ដងក៏តម្រូវឱ្យគាត់ ធ្វើចត្តាឡីស័ក និងចាក់វ៉ាក់សាំងបន្ថែមទៀតដែរ ទើបអនុញ្ញាតឱ្យគាត់ត្រឡប់ទៅផ្ទះវិញបាន»។ លោកថា ពលករចំនួន ៤៤ នាក់ ក្នុងចំណោម ២៣០ នាក់ ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ ៩ ស្រុកសំពៅលូន។ ចំណែកពលករដែលមានកាតចាក់វ៉ាក់សាំង ចំនួន ១៨៦ នាក់ ក្រុមគ្រូពេទ្យបានអនុញ្ញាតឱ្យត្រឡប់ទៅស្រុកកំណើតវិញ។ ការប្រគល់ជូនភាគីកម្ពុជានេះ គឺតាមរយៈលោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរលេខ ៨១៩ សហការជាមួយកម្លាំងប៉ុស្ដិ៍អូរអន្លក់ និងក្រុមគ្រូពេទ្យ។

លោក ទឹម រិធ៍យ អធិការនគរបាលស្រុកសំពៅលូនឱ្យដឹងថា ការទទួលពលករពីប្រទេសថៃ ជាកិច្ចការរបស់នគរបាលការពារព្រំដែនវរសេនាតូចលេខ ៨១៧។ ប៉ុន្តែក្រោយនគរបាលព្រំដែនបំពេញការងាររបស់គាត់រួច ទើបបញ្ជូនរបាយការណ៍ទៅតាមជំនាញដែលស្រុករបស់លោកក៏ទទួលបានដែរ។ មន្ត្រីនគរបាលស្រុកសំពៅលូនប្រាប់ដោយមិនឱ្យបញ្ចេញឈ្មោះថា កាលពីថ្ងៃទី ១៦ មករា ភាគីថៃ បានបញ្ជូនពលករចំនួន ២៨ នាក់ (ស្រី ១៧ នាក់) នៅភូមិពោធិជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង។ ក្នុងនោះមាន ១០ នាក់ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័ក និងចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ ១៩៕

## តុលាការឧទ្ធរណ៍ តម្កល់ទោស ជនជាតិអាមេរិកាំងម្នាក់ ជាប់គុក ៨ ឆ្នាំ ជាប់ពាក់ព័ន្ធបទល្មើស ការទិញពេស្យាចារកុមារខ្មែរ និង ផលិត រូបភាព និងសម្ភារៈអាសអាភាស នៅកម្ពុជា

https://dap-news.com/national/ BySS107Posted on January 18, 2022

ភ្នំពេញ: សាលាឧទ្ធរណ៍រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២២នេះ បានប្រកាសសាលក្រម លើបណ្ដឹងឧទ្ធរណ៍ របស់បុរសជាប់ចោទជនជាតិអាមេរិកម្នាក់ ជាប់ពន្ធនាគារ ៨ ឆ្នាំ ។ ជាប់ពាក់ព័ន្ធនឹងការរួមភេទជាមួយមួយកុមារខ្មែរ ជាច្រើននាក់ និង ថតស្រាត និង រូបអាសអាភាសរបស់ពួកគេ ដើម្បីចែកចាយ ប្រព្រឹត្តនៅ ខេត្តសៀមរាប នៅក្នុងឆ្នាំ២០១៩ ។

លោក គូ ពៅស៊ុន ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះសាលាឧទ្ធរណ៍រាជធានីភ្នំពេញ បានថ្លែងអោយដឹងថា ជនជាប់ចោទរូបនេះ មានឈ្មោះ REIDY JOHN PATRICK ភេទប្រុស អាយុ ៥៨ ឆ្នាំ ជនជាតិអាមេរិក មុខរបរមុនចាប់

ខ្លួន ជា អ្នកមើលថែសួន រស់នៅខេត្តសៀមរាប។ លោកចៅក្រមបានបញ្ជាក់ថា នៅក្នុងសំណុំរឿងក្តីនេះ ជនជាប់ចោទជនជាតិអាមេរិក ត្រូវបានសាលាដំបូងខេត្តសៀមរាប កាលពីថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០២០ កាត់ទោស ដាក់ពន្ធនាគារ កំណត់ ៨ ឆ្នាំ និង ពិន័យជាប្រាក់ ចំនួន ៨លានរៀល ដាក់ចូលក្នុងថវិកាជាតិ និង បង្គាប់ឱ្យគាត់ ត្រូវសងជំងឺចិត្តចំនួន ២០លានរៀល ទៅកុមារកម្ពុជាម្នាក់ ដែលជា ជនរងគ្រោះ។

ជនជាប់ចោទឈ្មោះ Eidy Jonh Patrick ត្រូវបានជាប់ចោទពីបទៈ ការទិញពេស្យាចារកុមារ និង ការផលិតរូបភាពនិងសម្ភារៈអាសអាភាសកុមារ តាមមាត្រា ៣៤ មាត្រា ៤១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើអាជីវកម្មផ្លូវភេទ។ តែគាត់បានប្តឹងឧទ្ធរណ៍ ។ ជនជាប់ចោទ ឈ្មោះ REIDYJOHNPATRICK ត្រូវបានចាប់ឃាត់ខ្លួន កាលពីថ្ងៃទី១៩ ខែ កក្កដា ឆ្នាំ ២០១៩ នៅសង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្ត សៀមរាប យោងតាមបណ្តឹងរបស់ អាណាព្យាបាលរបស់កុមាររងគ្រោះ ម្នាក់ ព្រមទាំងមានការ ចូលរួម អំពី មន្ត្រីជំនាញ នៃ អង្គការ APLE Cambodia៕ ដោយ គា លីហ្សា

## ថ្ងៃទី២០ ខែ មករា ឆ្នាំ២០២២

## ជម្រះបណ្តឹងឧទ្ធរណ៍ស្ត្រី
## ជាប់ចោទម្នាក់ ជាប់ពាក់ព័ន្ធនឹងការជួញដូរ ស្ត្រីខ្មែរ៧នាក់ ទៅលក់ដូរ នៅប្រទេសម៉ាឡេស៊ី

https://dap-news.com/national/ BySS107Posted on January 18, 2022

ភ្នំពេញ: សាលាឧទ្ធរណ៍ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២២នេះ បានបើកសវនាការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ ស្ត្រីជាប់ចោទម្នាក់ ដែលតុលាការថ្នាក់ក្រោម កាត់ទោស ដាក់ពន្ធធនាគារ កំណត់ ១៦ ឆ្នាំ ជាប់ពាក់ព័ន្ធនឹងការជួញដូរ ស្ត្រីខ្មែររងគ្រោះ ចំនួន៧នាក់ ទៅធ្វើការនៅប្រទេសម៉ាឡេស៊ី តែក្រោយមក ស្ត្រីរងគ្រោះ ទាំងនោះ ត្រូវបានគេលក់ដូរ និង គេងប្រវ័ញ្ចការងារ នៅទីនោះ ប្រព្រឹត្ត កាលពីអំឡុង ២០១៦។

លោក កូ ពៅស៊ុន ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះសាលាឧទ្ធរណ៍រាជធានី ភ្នំពេញ បានថ្លែងអោយដឹងក្នុងអង្គសវនាការថា ជនជាប់ចោទរូបនេះ ឈ្មោះ អ៊ុំ ប៉ាឌីន ភេទស្រី អាយុ ៣៥ ឆ្នាំ ។ ជនជាប់ចោទឈ្មោះ អ៊ុំ ប៉ាឌីន ត្រូវបានសាលាដំបូងខេត្តរាជធានីភ្នំពេញ កាលពីថ្ងៃទី ឆ្នាំ ២០១៨ កាត់ទោស ដាក់ពន្ធនាគារ កំណត់ ១៦ ឆ្នាំ ពីបទ:« ការនាំយកចេញ ដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន» តាមមាត្រា១១ នៃ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ។ តែនាងបាន ឧទ្ធរណ៍ ។ ជនជាប់ចោទ ឈ្មោះ អ៊ុំ ប៉ាឌីន ត្រូវចាប់ឃាត់ខ្លួន កាលពីថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៧ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ។ សាលាឧទ្ធរណ៍រាជធានីភ្នំពេញនឹងប្រកាសសាលដីកា លើសំណុំរឿងក្តីនេះ នៅព្រឹកថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០២២៕ដោយ គា លីហ្សា

## អាជ្ញាធរស្រុកសំពៅលូន ទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ និងប្រគល់ទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣

https://gdlf-kh.com/ 2022/01/18/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង០៥និង០០នាទី នាថ្ងៃអង្គារ ១រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ ដោយអនុវត្តន៍តាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គីមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ម៉ឹង-ម៉េត (នាយប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូន ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី កៅ-ប៊ុណ្ណា (មេបញ្ជាការរងកងអនុសេនាធំ), a កម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ផុក-លឹមឃី (មេបញ្ជាការរងកងអនុសេនាធំ) កម្លាំងនគរបាលអន្តោប្រវេសន៍ប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣ ចំនួន០២នាក់ ដឹកនាំដោយលោកវរសេនីយ៍ត្រី ហ៊ាន-ហាន (នាយរងផ្នែក) បានទទួលប្រជាពលរដ្ឋវិលត្រឡប់ចូលមកប្រទេសកម្ពុជាត្រង់ចំណុចភូមិសាស្ត្រ ភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០៤នាក់ (ស្រី០២នាក់ ក្មេងស្រី០១នាក់)។ ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើការកត់ឈ្មោះ ចុះកំណត់ហេតុ អប់រំណែនាំរួចបានប្រគល់បងប្អូនទាំងអស់ឱ្យទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣។

## ពលរដ្ឋខ្មែរ ជាង២០០នាក់ ត្រូវបានអាជ្ញាធរថៃបញ្ជូនមកវិញ តាមច្រកតំបន់អូរអន្លក់ ក្នុងស្រុកកំរៀង

https://dap-news.com/national/ ByTR110Posted on January 19, 2022

**ភ្នំពេញ ៖** ក្រុមអាជ្ញាធរថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន២៣៨នាក់ត្រឡប់មកវិញ តាមច្រកតំបន់អូរអន្លក់ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ក្នុងស្រុកកំរៀង ខេត្តបាត់ដំបង នៅព្រឹកថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២។ មូលហេតុនៃការបញ្ជូនមកវិញនេះ មិនទាន់ដឹងថា មកពីកត្តាអ្វីច្បាស់លាស់នោះទេ។ បើតាមការផ្សព្វផ្សាយពីផេករបស់អគ្គស្នងការដ្ឋាននគរបាលជាតិ គឺក្រុមមន្ត្រីជាន់ខ្ពស់របស់ខេត្តបាត់ដំបង និងមន្ត្រីព្រំដែនបានទៅទទួលពលរដ្ឋខ្មែរទាំងនោះនៅចំណុចច្រកតំបន់អូរអន្លក់។ បន្ទាប់ពីសាកសួរ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩ រួចមកពលរដ្ឋខ្មែរទាំង២៣៨នាក់ ក្នុងនោះមានក្មេង៣៧នាក់ ត្រូវកងកម្លាំង រួមទាំងក្រុមគ្រូពេទ្យបានធ្វើតេស្តរហ័សដោយលទ្ធផលបង្ហាញថា មានកូវីដ១៩ម្នាក់ ហើយបញ្ជូនទៅព្យាបាលនៅមណ្ឌលត្រារដូ ស្រុកសំពៅលូន។ ចំណែក ពលករចំនួន៤៣នាក់ទៀត បានបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន។ ដោយឡែក ពលករមានកាតចាក់វ៉ាក់សាំងចំនួន១៩៥នាក់ ព្រមទាំងបានចាក់វ៉ាក់សាំងក្មេងចាប់ពីអាយុ៥ឆ្នាំដល់១៨ឆ្នាំចំនួន១៥នាក់ ក្រុមគ្រូពេទ្យក៏អនុញ្ញាតឲ្យត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ ៕

# ថ្ងៃទី២១ ខែ មករា ឆ្នាំ២០២២

## ឧទ្ធរណ៍ជំនុំជម្រះសំណុំរឿងស្ត្រីម្នាក់ បម្រុងនាំនារីក្មេងៗទៅម៉ាឡេស៊ី

https://www.postkhmer.com/ គឹម សារុំ | Publication date 19 January 2022 | 10:59 ICT

**ភ្នំពេញៈ** សាលាឧទ្ធរណ៍នៅថ្ងៃទី ១៨ មករាបានលើកបណ្ដឹងឧទ្ធរណ៍របស់ស្ត្រីជាប់ចោទម្នាក់ក្នុងចំណោម ៣ នាក់មកជំនុំជម្រះ បន្ទាប់ពីស្ត្រីរូបនេះមិនសុខចិត្តនឹងតុលាការថ្នាក់ក្រោម ដែលផ្តន្ទាទោសដាក់ពន្ធនាគារ ១៦ ឆ្នាំពាក់ព័ន្ធករណីបម្រុងនាំនារីៗអាយុចន្លោះពី ១៦ ដល់ ១៩ ឆ្នាំ ចំនួន ៧ នាក់ទៅធ្វើការនៅប្រទេសម៉ាឡេស៊ីកាលពីឆ្នាំ ២០១៦ នៅរាជធានីភ្នំពេញ។

លោកចៅក្រម ភូ ពៅស៊ុន ប្រធានក្រុមប្រឹក្សាជំនុំជម្រះក្នុងសមាសភាពលោកចៅក្រម ៣ រូប បានអានអង្គហេតុនៅចំពោះមុខជនជាប់ចោទ និងមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទក្នុងបន្ទប់សវនាការនៅថ្ងៃទី ១៨ មករាថា ក្នុងសំណុំរឿងនេះ មានជនជាប់ចោទ ៣ នាក់ តែស្ត្រីជាប់ចោទ ឈ្មោះ អ៊ុំ រ៉ាដែន អាយុ ៣៥ ឆ្នាំ ប្តឹងឧទ្ធរណ៍តែម្នាក់គាត់ទេ។ តាមអង្គហេតុរបស់សាលាឧទ្ធរណ៍ភ្នំពេញបង្ហាញថា កាលពីដើមខែមិថុនា ឆ្នាំ ២០១៦ ស្ត្រីឈ្មោះ ចាន់ សុឃីម បានលួងលោមនារីក្មេងៗចំនួន ៧ នាក់ ដែលរស់នៅក្នុងឃុំផាត់សណ្ដាយ ខេត្តកំពង់ធំ ដោយប្រាប់ពួកនាងថា មានគេរើសស្ត្រីខ្មែរទៅធ្វើការនៅប្រទេសសាំងហ្គាពួរបានប្រាក់ខែច្រើន។ ក្រោយពីលួងលោមបានសម្រេចហើយនៅថ្ងៃទី ១៤ មិថុនា ឆ្នាំ ២០១៦ ស្ត្រីឈ្មោះ ចាន់ សុឃីម បាននាំនារីទាំង ៧ នាក់មកស្នាក់នៅបណ្ដោះអាសន្ននៅផ្ទះរបស់ស្ត្រីជាប់ចោទឈ្មោះ អ៊ុំ រ៉ាដា នៅក្នុងសង្កាត់-ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ ពេលពួកនារីទាំង ៧ នាក់កំពុងស្នាក់នៅរាជធានីភ្នំពេញនោះ ស្ត្រីជាប់ចោទ អ៊ុំ រ៉ាដា បាននិយាយប្រាប់នារីទាំង ៧នាក់នោះថា ពួកនាងមិនត្រូវបានយកទៅធ្វើការនៅប្រទេសសាំងហ្គាពួរទេ តែយកទៅប្រទេសម៉ាឡេស៊ីវិញ។

អំឡុងពេលនោះដែរស្ត្រីឈ្មោះ សំ យ៉ុង ដែលជាបក្ខពួករបស់ស្ត្រីឈ្មោះ អ៊ុំ រ៉ាដា បានទៅរត់ការដោយនិយាយភូតកុហកអាជ្ញាធរសង្កាត់ចោមចៅឱ្យកែសម្រួលឈ្មោះ អាយុនារីៗទាំងនោះ ដើម្បីបានទៅធ្វើលិខិតឆ្លងដែនស្របច្បាប់។ ប៉ុន្តែរឿងនេះ ត្រូវបែកការណ៍ ព្រោះត្រូវបានអាជ្ញាធរសង្កាត់ចោមចៅប្តឹងនគរបាលនៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ហើយបានឃាត់ខ្លួនជនល្មើសទាំង ៣ នាក់ និងបានរំដោះនារីទាំង ៧ នាក់នៅថ្ងៃទី ១៣ កក្កដា ឆ្នាំ ២០១៦។ សំណុំរឿងនេះត្រូវបានសាលាដំបូងរាជធានីភ្នំពេញ បើកសវនាការ និងប្រកាសសាលក្រមនៅថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១៩ សម្រេចផ្តន្ទាទោស ស្ត្រីឈ្មោះ អ៊ុំ រ៉ាដា និងឈ្មោះ ចាន់ សុឃីម ដាក់ពន្ធនាគារម្នាក់ ១៦ ឆ្នាំ ចោទពីបទនាំចេញដោយមិនស្របច្បាប់ សម្រាប់នាំឆ្លងដែនតាមមាត្រា ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ចំពោះឈ្មោះ សំ យ៉ុង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ១ ឆ្នាំចោទពីបទផ្តល់ឯកសារក្លែង។ ដោយមិនសុខចិត្តនឹងសាលក្រមខាងលើស្ត្រីជាប់ចោទឈ្មោះ អ៊ុំ រ៉ាដា បានប្តឹងមកសាលាឧទ្ធរណ៍ភ្នំពេញបន្តទៀត។

ស្ត្រីជាប់ចោទ អ៊ុំ រ៉ាដា បាននិយាយប្រាប់ចៅក្រមក្នុងអង្គសវនាការនៅថ្ងៃទី ១៨ មករា ថា គាត់ប្តឹងឧទ្ធរណ៍ពេលនេះមិនមែនជំទាស់ទៅនឹងទង្វើរបស់ខ្លួនទេ តែជំទាស់នឹងទណ្ឌកម្មទោសច្រើនឆ្នាំពេក។ ម្យ៉ាងគាត់ក៏មានបញ្ហាគ្មានអ្នកថែទាំចិញ្ចឹមកូន ៣ នាក់ ដោយសារគ្មានអ្នកមើលថែ។ ស្ត្រីជាប់ចោទថាៈ «ខ្ញុំសូមតុលាការបន្ថយទោសខ្ញុំផង ដើម្បីឆាប់បានចេញទៅមើលថែកូនៗ ដែលទើបមានអាយុ ១៣ ឆ្នាំ អាយុ ១២ ឆ្នាំ និងអាយុ ៧ ឆ្នាំ។ ពីមុនពួកគេមានឪពុកខ្ញុំមើលថែ ឥឡូវគាត់ត្រូវស្លាប់ដោយជំងឺកូវីដបាន ៣ ខែមកហើយ»។

លោក អ៊ឹម សុផាន តំណាងមហាអយ្យការសន្និដ្ឋានក្នុងអង្គសវនាការនៅថ្ងៃទី ១៨ មករាថា ជនជាប់ចោទបានសារភាពពីការប្រព្រឹត្តរបស់ខ្លួន ហើយត្រូវបានតុលាការថ្នាក់ក្រោមផ្តន្ទាទោស ១៦ ឆ្នាំ។ អំពើរបស់ស្ត្រីជាប់ចោទបើតាមច្បាប់ត្រូវផ្តន្ទាទោសពី ១៥ ឆ្នាំទៅ ២០ ឆ្នាំ ករណីជនរងគ្រោះជាអនីតិជន។ លោកថាៈ «ការដែល

តុលាការថ្នាក់ក្រោមផ្តន្ទាទោស ១៦ ឆ្នាំដល់ស្ត្រីជាប់ចោទគឺត្រឹមត្រូវតាមលក្ខណៈច្បាប់ហើយ ប៉ុន្តែជនជាប់ចោទគួរទទួលបានការសម្រាលទោសខ្លះ ព្រោះបទល្មើសនៅមិនទាន់សម្រេច»។

លោក ឡាយ ឡុងឌី ជាមេធាវីការពារក្តីឱ្យស្ត្រីជាប់ចោទ អ៊ុំ រ៉ាដា បានធ្វើសេចក្តីសន្និដ្ឋានថា លោកឯកភាពចំពោះការសន្និដ្ឋានរបស់តំណាងមហាអយ្យការ។ «កូនក្តីរបស់ខ្ញុំនៅគ្រប់ដំណាក់កាលគឺគាត់បានសារភាពរហូតមក។ ហេតុដូច្នេះ ខ្ញុំសូមតុលាការមេត្តាបន្ថយទោសដល់គាត់ផង»។ ក្រោយប្រើពេលជំនុំជម្រះជិត ១ ម៉ោងមក លោកចៅក្រម ភូ ពៅស៊ុន បានថ្លែងថា សាលដីកានេះនឹងត្រូវប្រកាសនៅថ្ងៃទី ២៨ មករា៕

## កម្លាំងនគរបាល
## ទទួលពលរដ្ឋចូលកម្ពុជា០៩នាក់ ខណៈ៧នាក់ធ្វើចត្តាឡីស័ក និង២នាក់ឲ្យត្រឡប់ទៅផ្ទះ

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ ២០ ខែ មករា ឆ្នាំ ២០២២ ម៉ោង ១៥:១៥

ខេត្តបាត់ដំបង ៖ កម្លាំងនគរបាលសហការជាមួយកម្លាំងយោធាបាន ទទួលប្រជាពលរដ្ឋត្រឡប់ចូលប្រទេសកម្ពុជាវិញ ចំនួន០៩នាក់ នៅស្រុកសំពៅលូន ខេត្តបាត់ដំបង នៅវេលាម៉ោង១៩និង០០នាទីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២ ដោយពលរដ្ឋមួយចំនួនត្រូវបានក្រុមគ្រូពេទ្យអនុញ្ញាតឲ្យត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួនវិញ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ) ចំណែកអ្នកមានប័ណ្ណចាក់វ៉ាក់សាំង តែស្តេនអត់ចេញ ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័ក ។ នេះបើយោងតាមផេក អគ្គស្នងការដ្ឋាននគរបាលជាតិបានផ្សាយនាថ្ងៃទី២០ ខែមករានេះ ។ ដោយអនុវត្តន៍តាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប់ជាប្រចាំ តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញចូលខុសច្បាប់ តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ។ ក្រោមការបញ្ជាផ្ទាល់ របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក លេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍គីឡូ១៣ ចំនួន០២នាក់ សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន០២នាក់ និងកម្លាំងយោធាវរសេនាតូច៥៣៣ ចំនួន០២នាក់ បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ត្រង់ភូមិសាស្ត្រ ភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង សរុបចំនួន០៩នាក់ (ស្រី០២នាក់) ។

ក្រោយពីទទួលកម្លាំងសមត្ថកិច្ចបានកត់ឈ្មោះ និងសុំបងប្អូនសហការ ដើម្បីពិនិត្យសម្ភារៈហាមឃាត់ និងបានអប់រំណែនាំ រួចសមត្ថកិច្ចបានប្រគល់បងប្អូនទាំងអស់ឲ្យទៅក្រុមគ្រូពេទ្យនៃមន្ទីរពេទ្យបង្អែកស្រុកសំពៅលូនធ្វើតេស្ត និងពិនិត្យសុខភាព ។ ជាលទ្ធ អវិជ្ជមាន រួចក្រុមគ្រូពេទ្យអនុញ្ញាតឲ្យបងប្អូនត្រឡប់ទៅមូលដ្ឋានរៀងៗខ្លួនចំនួន០២នាក់ (ចំពោះអ្នកមានប័ណ្ណចាក់វ៉ាក់សាំងត្រឹមត្រូវ) ចំណែកអ្នកមានប័ណ្ណចាក់វ៉ាក់សាំងតែស្តេនអត់ចេញចំនួន០៧នាក់ (ស្រី០២នាក់, ក្មេងស្រី ០២នាក់) ត្រូវបានបញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័ក រោងចក្រម្សៅមី ស្ថិតក្នុងភូមិអូរល្វា ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង ៕

## គម្រោង RIGHT-TO-WORK រួមចំណែកជួយលើកកម្ពស់ពលករ
## ចំណាកស្រុកដែលមានជំនាញទាប បានប្រកាសបិទគម្រោងជាផ្លូវការ ក្នុងឆ្នាំ២០២២នេះ

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី២០ ខែមករា ឆ្នាំ២០២២

(ភ្នំពេញ)៖ គម្រោង RIGHT-TO-WORK ក្រោមជំនួយរបស់សហគមន៍អឺរ៉ុប ដោយសហការអនុវត្តដោយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (ជ. ច. ក. ស.) និងអង្គការវីវើល (WeWorld) នៅក្នុងខេត្តសៀមរាប និងកំពង់ចាម បានប្រកាសបិទសកម្មភាពលើកកម្ពស់ការយល់ដឹង និងការការពារសិទ្ធិការងារដល់ពលករចំណាកស្រុកដែលមានជំនាញទាបរបស់ខ្លួន ក្រោមអធិបតីភាពរបស់ រដ្ឋលេខាធិការក្រសួងការងារ និងវិជ្ជាជីវៈ ឯកឧត្តម

ហ៊ួ វុឌ្ឍី ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។ ក្នុងនោះដែរ ក៏មានការចូលរួមពីសំណាក់ លោក Andrea Cefis តំណាងប្រចាំប្រទេសអង្គការ វីរើល និងលោក មុំ សុខចារ នាយកអង្គការ ជ. ច. ក. ស. ក៏ដូចជាតំណាងសហគមន៍ សហជីព អង្គការជាតិ អន្តរជាតិ ទីភ្នាក់ងារ អង្គការ សហប្រជាជាតិ និងដៃគូឯកជនសរុបប្រមាណ ៧០នាក់។ ការប្រកាសបិទគម្រោងជាផ្លូវការនេះ ដែលអនុវត្តតាំងពីឆ្នាំ២០១៩ ត្រូវបានប្រព្រឹត្តទៅពីថ្ងៃទី១៨ ដល់ទី១៩ ខែមករា ឆ្នាំ២០២២ នាសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ។

រដ្ឋលេខាធិការក្រសួងការងារ និងវិជ្ជាជីវៈ ឯកឧត្តម ហ៊ួ វុឌ្ឍី ក្នុងឱកាសនោះ បានមានប្រសាសន៍ថា៖ « ក្រសួងបានបង្កើតនូវច្រកព័ត៌មាននានា ដើម្បីជួយឱ្យពលករដែលចង់ចំណាកស្រុកទៅធ្វើការនៅប្រទេសដទៃចេះពិចារណា និងគិតគូរ មុននឹងសម្រេចចិត្តចេញទៅ។ គម្រោង RIGHT-TO-WORKនេះ បានរួមចំណែកក្នុងការកាត់បន្ថយហានិភ័យ តាមរយៈការស្រាវជ្រាវ និងសិក្សាព័ត៌មានច្បាស់ការណ៍ពីគ្រប់ភាគីពាក់ព័ន្ធ មិនថា សហគម និង អង្គការដៃគូនានា»។ ឯកឧត្តម បានសម្ដែងនូវភាពសោមនស្សរបស់លោក និងបានកោតសរសើរទៅលើសកម្មភាព និងកិច្ចប្រឹងប្រែងរបស់អង្គការដៃគូទាំងពីរគឺ អង្គការវីរើល និងអង្គការ ជ.ច.ក.ស.។ ឯកឧត្តមក៏បានឆ្លើយតប ជាវិជ្ជមានភ្លាមៗដែរ ទៅដល់សំណូមពរមួយចំនួនដែលបានលើកឡើងដោយតំណាងអ្នកផ្សព្វផ្សាយ សហគមន៍លោកស្រី សយ សាមន។ សំណូមទាំង១៦ចំណុច គឺបានដកស្រង់ចេញពីសិក្ខាសាលា ទាក់ទាញមតិគាំទ្រ កាលពីថ្ងៃទី ១៧ ខែធ្នូ ឆ្នាំទៅនៅខេត្តសៀមរាប។

លោក Andrea Cefis បានគូសបញ្ជាក់ថា៖ «បេសកកម្មរបស់វីរើល នៅកម្ពុជា គឺជួយដល់ជនងាយរងគ្រោះក្នុងសង្គម អភិវឌ្ឍធនធានមនុស្ស និងសេដ្ឋកិច្ច ជាពិសេសស្ត្រីនិងកុមារ ដើម្បីធានាថាគ្មាននរណាម្នាក់ ត្រូវទុកចោលនោះទេ។ ហេតុដូច្នេះហើយបានជា យើងលើកគម្រោង RIGHT-TO-WORK នេះឡើង ជាមួយ ជ.ច.ក.ស. ដើម្បីធានានូវការការពារសិទ្ធិដល់អ្នកចំណាកស្រុក ប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ក៏ដូចជា អនុវត្តសកម្មភាពរបស់យើងឱ្យបានតាមពាក្យសម្ដី។ ជាក់ស្ដែង យើងបានដាក់ចេញនូវជាពិសេសយុទ្ធនាការផ្សព្វផ្សាយនា ៨ខែចុងក្រោយនេះ តាមរយៈFacebook វិទ្យុ ជនមានឥទ្ធិពល ភាពយន្តឯកសារ ការបញ្ចាំងតាម ភូមិ ដោយសហការជាមួយ អង្គការភាពយន្តឈូករ័ត្ន»។

លោកមេធាវី មុំ សុខចារ បានបញ្ជាក់ថា៖ «យើងជឿថាគ្រប់គ្នាសុទ្ធតែមានជំនាញ គ្រាន់តែមានតិច ល្មម ឬច្រើន។ ដូច្នេះ តាមរយៈគម្រោងនេះ យើងចង់សាងបរិយាកាសអំណោយផលដល់ពលករទេសន្តប្រវេសន៍ របស់យើងដែលមានជំនាញទាប ក៏ដូចជាអនុវត្តនូវសុច្ចនករតាមគោលដៅទី៨ ក្នុងការអភិវឌ្ឍន៍ប្រកបដោយ និរន្តរភាពរបស់អង្គការសហប្រជាជាតិ នៅក្នុងខេត្តកំពង់ចាម និងសៀមរាប» ។ ក្នុងរយៈពេល១ថ្ងៃកន្លះ គឺថ្ងៃទី១៨ មួយថ្ងៃពេញ និង១៩ មួយព្រឹក សិក្ខាសាលាបានសម្រេចបាទសកម្មភាពដូចតទៅ៖ ការបង្ហាញលទ្ធផលសិក្ខាសាលាទាក់ទាញមតិលើកទី២ ដោយតំណាងអ្នកសម្របសម្រួលសហគមន៍, ការប្រគល់ជូនឯកសារលទ្ធផលនៃសិក្ខាសាលាទាក់ទាញមតិលើកទី២ជូន ឯកឧត្តម ហ៊ួ វុឌ្ឍី , ការចែករំលែកពីសកម្មភាព បញ្ហាប្រឈម សមិទ្ធិផល និងមេរៀនដែលរៀនបានពីគម្រោង, ការចែករំលែកភាពយន្តឯកសារដែលផលិតដោយអង្គការភាពយន្តឈូករ័ត្ន និងអ្នកស្ម័គ្រចិត្តយកព័ត៌មាន សហគមន៍, កិច្ចពិភាក្សា៖ ចំណាប់អារម្មណ៍លើគម្រោង និងការបន្តអនុវត្តសកម្មភាពរបស់គម្រោង, កិច្ចពិភាក្សា៖ និរន្តរភាពរបស់គម្រោងនៅក្នុងសហគមន៍, ការចែករំលែក និងកិច្ចពិភាក្សាតុមូលស្ដីពីកិច្ចការពារ និងលើកកំពស់សិទ្ធិការងារពលករចំណាកស្រុក ដែលមានជំនាញទាបក្នុងអំឡុងពេលកូវីដ១៩ និងក្រោយកូវីដ១៩,ការដាក់បញ្ចាំងខ្សែភាពយន្តរបស់ភាពយន្តឈូករ័ត្ននិងកិច្ចពិភាក្សាពីផែនការផ្សព្វផ្សាយសម្រាប់សហគមន៍។

សូមជម្រាបថា គម្រោងRIGHT-TO-WORK (គម្រោងសិទ្ធិការងារសម្រាប់ពលករចំណាកស្រុកដែលមានជំនាញទាប) បានអនុវត្តសកម្មភាពរបស់ខ្លួនរយៈពេលបីឆ្នាំដោយចាប់ផ្តើមក្នុងឆ្នាំ២០១៩ នឹងបានបញ្ចប់ក្នុងឆ្នាំ២០២២ ក្រោមជំនួយរបស់សហគមន៍អឺរ៉ុប ដោយសហការអនុវត្តដោយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (ជ ច ក ស) និងអង្គការវីវើល នៅក្នុងខេត្តសៀមរាប និងកំពង់ចាម។ សិក្ខាសាលាបិទបញ្ចប់គម្រោង នេះមានគោលបំណងចែករំលែកពីសមិទ្ធិផលរបស់គម្រោង បញ្ហាប្រឈម និងការអនុវត្តល្អៗ ជាពិសេស សិក្ខាសាលានេះក៏បានបង្កើតឱ្យមានឱកាសដើម្បីអោយសហគមន៍ និងដៃគូរពាក់ព័ន្ធបានជួបប្រាស្រ័យទាក់ទងគ្នា នឹងដោះស្រាយបញ្ហារួមគ្នាផងដែរ។

## ទាហានឈុតខ្មៅថៃ ឃាត់ពលករខ្មែរ១៨នាក់ដែលលួចចូលទៅរកការងារធ្វើប្រទេសថៃ

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ ២១ ខែ មករា ឆ្នាំ ២០២២ ម៉ោង ០៩:១៧

បន្ទាយមានជ័យ៖ទាហានឈុតខ្មៅថៃឃាត់ពលករខ្មែរចំនួន១៨នាក់ដែលលួចចូលទៅរកការងារធ្វើប្រទេសថៃ នៅរសៀលថ្ងៃទី២០ ខែមករា ឆ្នាំ២០២២ តាមបន្ទាត់ព្រំដែនក្នុងភូមិសាស្ត្រអារញ្ញ ខេត្តស្រះកែវប្រទេសថៃ។

លោកវរៈសេនីយ៍ឯក សួង សៅ មេបញ្ជាការវរៈសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ បានប្រាប់ថា ៖ បានទទួលព័ត៌មានពីកម្លាំងទាហានឈុតខ្មៅថៃបានឃាត់ពលករខ្មែរចំនួន១៨នាក់ ស្រី០៩នាក់ កុមារ៣នាក់ ដែលលួចឆ្លងដែនទៅចូលក្នុងទឹកដីថៃ ដើម្បីទៅរកការងារធ្វើនៅប្រទេសថៃ តាមបន្ទាត់ព្រំដែនក្នុងភូមិសាស្ត្រស្រុកអារញ្ញ ដែលឈមស្រុកម៉ាឡៃ ។ លោកបានបញ្ជាក់ថា ៖ ក្រោយពីទាហានឈុតខ្មៅថៃឃាត់ពលករខ្មែរចំនួន១៨នាក់ បានបញ្ជូនអោយទៅកម្លាំងអធិការដ្ឋាននគរបាលស្រុកអារញ្ញ ដើម្បីសាកសួរតាមចម្លើយពួកគាត់បានលួចឆ្លងដែនមានបំណងទៅរកការងារធ្វើនៅប្រទេសថៃ តាមរយៈមេខ្យល់កម្ពុជាបានជូនឆ្លងដែនមកដាក់ព្រំដែនក្នុងទឹកដីថៃ ដោយរងចាំមេខ្យល់ថៃយកឡានមកទទួលត្រូវបានកម្លាំងទាហ៊ានឈុតខ្មៅថៃល្បាតប្រទះឃើញឃាត់ខ្លួន ។ លោកវរៈសេនីយ៍ឯក សួង សៅ បានបញ្ជាក់ថា ៖ តាមចម្លើយពលករខ្មែរពួកគាត់ត្រូវបានមេខ្យល់យកម្នាក់ចំនួន៧.០០០បាត ហើយទទួលជូនទៅរកការងារធ្វើនៅបាងកក ប្រទេសថៃ តែពេលរកចាំមេខ្យល់ថៃយកឡានមកទទួលត្រូវទាហានឈុតខ្មៅឃាត់ ហើយកម្លាំងវរៈការពារព្រំដែនលេខ៨១៥កំពុងស្រាវជ្រាវរកចាប់ខ្លួនមេខ្យល់កម្ពុជាអោយបាន ដើម្បីចាត់ការតាមច្បាប់ ៗ

# ថ្ងៃទី២៤ ខែ មករា ឆ្នាំ២០២២

## គម្រោងបញ្ជូនពលករខ្មែរMOUទៅធ្វើការនៅថៃត្រូវបានពន្យារពេលដោយសារជំងឺអូមីក្រុង

https://www.kampucheathmey.com/ ថ្ងៃសុក្រ ២១ មករា ២០២២ដោយ Sokhom Khon

គម្រោងបញ្ជូនពលករខ្មែរMOUទៅធ្វើការនៅប្រទេសថៃ នៅក្នុងខែមករានេះ ត្រូវបានពន្យារពេលដោយសារការរាតត្បាតជំងឺអូមីក្រុង។ លោក អន ប៊ុនហាក់ ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា បានឱ្យដឹងថ្ងៃទី២១ ខែមករានេះថា តាមគម្រោងនៅចុងខែមករា ឆ្នាំ២០២២នេះ យើងគ្រោងនឹងបញ្ជូនពលករ MOU ទៅធ្វើការនៅប្រទេសថៃប្រមាណពី២ ទៅ៣ពាន់នាក់។ ប៉ុន្តែត្រូវបានពន្យាពេលវិញ ដោយសារប្រទេសថៃមានបញ្ហាផ្ទុះជំងឺកូវីដ១៩ប្រភេទអូមីក្រុង ពិសេសនៅកន្លែងដែលពលករត្រូវធ្វើចត្តាឡីស័ក។ លោកបានបន្តថា «គម្រោងបញ្ជូនពលករនៅតែដដែលទេ គ្រាន់តែរាងយឺតបន្តិច ដោយសារតំបន់ដែលសម្រាប់ទុកធ្វើចត្តាឡីស័កសម្រាប់ពលករខ្មែរមានឆ្លងជំងឺអូមីក្រុង។ អីចឹងផែនការរបស់យើងគឺនៅដដែលទេ ហើយពលករដែលត្រូវបញ្ជូនទៅនៅចុងខែមករានេះ យើងនឹងយកទៅបញ្ចូលនៅដើមខែក្រោយវិញ»។

បើតាមលោក អន ប៊ុនហាក់ ពលករ MOU ដែលនឹងបញ្ជូនទៅធ្វើការនៅប្រទេសថៃនៅខែក្រោយនេះមានប្រមាណជាង១ម៉ឺននាក់ ដោយពួកគាត់ធ្វើទៅលើវិស័យសំណង់ ផ្នែកចំណីអាហារនិងគ្រឿងសមុទ្រជាដើម។ លោក អន ប៊ុនហាក់ បានបន្តថា ការបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃនេះ រដ្ឋាភិបាលថៃបានតម្រូវឱ្យនិយោជកថៃត្រូវទិញប័ណ្ណធានារ៉ាប់រងសម្រាប់ទុកចំណាយទៅលើការព្យាបាលពេលដែលពលករខ្មែរមានឆ្លងជំងឺកូវីដ១៩ ព្រោះថារាល់ការព្យាបាលជាបន្ទុករបស់និយោជកទាំងស្រុង។ លោកបានបន្តទៀតថា ពលករខ្មែរដែលអាចទៅធ្វើការនៅប្រទេសថៃត្រូវមានលក្ខខណ្ឌមួយចំនួនដូចជា ត្រូវមានកាតចាក់វ៉ាក់សាំងធ្វើតេស្តរកជំងឺកូវីដ១៩រយៈពេល៧២ម៉ោងតាមម៉ាស៊ីនPCR ឬតេស្តរហ័សដែលធ្វើដោយគ្រូពេទ្យជំនាញដើម្បីបញ្ជាក់វិញ្ញាបនបត្រថា មិនមានឆ្លងជំងឺកូវីដ១៩។ ពេលទៅដល់ព្រំដែនពលករខ្មែរដែលចាក់វ៉ាក់សាំង២ដូសរួចហើយត្រូវធ្វើចត្តាឡីស័ករយៈពេល៧ថ្ងៃហើយពលករដែលអត់ទាន់បានចាក់វ៉ាក់សាំងទេត្រូវធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ។ បើតាមការប៉ាន់ស្មានបច្ចុប្បន្ននេះប្រទេសថៃត្រូវការពលករបរទេសចំនួន៤២០.០០០នាក់ ដែលភាគច្រើនក្នុងការងារសំណង់ រោងចក្រ និងឧស្សាហកម្មអាហារសមុទ្រ៕ អត្ថបទ៖ សំអឿន

## ពលករលួចឆ្លងដែនខុសច្បាប់ ២១នាក់ ត្រូវឃាត់ខ្លួនដោយកងកម្លាំងអន្តរាគមន៍

https://cen.com.kh/ Posted ByPen Srey NeatJanuary 22, 2022

បន្ទាយមានជ័យ ៖ កម្លាំងអន្តរាគមន៍វរសេនាតូចថ្មើរជើងលេខ៥១៣ កងពលតូចថ្មើរជើងលេខ៥១ សហការជាមួយកម្លាំងនគរបាលព្រំដែនគោកលេខ៨១៥ ធ្វើការឃាត់ខ្លួនពលរដ្ឋខ្មែរបម្រុងលួចឆ្លងដែនទៅប្រទេសថៃចំនួន ២១នាក់ ស្រី ១០នាក់ ប្រុស ១១នាក់ និងកុមារ ១នាក់ នៅយប់ថ្ងៃទី២១ ខែមករា ឆ្នាំ២០២២ នៅត្រង់ចំណុច ភូមិឈើទាល ឃុំអូរស្រឡៅ ស្រុកម៉ាឡៃ។

ដោយមានការបញ្ជាផ្ទាល់ពី ឧត្តមសេនីយ៍ត្រី សឹង្ក ទុំ មេបញ្ជាការកងពលតូចថ្មើរជើងលេខ៥១ ដាក់បទបញ្ជាយ៉ាងតឹងរឹង ការពារនៅតាមបន្ទាត់ព្រំដែន ក្នុងការរឹតបន្តឹងសន្តិសុខព្រំដែនទប់ស្កាត់ពលករលួចឆ្លងដែន ជាពិសេសបានចាត់តាំងកម្លាំងចុះស៊ើបអង្កេតស្វែងរកមុខសញ្ញាមេខ្យល់ ចាប់ខ្លួនបញ្ជូនឲ្យសមត្ថកិច្ចជំនាញចាត់ការតាមផ្លូវច្បាប់។

សូមបញ្ជាក់ថា ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ កុំឲ្យឆ្លងចូលជាសហគមន៍ កម្លាំងអន្តរាគមន៍កងពលតូចថ្មើរជើងលេខ៥១ តែងតែយកចិត្តទុកដាក់អនុវត្តតាមបទបញ្ជាថ្នាក់លើទាំង ៣ ទិសក្នុងខេត្តបន្ទាយមានជ័យ ចាប់ពីទិសអូរនាង ប៉ោយប៉ែត និងទិសម៉ាឡៃ សហការជាមួយកម្លាំងនៅតាមមូលដ្ឋាន ចេញល្បាតផែកឆែរត្រួតពិនិត្យជាប្រចាំ ក្នុងការទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់។

ក្រោយពីឃាត់ខ្លួន បានធ្វើការណែនាំដល់បងប្អូនប្រជាពលរដ្ឋ កុំបន្តចាញ់បោកមេខ្យល់ ដែលតែងតែបញ្ចុះបញ្ចូល នាំពលករឆ្លងដែនខុសច្បាប់ ដោយមិនគិតពីសុវត្ថិភាព និងខាតបង់ប្រាក់កាសជាបន្តបន្ទាប់ ជាពិសេសសូមបន្តចូលរួមអនុវត្តវិធានការ ៣កុំ ៣ការពារ អោយបានទាំងអស់គ្នា និងបានប្រគល់ពួកគាត់អោយទៅនគរបាលព្រំដែនគោកលេខ៨១៥ សាកសួរនិងចាត់ការទៅតាមផ្លូវច្បាប់៕ រក្សាសិទ្ធិដោយ ៖ សុទ្ធ លី

## អាជ្ញាធរថៃ បញ្ជូនពលករខ្មែរចំនួន ២២៥នាក់ មកស្រុកកំណើតវិញ តាមច្រកតំបន់អូរអន្លក់

https://cen.com.kh/ Posted ByPen Srey NeatJanuary 23, 2022

ស្រុកកំរៀង ៖ ភាគីថៃ បានបញ្ជូនពលករខ្មែរចំនួន ២២៥នាក់ (ស្រី៨០នាក់ ក្មេង៤១នាក់ ស្រី២០នាក់) មកតាមច្រកតំបន់អូរអន្លក់ ហើយកម្លាំងប៉ុស្តិ៍អូរអន្លក់ សហការជាមួយកម្លាំងកងយោធពលខេមរភូមិន្ទ និងក្រុមគ្រូ

ពេទ្យ បានទទួលពលករទាំងនោះ ដែលវិលត្រឡប់មកស្រុកវិញ , ក្រុមគ្រូពេទ្យធ្វើតេសរហ័ស ជាលទ្ធផល អវិជ្ជមានកូវីដ១៩ ទាំងអស់។

នៅថ្ងៃទី២៣ ខែ មករា ឆ្នាំ២០២២ ដោយអនុវត្តន៍តាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្តីពីការការពារសន្តិសុខ តាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវរកមុខសញ្ញា មេខ្យល់នាំពលករ ចេញដោយមិស្របច្បាប់ ក្នុងភូមិសាស្ត្រ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរៈ៨១៩ បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់ សហការជាមួយកម្លាំងកងយោធពលខេរភូមិន្ទ និងក្រុមគ្រូពេទ្យ បានទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃ បានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង។

បន្ទាប់ពីសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការ ការពារការឆ្លងជំងឺកូវី-១៩ រួចចំនួន២២៥នាក់ (ស្រី៨០នាក់ ក្មេង៤១នាក់ ស្រី២០នាក់) កម្លាំងយើងបានកត់ឈ្មោះរួច ក្រុមគ្រូពេទ្យធ្វើតេសរហ័ស ជាលទ្ធផល អវិជ្ជមានកូវីដ១៩ ទាំងអស់។ ក្នុងនោះពលករចំនួន៤៥នាក់ ស្រី១៧នាក់ ក្មេង៤នាក់ ស្រី១នាក់ បញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៥ ស្រុកសំពៅលូន។ ពលករដែលមានកាតចាក់វ៉ាក់សាំង ចំនួន១៨០នាក់ ស្រី៦៣នាក់ ក្មេង៣៧នាក់ ស្រី១៩នាក់។ ក្នុងនោះបានចាក់វ៉ាក់សាំងឲ្យក្មេងចាប់ពីអាយុ៥ឆ្នាំដល់១៨ឆ្នាំ ចំនួន២៤នាក់ ស្រី១០នាក់ ក្រុមគ្រូពេទ្យអនុញ្ញាតឲ្យត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ៕ ដោយ ៖ សុទ្ធ លី

## ថ្ងៃទី២៥ ខែ មករា ឆ្នាំ២០២២

### ពលករខ្មែរ ៣ ១៦០ នាក់វិលត្រឡប់ពីថៃ
### ក្នុងរយៈពេល ៣ សប្តាហ៍ក្នុងខែនេះ និងរកឃើញមានផ្ទុកវីរុសកូវីដ ៥ នាក់

https://www.postkhmer.com/ អោម ប៊ុនធឿន | Publication date 23 January 2022 | 18:39 ICT

**ភ្នំពេញៈ** យ៉ាងហោចណាស់មានពលករខ្មែរចំនួន៣.១៦០នាក់បានវិលត្រឡប់មកពីប្រទេសថៃវិញក្នុងរយៈពេល៣សប្តាហ៍ គិតពីថ្ងៃទី ១-២១ មករា ឆ្នាំ ២០២២ ដែលក្នុងនោះមាន ពលរដ្ឋ ៤៥៥ នាក់ កំពុងធ្វើចត្តាឡីស័ក និង ៥ នាក់ រកឃើញមានជំងឺកូវីដ ១៩។ នេះបើតាមលោក សឿម ប៊ុនរិទ្ធិ អ្នកនាំពាក្យរដ្ឋបាលខេត្តបាត់ដំបង។

លោក សឿម ប៊ុនរិទ្ធិ អភិបាលរង និងជាអ្នកនាំពាក្យរដ្ឋបាលខេត្តបាត់ដំបង ថ្លែងនៅថ្ងៃទី២៣ ខែមករា ថា រយៈពេល២១ថ្ងៃ គិតចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី២១ មករា មានប្រជាពលរដ្ឋ ដែលជាពលករខ្មែរ បានវិលត្រឡប់មកពីប្រទេសថៃវិញ ចូលតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង និងច្រករបៀងផ្សេងៗ សរុបចំនួន៣១៦០នាក់ ក្នុងនោះ រកឃើញមានអ្នកជំងឺកូវីដ១៩ ចំនួន៥នាក់។ លោកថា អ្នកដែលវិលត្រឡប់ចូលប្រទេសវិញ ដោយបានចាក់វ៉ាក់សាំងត្រឹមត្រូវ ត្រូវអនុញ្ញាតឱ្យបន្តដំណើរទៅលំនៅឋានរៀងខ្លួន។ ប៉ុន្តែពលរដ្ឋខ្មែរដែលត្រឡប់មកពីប្រទេសថៃ មិនទាន់ចាក់វ៉ាក់សាំង ត្រូវធ្វើចត្តាឡីស័កគ្រប់១៤ថ្ងៃទើបអនុញ្ញាតឱ្យទៅលំនៅឋានវិញ។ លោកថ្លែងថា៖«រាល់ថ្ងៃពលករដែលធ្វើចត្តាឡីស័កហ្នឹងមានចំនួន៤៥៥នាក់។ ចំនួននេះចែកជា២ គឺប្រជាពលរដ្ឋដែលនៅខេត្តបាត់ដំបងផ្ទាល់ចំនួន១៩៣នាក់ និងពលករដែលក្រៅខេត្តមានចំនួន២៦២នាក់។ ទាំងអ្នកនៅក្នុងខេត្ត និងក្រៅខេត្ត នឹងអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះរៀងៗខ្លួន ក្រោយចត្តាឡីស័ក១៤ថ្ងៃ ហើយគ្មានជំងឺកូវីដ១៩» ។

លោក សេក សុខុម អ្នកនាំពាក្យរដ្ឋបាលខេត្តបន្ទាយមានជ័យថ្លែងនៅថ្ងៃទី២៣ ខែមករាថា ពលរដ្ឋខ្មែរដែលត្រឡប់មកពីប្រទេសថៃវិញ ជិត៤០០នាក់កំពុងធ្វើចត្តាឡីស័ក។ ដោយឡែកអ្នកដែលបានចាក់វ៉ាក់សាំង និងពិនិត្យឃើញអវិជ្ជមានកូវីដ១៩ គឺត្រូវអនុញ្ញាតឱ្យបន្តដំណើរទៅកាន់ទីលំនៅរៀងៗខ្លួន។ ទោះយ៉ាងណា លោកមិនបានបញ្ជាក់ប្រាប់ចំនួនពលករសុរប រយៈពេល៣សប្តាហ៍ក្នុងខែមករានេះទេ ប៉ុន្តែ លោកប្រាប់ថា ក្នុង១ថ្ងៃ ពលករ

ខ្មែរដែលត្រឡប់មកពីប្រទេសថៃមានចំនួន ពី ១០០ ទៅ២០០ នាក់ជារៀងរាល់ថ្ងៃ។ លោកថ្លែងថា៖«ពលករទាំងអស់ដែលត្រឡប់មកពីប្រទេសថៃវិញភាគច្រើនសុទ្ធតែបានចាក់វ៉ាក់សាំងរួចហើយ ដោយសារតែពួកគាត់ចេញចូលៗទៅវិញទៅមកចាក់នៅយើងដដែល។ អ៊ីចឹងភាគច្រើនចាក់នៅយើងទាំងអស់ហ្នឹង ព្រោះបើចាក់នៅស្រុកថៃអស់ ៥០០បាត តែចាក់នៅយើងហ្វ្រីហ្នឹង»។ លោកសេក សុខុម បញ្ជាក់ថា ការត្រឡប់ទៅផ្ទះរបស់ពលករលើកនេះលែងមានការដឹកជញ្ជូនដោយឥតគិតថ្លៃដូចពេលមុនទៀត ហើយ ហេតុនេះ ក្រោយធ្វើការពិនិត្យមើលរួចរាល់ ពលករអាចស្វែងរកមធ្យោបាយធ្វើដំណើរទៅលំនៅឋានរៀងៗខ្លួន។ លោកថ្លែងថា៖«ពេលគាត់ចូលមក យើងវាស់កម្ដៅយើងអីបានត្រឹមត្រូវហើយ។ បើគាត់អត់មានអីទេ មានវ៉ាក់សាំងមានអីត្រឹមត្រូវ យើងឱ្យគាត់ទៅវិញដោយខ្លួនឯងលើកនេះឈប់ហ្វ្រីឡានដូចមុនហើយ»។

លោកផល លឹម អ្នកនាំពាក្យរដ្ឋបាលខេត្តឧត្តរមានជ័យថ្លែងថា តាមរបាយការណ៍ប្រចាំថ្ងៃ ដែលលោកទទួលបាន គឺខេត្តឧត្តរមានជ័យនៅតែមានប្រជាពលរដ្ឋត្រឡប់មកពីប្រទេសថៃវិញជារៀងរាល់ថ្ងៃ ដែលមានពលករចន្លោះពី១០០ទៅ២០០នាក់។ យ៉ាងណាលោកប្រាប់ថា លោកមិនមានទិន្នន័យសរុបចំនួនពលករត្រឡប់មកវិញក្នុងរយៈពេល៣សប្ដាហ៍ចុងក្រោយនេះទេ៕

## ឃាត់ខ្លួនពលករខ្មែរ
## បម្រុងលួចឆ្លងដែនទៅប្រទេសថៃ២លើកមាន២១នាក់ ក្នុងភូមិសាស្ត្រស្រុកម៉ាឡៃ

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ ២៤ ខែ មករា ឆ្នាំ ២០២២ ម៉ោង ០៩:០១

បន្ទាយមានជ័យ ៖ កម្លាំងចម្រុះឃាត់ពលករខ្មែរបម្រុងលួចឆ្លងដែនទៅប្រទេសថៃ២លើក ចំនួន២១នាក់ កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០២២ ភូមិសាស្ត្រស្រុកម៉ាឡៃ ។

លោកវរៈសេនីយ៍ឯក សួង សៅ មេបញ្ជាការវរៈសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៥ បានប្រាប់ថា ៖ កម្លាំងចម្រុះមានកម្លាំងនគរបាលការពារព្រំដែនគោកលេខ៨១៥ និងកម្លាំងយោធាកងពលថ្មើរជើងលេខ ៥១ បានចេញល្បាតតាមបន្ទាត់ព្រំដែនបានប្រទះឃើញពលករខ្មែរបម្រុងលួចឆ្លងដែន ទៅប្រទេសថៃ ឃាត់ខ្លួន២កន្លែង មានចំនួន២១នាក់ ស្រី១០នាក់ កុមារ១នាក់ ។ លោកបានបញ្ជាក់ថា ៖ ឃាត់នៅគោលដៅទី១.នៅចំណុចប៉ុស្តិ៍ស្វាយព្រៃឃុំ.ស្រុកម៉ាឡៃ មានចំនួន១៦នាក់ ស្រី០៨នាក់ កុមារ១នាក់ មានប្រជាពលរដ្ឋខេត្តសៀមរាប១៤នាក់ ខេត្តបាត់ដំបង២នាក់ គោលដៅទី២.ប៉ុស្តិ៍ក្បាលទំនប់ ឃុំអូរសំព័រ ស្រុកម៉ាឡៃ ចំនួន០៥នាក់ ស្រី០២នាក់ ។

លោកវរៈសេនីយ៍ឯក សួង សៅ បានបញ្ជាក់ថា ៖ ក្រោយឃាត់ពលករខ្មែរ២លើក ចំនួន២១នាក់ នៅ២គោលដៅ បាននាំយកយកទីបញ្ជាការ ដើម្បីធ្វើការសាកសួរតាមចម្លើយពួកបានប្រាប់ថា ពួកគាត់មានបំណងឆ្លងដែនទៅប្រទេសថៃ ដើម្បីរកការងារធ្វើ តាមរយៈមេខ្យល់ទទួលជូនទៅរកការងារធ្វើក្នុងម្នាក់ មេខ្យល់យកតម្លៃ ៧.០០០បាត នៅពេលដែលបម្រុងឆ្លងដែនត្រូវបានកម្លាំងឃាត់ខ្លួនធ្វើការណែនាំកិច្ចសន្យា និងស្រាវជ្រាវរកមេខ្យល់ ដើម្បីចាត់ការតាមច្បាប់ ៕

## នៅឯច្រកអូរស្មាច់ មានកំណើនពលករវិលមកពីថៃ ខណៈថ្ងៃចូលឆ្នាំចិនខិតជិតមកដល់

https://master.btv.com.kh/ 01/24/2022 12:01 PM

ឧត្តរមានជ័យ៖ ខណៈបុណ្យចូលឆ្នាំចិន ខិតជិតមកដល់ នៅឯច្រកព្រំដែនអូរស្មាច់ ក្នុងខេត្តឧត្តរមានជ័យ គេសង្កេតឃើញថា មានកំណើនវំហូរពលករខ្មែរ ដែលធ្វើការនៅប្រទេសថៃ វិលត្រឡប់មកកម្ពុជា ហើយបញ្ហាកូវីដ-១៩ ក៏មិនគួរឱ្យព្រួយបារម្ភដែរ។ របាយការណ៍របស់រដ្ឋបាលខេត្តឧត្តរមានជ័យ បានឱ្យដឹងថា កាលពីម្សិលមិញ ពលករឆ្លងដែន មកពីថៃ មានចំនួន២១៩នាក់ ក្នុងនោះរកឃើញវិជ្ជមានជំងឺកូវីដ-១៩ ចំនួនពីរនាក់។

ឯកឧត្តម ប៉ែន កុសល្យ អភិបាលខេត្ត និងជាប្រធានគណៈកម្មការប្រយុទ្ធជំងឺកូវីដ-១៩ខេត្តឧត្តរ មានជ័យ ក្នុងពេលចុះពិនិត្យស្ថានភាពតាមព្រំដែន កាលពីម្សិលមិញ បានស្នើដល់ពលករទាំងអស់ ដែល មានបំណងឆ្លងដែន មកកម្ពុជាវិញ តាមច្រកអូរស្មាច់ កុំមានការលួចឆ្លងដែនតាមច្រករបៀង ឬក៏តាមរយៈមេខ្យល់ឲ្យសោះ ប្រសិនបើលួចឆ្លងដែនដោយខុសច្បាប់ មិនមានការត្រួតពិនិត្យសុខភាព ពីមន្ត្រីជំនាញ សុខាភិបាលនោះទេ នឹងប្រឈមមុខចំពោះច្បាប់។ ឯកឧត្តម បានបញ្ជាក់ថា ក្នុងអំឡុងពេលនេះ ជាពេលដែលរាជរដ្ឋាភិបាលកំពុងខិតខំប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ដែលបំប្លែងខ្លួនថ្មី គឺអូមីក្រុង ដែលបាននឹងកំពុងឆ្លងចូលសហគមន៍កម្ពុជាហើយ ដូច្នេះពលករទាំងអស់ ត្រូវតែចូលរួមសហការទប់ស្កាត់ការចម្លងនៃមេរោគនេះ។

តាមការឱ្យដឹងពីមន្ត្រីសុខាភិបាល ការឆ្លងរាលដាលជំងឺកូវីដ-១៩ ក្នុងសហគមន៍ខេត្តឧត្តរមានជ័យ ក្នុងរយៈពេលចុងក្រោយ លែងសូវជាការព្រួយបារម្ភទៀតហើយ ដោយសារប្រជាពលរដ្ឋភាគច្រើនបាន ចាក់វ៉ាក់សាំង៕ អត្ថបទ៖ យិន សារិទ្ធ

## តុលាការឧទ្ធរណ៍ ពន្យារពេលប្រកាសសាលដីកា
## បុរសចិនម្នាក់ ដែលជាប់គុក១៦ ឆ្នាំ ជាប់ពាក់ព័ន្ធបទល្មើសលក់ដូរមនុស្ស សម្រាប់ឆ្លងដែន !!

https://cen.com.kh/ Posted ByPen Srey NeatJanuary 24, 2022

ភ្នំពេញ ៖ សាលាឧទ្ធរណ៍រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី ២៤ ខែមករា ឆ្នាំ២០២២ នេះ បានលើកសវនាការទៅពេលក្រោយ នឹងហៅសាក្សី មកសាកសួរ ដើម្បីបន្តសំណុំរឿង របស់បុរសជាប់ចោទជនជាតិចិនម្នាក់ ជាប់ពាក់ព័ន្ធនឹងការ អំពើលក់ដូរមនុស្សសម្រាប់ឆ្លងដែន ប្រព្រឹត្តនៅរាជធានីភ្នំពេញ នៅក្នុងឆ្នាំ២០១៧ ។

លោក ស៊ិន វិសាល ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះសាលាឧទ្ធរណ៍រាជធានីភ្នំពេញ បានថ្លែងឲ្យដឹងថា ជនជាប់ចោទរូបនេះ មានឈ្មោះ XU WENJUN ភេទប្រុស អាយុ៤៣ឆ្នាំ ជជនជាតិចិនដីគោក មុខរបរមុនចាប់ខ្លួន ជាម្ចាស់រោងចក្រមួយនៅប្រទេសចិន ។ លោកចៅក្រមបានបញ្ជាក់ថា នៅក្នុងសំណុំរឿងក្ដីនេះ ជនជជនជាប់ចោទជនជាតិចិន ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ កាលពីអំឡុង ឆ្នាំ ២០១៨ កាត់ទោស ដាក់ពន្ធនាគារ កំណត់ ១៦ ឆ្នាំ ពីបទ: អន្តរការរវាងអ្នកសុំកូន និង ស្ត្រីពពោះ និង អំពើលក់ដូរមនុស្សសម្រាប់ឆ្លងដែន តាមមាត្រា ៣៤ មាត្រា ៤១ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើ ជួញដូរមនុស្ស និង អំពើអាជីវកម្មផ្លូវភេទ។ តែគាត់បានប្ដឹងឧទ្ធរណ៍។ ជនជាប់ចោទ ឈ្មោះ XU WENJUN ត្រូវបានចាប់ឃាត់ខ្លួន កាលពីអំឡុងខែមិថុនា ២០១៧ នៅរាជធានីភ្នំពេញ៕ រក្សាសិទ្ធិដោយ ៖ ចន្ទា ភា

## អាជ្ញាធរស្រុកសំពៅលូន ទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ ពីប្រទេសថៃ និងប្រគល់ទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣

https://gdlf-kh.com/ 2022/01/24/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង០៩និង០១នាទី នាថ្ងៃចន្ទ ៧រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរងផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនកូនភ្នំចំនួន០៤នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ខៀវ-ផាត (នាយរងប៉ុស្តិ៍) សហការជាមួយកម្លាំងយោធាកងអនុសេនាធំទី១, វរសេនាតូចលេខ១ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ឡៃ-លឿន (មេបញ្ជាការកងអនុសេនាតូច),កម្លាំងយោធាកងអនុសេនាធំគាំទ្រ, វរសេនាតូច៥៣៣ ចំនួន០៤នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ភួង-វៃ (មេបញ្ជាការរងកងអនុសេនាធំ) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញត្រង់ចំណុច ភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០៦នាក់ (ស្រី ០២នាក់ ក្មេង០២នាក់ ក្មេងស្រី០១នាក់)។ ក្រោយពីទទួលបាន កម្លាំងយើងបានធ្វើការសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំ រួចបានប្រគល់បងប្អូនឲ្យទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅចំណុចច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣។

# ថ្ងៃទី២៦ ខែ មករា ឆ្នាំ២០២២

## ដើមឆ្នាំ២០២២ ពលករចំណាកស្រុកមកពីប្រទេសថៃ តាមច្រកអន្តរជាតិអូរស្មាច់ និងច្រកអន្តរជាតិជាំ ក្នុងខេត្តឧត្តរមានជ័យមានជាង១០ម៉ឺននាក់

http://freshnewsasia.com/ 2022-01-25 12:20pm

**(ឧត្តរមានជ័យ)៖** សម្រាប់ខេត្តឧត្តរមានជ័យ ចាប់តាំងពីជំងឺកូវីដ១៩ ឆ្លងរីករាលដាលជាសកល ធ្វើឲ្យពលករ និងប្រជាពលរដ្ឋខ្មែរយើង ដែលបម្រើការ និងរស់នៅក្រៅប្រទេស ពិសេសនៅប្រទេសថៃ បានបង្ខំចិត្តវិលមកស្រុក កំណើតវិញ មានចំនួនគួរឲ្យកត់សម្គាល់។

មន្ត្រីជាន់ខ្ពស់សាលាខេត្តឧត្តរមានជ័យ បានថ្លែងប្រាប់ភ្នាក់ងារព័ត៌មាន Fresh News ឲ្យដឹងនៅព្រឹកថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២នេះថា គិតត្រឹមចុងសប្តាហ៍ទី៣ នៃខែមករា ឆ្នាំ២០២២នេះ ពោលគិតចាប់តាំងពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ ដល់ល្ងាចថ្ងៃទី២៣ ខែមករា ឆ្នាំ២០២២នេះ ពលករចំណាកស្រុកមកពីប្រទេសថៃ តាមច្រកអន្តរជាតិអូរស្មាច់ និងច្រកអន្តរជាតិជាំមានចំនួន ១១៣.៧១៨នាក់ (ស្រី៥០.៨៨៧នាក់) ក្នុងនោះពលករ និងប្រជាពលរដ្ឋ ដែលរស់នៅខេត្តឧត្តរមានជ័យផ្ទាល់មានចំនួន ១៤.៧៨២ (ស្រីចំនួន៦.៨៤៨នាក់) ផងដែរ។ មន្ត្រីដដែលបានថ្លែងឱ្យដឹងទៀតថា ក្រោមបទបញ្ជារបស់លោក ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ ទោះពលករដែលមានបណ្ណចាក់វ៉ាក់សាំងការពារជំងឺវីដ១៩ ក៏ដោយ ក៏ត្រូវអនុវត្តន៍តាមវិធានការសុខាភិបាលដែរ គឺត្រូវធ្វើតេស្ត រ៉ាស់កំដៅជាមុនផងដែរ បើរកមិនឃើញអាការៈជំងឺដែលគួរឲ្យសង្ស័យទេ សមត្ថកិច្ចមិនអនុញ្ញាតឲ្យបន្តដំណើរទៅមុខទៀតតាមមធ្យោបាយរៀងៗខ្លួន។

មន្ត្រីជាន់ខ្ពស់សាលាខេត្តឧត្តរមានជ័យ បានបញ្ជាក់ទៀតថា អំពីស្ថានភាពនៅតាមច្រកព្រំដែនអន្តរជាតិ នៃខេត្តឧត្តរមានជ័យ គឺប្រព្រឹត្តទៅជាធម្មតាចំពោះការនាំចេញ-នាំចូលទំនិញ ប៉ុន្តែចំពោះការធ្វើដំណើររបស់ប្រជាពលរដ្ឋ ភាគីថៃមិនទាន់បើកឲ្យចេញ-ចូល នៅឡើយទេ។ លោកក៏បានបញ្ជាក់ផងដែរថា កន្លងមកអាជ្ញាធរខេត្តឧត្តរមានជ័យ និងអាជ្ញាធរខេត្តពាក់ព័ន្ធរបស់ថៃ បានពិភាក្សាគ្នាគ្រោងស្នើសុំបើកដំណើរការច្រកនៅតាមព្រំដែនឡើងវិញ ប៉ុន្តែកម្មវិធីត្រូវបានអាក់ខានដោយជំងឺកូវីដ-១៩ ប្រភេទអូមីក្រុងផ្ទុះឡើង៕

## ពលករធ្វើការនៅថៃ ព្រួយបារម្ភជួបវិបត្តិអត់ការងារធ្វើឡើងវិញ ដោយសារជំងឺកូវីដ១៩ បំប្លែងថ្មីអូមីក្រុង កំពុងឆ្លងច្រើនករណី

https://www.rfa.org/ ដោយ ទីន ហ្សាការីយ៉ា 2022-01-24

ពលករមួយចំនួនកំពុងធ្វើការនៅក្នុងប្រទេសថៃ ព្រួយបារម្ភថា ពួកគាត់នឹងអាចជួបវិបត្តិអត់ការងារធ្វើម្ដងទៀត ដោយសារស្ថានភាពជំងឺកូវីដ១៩បំប្លែងថ្មីអូមីក្រុង (omicron) កំពុងឆ្លងច្រើនករណីនៅក្នុងប្រទេសនេះ។ សង្គមស៊ីវិល សង្កេតឃើញថា ការបារម្ភនេះបណ្ដាលឲ្យមានពលករខ្លះបានត្រឡប់មកខ្មែរវិញ ខណៈពលករខ្លះទៀតនៅតែបន្តលួចឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃដដែល។ ការផ្ទុះជំងឺកូវីដ១៩ បំប្លែងថ្មីអូមីក្រុងនេះ កំពុងបង្កភាពភ័យខ្លាចទាំងផ្នែកសុខភាព និងប្រាក់ចំណូលដល់ពលករម្ដងទៀត។

ពលករធ្វើសំណង់ម្នាក់នៅប្រទេសថៃ លោក ធន សុខខឿន ឲ្យដឹងថា ស្ថានភាពឆ្លងកូវីដ១៩ អូមីក្រុងនៅថៃ ច្រើនគឺជិតមួយម៉ឺន (១០.០០០) នាក់ក្នុងមួយថ្ងៃ ប៉ុន្តែរដ្ឋាភិបាលថៃមិនទាន់ដាក់ចេញវិធានការតឹងរ៉ឹង ឬឈានដល់ការបិទខ្ទប់ការដ្ឋានសំណង់ដូចមុនទេ។ ទោះយ៉ាងណា ពលកររូបនេះព្រួយបារម្ភថា ប្រសិនបើតួលេខនៅតែឆ្លងខ្លាំងបែបនេះទៀត ពួកគាត់នឹងជៀសមិនផុតពីការបាត់បង់ការងារធ្វើនោះទេ។ លោកបន្តថា បច្ចុប្បន្នពលករភាគច្រើននៅមានការងារធ្វើធម្មតាទេ ប៉ុន្តែប្រាក់ចំណូលបានថយជាងមុន បើធៀបនឹងមុនពេល ដែលមានការឆ្លងកូវីដ១៩៖ «កាលមុនយើងថា ការងារយើងមានជាប់រាល់ថ្ងៃទៅ យើងអាចរកចំណូលបានខ្លះៗ។ សព្វថ្ងៃនេះដល់ពេលយើងមានកម្លាំងទៅ ដល់ពេលនេះ ការងារយើងអត់សូវជាប់ប៉ុន្មានទេ។ ការងារវាមានតិចៗ អត់សូវសំបូរដូចពីមុនណា»។

ពលរដ្ឋខ្មែរម្នាក់ទៀត គឺជាអ្នកដើររើសអេតចាយនៅខេត្តសមុទ្រប្រាកាន (Samut Prakan) លោក ណាត យ៉ាន ឲ្យដឹងដែរថា ចាប់តាំងពីជំងឺកូវីដ១៩ អូមីក្រុងឆ្លងច្រើនមក លោកមិនសូវមានសំបកកំប៉ុង ឬសម្ភារៈចាស់ៗរើសទេ។ លោកអះអាងថា ថ្ងៃខ្លះ លោក និងប្រពន្ធ សឹងតែរើសអេតចាយមិនបានលុយទិញអង្ករដាំបាយឲ្យកូនហូបផង។ ទោះជាយ៉ាងណា ពលរដ្ឋរូបនេះមិនទាន់គម្រោងនឹងត្រឡប់មកកម្ពុជាពេលនេះវិញទេ ដោយលោកមានបំណងស៊ូទ្រាំមួយរយៈទៀត ក្រែងអាចរកបានប្រាក់មួយចំនួន៖ «មិនមែនថាមិនទៅ (ស្រុកកំណើត) ទេ។ ក៏ប៉ុន្តែឥឡូវនេះ ម៉ែក្មេកគាត់ខលមក ថា បើឥឡូវបើថាកូនឯងមិនព្រមទៅផ្ទះទេ ឲ្យយកកូន២នាក់ហ្នឹងទៅផ្ទះទៅ ហើយកូនឯងនៅរកស៊ីឯហ្នឹងទៅ។ ខ្ញុំវាខ្មាស់គេ បើនិយាយឲ្យចំទៅ ខ្ញុំវាខ្មាសគេ»។

ស្ថានភាពលំបាកនេះ ទើបតែកើតឡើងថ្មីៗ នេះទេ ដោយសារតែកំណើននៃការឆ្លងជំងឺកូវីដ១៩ បំប្លែងថ្មីអូមីក្រុង។ កាលពីពាក់កណ្ដាលឆ្នាំ២០២១ ពលករខ្មែរនៅប្រទេសថៃ រងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារវិបត្តិជំងឺកូវីដ១៩ នេះម្ដងហើយ ដោយសារថៅកែបានបញ្ឈប់ពលករស្ទើរទាំងស្រុង ហើយអាជ្ញាធរថៃ បានទុកពលករឆ្លងជំងឺកូវីដ១៩ ចោល។ កាលនោះ មានពលករខ្មែរជាច្រើននាក់ បានធ្លាក់ខ្លួនឈឺធ្ងន់ក្រោយឆ្លងជំងឺកូវីដ១៩ ហើយពួកគាត់មិនទទួលបានសេវាព្យាបាលត្រឹមត្រូវទេ ដោយនាំគ្នាដេកនៅក្នុងតង់សំពត់កៅស៊ូ ទិញថ្នាំលេបខ្លួនឯង និងប្រើវិធីខ្មែរបុរាណ គឺការស្ដោង់ ជាដើម។ លើសពីនេះ នៅពេលមានភ្លៀងធ្លាក់ម្ដងៗ ខ្យល់បោកតង់សំពត់កៅស៊ូប៉ើងដួល

ធ្វើឱ្យពួកគាត់ខ្លះ ត្រូវដេកនៅហាលភ្លៀងទាំងយប់ក៏មានដែរ។ ក្នុងស្ថានភាពលំបាកខ្លាំងនោះ រដ្ឋាភិបាលខ្មែរ ក៏បានបិទព្រំដែនហាមពួកគាត់មិនឲ្យឆ្លងមកកម្ពុជាវិញដែរ ក្រោមហេតុផលខ្លាចនាំជំងឺកូវីដ១៩ ប្រភេទដែលតា (Delta) ចូលកម្ពុជា។ រដ្ឋាភិបាល បានទុកឲ្យពួកគាត់ដេកកណ្ដាលព្រៃក្នុងដីថៃ។

វិទ្យុអាស៊ីសេរី មិនអាចសុំការបញ្ជាក់ពីស្ថានភាពពលករ និងការឆ្លងជំងឺកូវីដ១៩ ពីខាងមន្ត្រីស្ថានទូតខ្មែរប្រចាំប្រទេសថៃបានទេ នៅថ្ងៃទី២៤ មករា។ តែយ៉ាងណា ទំព័រហ្វេសប៊ុក (Facebook page) របស់ស្ថានទូតចុះផ្សាយថា ក្រុមអនុព័ន្ធការងារអមស្ថានទូតកម្ពុជាតែងតែបានចុះជួបសំណេះសំណាល និងសាកសួរសុខទុក្ខពលករខ្មែរកំពុងធ្វើការនៅប្រទេសថៃ និងបានអប់រំពន្យល់ណែនាំអំពីបម្រាម ច្បាប់ ការគាំពារ និងសិទ្ធិអត្ថប្រយោជន៍ផ្សេងៗ ដែលពលករស្របច្បាប់ត្រូវទទួលបាន។

ប៉ុន្តែក្រុមពលករ លើកឡើងថា ថៅកែថៃមិនបានអនុវត្តកាតព្វកិច្ចផ្ដល់អត្ថប្រយោជន៍ឲ្យពួកគាត់ ក្នុងអំឡុងពេលឆ្លងកូវីដ១៩ ឬក្នុងពេលបិទខ្ទប់ទេ។ ជុំវិញករណីនេះដែរ សង្គមស៊ីវិលឃ្លាំមើលសិទ្ធិពលករនៅប្រទេសថៃបារម្ភថា ពលករនឹងអាចជួបវិបត្តិគ្មានការងារធ្វើ ឬផលប៉ះពាល់សុខភាពម្ដងទៀត ប្រសិនបើជំងឺកូវីដ១៩ អូមីក្រុងនៅតែបន្តឆ្លងច្រើនដូចសព្វថ្ងៃ។

មន្ត្រីសិទ្ធិការងារនៃអង្គការសង់ត្រាល់ (Central) ប្រចាំប្រទេសថៃ លោក លឹង សុផុន សង្កេតឃើញថា ថ្វីត្បិតតែស្ថានភាពជំងឺកូវីដ១៩អូមីក្រុង មិនទាន់ផ្ដល់ផលប៉ះពាល់ធ្ងន់ធ្ងរដូចមុនមែន តែពលករខ្លះបានរាងចាល និងខ្លះទៀតចាប់ផ្ដើមធុញទ្រាន់នឹងស្ថានភាពអូសបន្លាយនៃវិបត្តិជំងឺកូវីដ១៩ ដោយពួកគាត់មានបំណងចង់វិលត្រឡប់ទៅកម្ពុជាវិញ។ លោក បន្តថា រយៈពេលប៉ុន្មានថ្ងៃចុងក្រោយនេះ មានពលករច្រើនបានត្រឡប់ទៅកម្ពុជាវិញ។ ប៉ុន្តែទន្ទឹមនឹងនេះ ពលរដ្ឋផ្សេងទៀតក៏កំពុងរកគ្រប់មធ្យោបាយ ដើម្បីលួចឆ្លងដែនមករកការងារធ្វើនៅក្នុងប្រទេសថៃវិញដែរ៖ «អំឡុងពេលនេះ វាប៉ះពាល់ដែរ។ តែមិនដូចអំឡុងពេលខែ៩ ឬខែ១០ កន្លងមក ដោយសារតែមិនត្រឹមតែរោគកូវីដទេ ថៃមទាំងលិចទឹក លិចអ្វីទៀតណា នៅតំបន់ទំនាបខ្លះ ដូចជា ខាងរ៉ាក់យ៉ង សមុទ្រប្រកាន។ ពលករដែលធ្វើការសំណង់ភាគច្រើនលិចទឹក។ អ៊ីចឹង!មិនត្រឹមតែផ្អាកការងារទេ ថៃមទាំងលិចទឹក។ អ៊ីចឹង! ធ្វើឲ្យពួកគាត់ហ្នឹងខ្វះខាត ហើយនឹងជីវភាពពួកគាត់ក៏លំបាក»។

របាយការណ៍របស់រដ្ឋបាលខេត្តឧត្តរមានជ័យ បង្ហាញថា កាលពីថ្ងៃទី២៣ មករាមាន ពលករ ២១៩នាក់ បានឆ្លងដែនតាមច្រកអូស្មាច់ត្រឡប់ពីប្រទេសថៃ។ ក្នុងនោះ អាជ្ញាធររកឃើញពលករ២នាក់ ឆ្លងជំងឺកូវីដ-១៩។ ចំណែកពលរដ្ឋដែលលួចឆ្លងដែនចូលទៅថៃវិញនោះ ក៏មានចំនួនច្រើនដែរ។ ក្រុមពលករដែលបានលួចឆ្លងដែនចូលក្នុងប្រទេសថៃ ឲ្យដឹងថា ក្នុងមួយថ្ងៃៗមានពលរដ្ឋរាប់រយនាក់លួចឆ្លងដែនពីកម្ពុជាចូលប្រទេសថៃ ដើម្បីស្វែងរកការងារធ្វើ តែមានប្រមាណ ១០នាក់ប៉ុណ្ណោះអាចលួចចូលបាន។ ពួកគាត់ ថា ក្នុងករណីប៉ូលិសខ្មែរ ឬ ខាងថៃពួនស្ទាក់ចាប់បាន ពួកគាត់ត្រូវចាប់បញ្ជូនត្រឡប់ទៅស្រុកកំណើតវិញ ហើយរកវិធី ឬផ្លូវថ្មីលបចូលម្ដងទៀត។ ពួកគាត់អះអាងថា បច្ចុប្បន្នតម្លៃនាំផ្លូវដើរឆ្លងដែនពីខ្មែរទៅថៃ ម្នាក់ខ្ទង់ ៩ពាន់ (៩.០០០) បាត ឬប្រហែល ៣០០ ដុល្លារ៕

## អាជ្ញាធរស្រុកសំពៅលូន ទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ និងប្រគល់ទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣

https://gdlf-kh.com/ 2022/01/25/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃអង្គារ ៨រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៥ ខែមករា ឆ្នាំ ២០២២ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំ ស្ដីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់

នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ និងលោកវរសេនីយ៍ឯក ហាត ឡៃឡៃ ស្នងការរង ផែនការងារវរសេនាតូចនគរបាលការពារព្រំដែនគោក ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនទាំង៦ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធាចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្រ្តប៉ុស្តិ៍គ្រប់គ្រង និងបានទទួលប្រជាពលរដ្ឋវិលត្រឡប់ពីប្រទេសថៃវិញ ត្រង់ចំណុចភូមិសាស្រ្ត ឃុំសន្តិភាព និងឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង សរុបបានចំនួន០៣នាក់។

ក្រោយពីទទួលបាន កម្លាំងយើងបានកត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំ រួចក៏បានប្រគល់បងប្អូនទាំងអស់អោយទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣។

# ថ្ងៃទី២៧ ខែ មករា ឆ្នាំ២០២២

## ក្មេងជំទង់ជនជាតិថៃ
## ម្នាក់គេចខ្លួនពីមណ្ឌលហៅទូរស័ព្ទឆបោក នៅក្រុងប៉ោយប៉ែតប្រទេសកម្ពុជា

https://www.khmertimeskh.com/ Khmer Times January 26, 2022

ជនជាតិថៃអាយុ១៨ឆ្នាំម្នាក់បានប្ដឹងទៅសមត្ថកិច្ច បន្ទាប់ពីគាត់ត្រូវបានល្បួងឱ្យធ្វើការនៅមជ្ឈមណ្ឌលហៅទូរស័ព្ទបោកប្រាស់ នៅព្រំដែនកម្ពុជា មុនពេលរត់គេចខ្លួន និងរាយការណ៍ពីបទល្មើស។ បុរសដែលត្រូវបានគេស្គាល់ មានឈ្មោះ Surasak បានរត់គេចខ្លួន និងស្វែងរកការការពារពីក្រសួងយុត្តិធម៌ ដោយមានជំនួយពីគេហទំព័រឆ្លើយតបបន្ទាន់មួយដែលមានឈ្មោះថា Sai Mai Tong Rod (Sai Mai District Must Survive) ដែលបង្កើតឡើងដោយ Ekkapob Luengprasert។ លោកបាននិយាយថា លោកបារម្ភពីសុវត្ថិភាពរបស់លោកចាប់តាំងពីបានរត់គេចខ្លួនពីក្រុមជនខិលខូចដែលមានមូលដ្ឋាននៅក្រុងប៉ោយប៉ែត ជាប់នឹងខេត្តស្រះកែវ។ គាត់ត្រូវបាននាំទៅក្រសួងកាលពីម្សិលមិញដោយលោក Ekkapob ជាកន្លែងដែលគាត់បានជួប Thanakrit Jitta-areerat លេខាក្រសួងយុត្តិធម៌ដែលបានយល់ព្រមទទួលយកសំណុំរឿងរបស់គាត់។ លោក Surasak បាននិយាយថា លោកបានស្វែងរកការងារធ្វើតាំងពីដើមឆ្នាំមុន នៅពេលដែលលោកបានដឹងពីការផ្សាយពាណិជ្ជកម្មតាមអ៊ីនធឺណិតអំពីការងារនៅក្រុងប៉ោយប៉ែត ដោយសន្យាថានឹងទទួលបានប្រាក់ខែខ្ពស់ប្រចាំខែចំនួន ៤០,០០០ បាត។

កាលពីខែកញ្ញា គាត់បានធ្វើដំណើរទៅស្រុកខក់ស៊ុង ខេត្តស្រះកែវ ជាកន្លែងដែលគាត់ត្រូវបានបុរសថៃម្នាក់នាំគាត់ឆ្លងកាត់តាមព្រៃភ្នំឆ្លងព្រំដែនទៅប៉ោយប៉ែត។ នៅទីនោះ គាត់ត្រូវបានគេដាក់នៅក្នុងអគារមួយដែលគាត់បានជួបជាមួយជនជាតិថៃចំនួន ១០០ នាក់ផ្សេងទៀតដែលត្រូវបានល្បួងដោយមជ្ឈមណ្ឌលហៅទូរស័ព្ទដូចគ្នា។ នៅក្នុងអគារ ដែលជាកន្លែងការិយាល័យផងដែរ លោក Surasak បាននិយាយថា លោកក៏បានឃើញជនបរទេសមកពីប្រទេសហ្វីលីពីន ឥណ្ឌូនេស៊ី និងម៉ាឡេស៊ីផងដែរ។ មនុស្ស៥នាក់ត្រូវបានរៀបចំអោយស្នាក់នៅក្នុងបន្ទប់មួយ។ អ្នកដែលបានល្បួងឱ្យធ្វើការត្រូវបានគេដាក់នៅក្នុងមជ្ឈមណ្ឌលហៅទូរស័ព្ទ "ស្ថានីយ"។ ពួកគេត្រូវបានគេប្រាប់ឱ្យក្លែងខ្លួនជាមន្ត្រីមកពីភ្នាក់ងារអនុវត្តច្បាប់ដូចជាប៉ូលិស ឬនាយកដ្ឋានស៊ើបអង្កេតពិសេស ហើយត្រូវទូរសព្ទ័ទៅប្រជាជនក្នុងប្រទេសថៃ។ ជនរងគ្រោះនឹងត្រូវបានគេប្រាប់ថា ពួកគេមានបញ្ហាជាមួយនឹងច្បាប់ ហើយត្រូវបង់ប្រាក់សំណូកដើម្បីដោះស្រាយរឿងនេះ។ លោក Surasak បាននិយាយថា "ជារៀងរាល់ថ្ងៃ ជនរងគ្រោះផ្ទេរប្រាក់ពី ២-៣ លានបាតទៅឱ្យក្រុមទុច្ចរិត។ ប្រភព: Bangkokpost

## ស្ត្រីខ្មែរម្នាក់របួសជើងមិនអាចឈរបាន ក្នុងចំណោមពលករត្រឡប់ពីថៃវិញ

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២៦ ខែ មករា ឆ្នាំ ២០២២ ម៉ោង ១៤:៣៤

បន្ទាយមានជ័យ ៖ ស្ត្រីពលករខ្មែរម្នាក់របួ.សជើងមិនអាចដើបឈរបាន ក្នុងចំណោមពលករត្រឡប់ពីថៃចូលមកកម្ពុជា ក្នុង១ថ្ងៃ ជិត៣០០នាក់ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ ក្នុងភូមិសាស្ត្រ ខេត្តបន្ទាយមានជ័យ ។

លោកវរៈសេនីយ៍ឯក សួង សៅ មេបញ្ជាការវរៈសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ បានប្រាប់ថា ៖ មានស្ត្រីជាពលករខ្មែរម្នាក់ ដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាក្នុងភូមិសាស្ត្រ ស្រុកម៉ាឡៃ ដែលក្រុមការងារទទួលនៅចំណុចប៉ុស្តិ៍សង្កែ និងប៉ុស្តិ៍ចំប៉ក់ចំនួន៤៣នាក់ ស្រី២០នាក់កុមារ ៣នាក់ ក្នុងនោះមានស្ត្រីម្នាក់បានរបួសជើងធ្ងន់ដោយទៅធ្វើកម្មករកាប់អំពៅតាមបន្ទាត់ព្រំដែន នៅពេលស៊ីឈ្នួលកាប់អំពៅអោយថៃ ត្រូវគល់អំពៅធ្លាក់បុកចំជើង បណ្តាលរបួស ធ្វើការមិនកើតទើបត្រឡប់មកស្រុកវិញត្រូវបញ្ជូនទៅមន្ទីរពេទ្យបង្អែកស្រុកម៉ាឡៃ ។

លោកវរៈសេនីយ៍ទោ ម៉ាន់ ធី អធិការនគរបាលស្រុកអូរជ្រៅបានប្រាប់ថា ៖ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២នេះក្រុមការងារប្រចាំច្រកអូបីជាន់ ស្រុកអូរជ្រៅទទួលពលករខ្មែរដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាវិញ មានចំនួន២៣០នាក់ ស្រី១១៨នាក់ កុមារ២៧នាក់ ហើយអ្នកមានឯកសារចាក់វ៉ាក់សាំងការពារកូវីដ១៩ ដូសទី២ មានចំនួន១៩៩នាក់ ស្រី១០៥នាក់ អ្នកដែលមិនបានចាក់វ៉ាក់សាំងការពារត្រូវបញ្ជូនទៅមណ្ឌល ដើម្បីធ្វើចត្តាឡីស័ក ៕

## ថ្ងៃទី២៨ ខែ មករា ឆ្នាំ២០២២

## មេយោធាថ្នាក់ភូមិភាគ កម្ពុជា ថៃ ជួបគ្នាបង្កើនភាពជឿជាក់និងសហប្រតិបត្តិការ

https://www.rasmeinews.com/ JAN 27, 2022 Views: 40

*ដោយៈអូរស្មាច់/ឧត្តរមានជ័យៈ មេបញ្ជាការយោធភូមិភាគទី៤(កម្ពុជា)និងមេបញ្ជាការយោធភូមិភាគទី២(ថៃ)បានជួបពិភាក្សាការងារបង្កើនកិច្ចសហការនិងទំនាក់ទំនងភាពជឿជាក់គ្នាបន្ថែមទៀតនៅមាត់ច្រកអន្តរជាតិជាំសាងាំស្រុកអន្លង់វែង។*

ក្នុងជំនួបពិភាក្សាការងារកាលពីថ្ងៃទី២៦ខែមករាភាគីកម្ពុជាដឹកនាំដោយឧត្តមសេនីយ៍ឯក ពៅ ហេង មេបញ្ជាការរងកងទ័ពជើងគោក មេបញ្ជាការយោធភូមិភាគទី៤និងប្រធានគណៈកម្មាធិការព្រំដែនថ្នាក់យោធភូមិភាគ(កម្ពុជា)ឯភាគីថៃដឹកនាំដោយឧត្តមសេនីយ៍ទោ សរៈវ៉ាត សែងផុនមេបញ្ជាការយោធភូមិភាគទី២(ថៃ)។

លោកឧត្តមសេនីយ៍មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការយោធភូមិភាគទី៤ បានមានប្រសាសន៍ថា ដើម្បី រឹតចំណងមិត្តភាពនិងបង្កើនភាពស្និទ្ធស្នាល ពង្រឹងពង្រីកកិច្ចសហការល្អលើគ្រប់វិស័យ សន្តិសុខ ស្ថេរភាព និងការអភិវឌ្ឍ តំបន់ព្រំដែន នៃយោធភូមិភាគទាំងពីរ ដើម្បីលើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ នៃប្រទេសទាំងពីរ។ កសាងភាពជឿជាក់ទុកចិត្តគ្នាទៅវិញទៅមក ។សហការផ្តល់ព័ត៌មានរវាងគ្នានិងគ្នានិងរួមគ្នាដោះស្រាយបញ្ហានានា តាមយន្តការ កិច្ចចរចារដោយសន្តិវិធី។ លោកឧត្តមសេនីយ៍យោធភូមិភាគទី៤ និងស្នើសុំគោលការណ៍ថ្នាក់ដឹកនាំ ដើម្បីរៀបចំកិច្ចប្រជុំគណៈកម្មាធិការព្រំដែន ថ្នាក់យោធភូមិភាគនិងភូមិភាគ និងគ្រោងក្នុងខែឧសភា ឆ្នាំ២០២២នេះ បើសភាពការណ៍កូវីដ-១៩ អំណោយផល។

លោកឧត្តមសេនីយ៍អំពាវនាវដល់កងកម្លាំងនៃប្រទេសទាំងពីរនឹងរួមសហប្រតិបត្តិការ ក្នុងការទប់ស្កាត់ការឆ្លងដែនខុសច្បាប់ និងការការពារបង្ការរោគត្បាតកូវីដ-១៩ និងបានថ្លែងអំណរគុណ ចំពោះភាគីថៃ ដែលបានបង្ក

លក្ខណៈសម្របសម្រួលនិងផ្តល់កិច្ចសហប្រតិបត្តិការក្នុងការធ្វើមាតុភូមិនិវត្តន៍ របស់ពលករ និងប្រជាពលរដ្ឋកម្ពុជា នាបច្ចុប្បន្ននេះ៕សរន

## កងកម្លាំងអាជ្ញាធរ បន្តទទួលពលករ
## វិលត្រឡប់មកស្រុកវិញ ដែលភាគីថៃ បញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្រុកកំរៀង

https://gdlf-kh.com/ 2022/01/27/ Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ ដោយអនុវត្តន៍តាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ជាប់ជាប្រចាំស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងស្រាវជ្រាវរកមុខសញ្ញា មេខ្យល់នាំពលករចេញដោយមិនស្របច្បាប់ក្នុងភូមិសាស្ត្រ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរៈ៨១៩ បានចាត់កម្លាំងប៉ុស្តិ៍អូរអន្លក់សហការជាមួយកម្លាំងកងយោធពលខេរភូមិន្ទ និងក្រុមគ្រូពេទ្យ បានទទួលពលករវិលត្រឡប់មកស្រុកវិញ ដែលភាគីថៃបានបញ្ជូនមកតាមច្រកតំបន់អូរអន្លក់ ស្ថិតក្នុងភូមិអូរអន្លក់ ឃុំតាសែន ស្រុកកំរៀង។

ពលករដែលវិលត្រលប់មកកម្ពុជាវិញ សរុបចំនួន២៤៤នាក់, ស្រី៨៧នាក់ និងក្មេង៥៤នាក់ បន្ទាប់ពីសាកសួរ កត់ឈ្មោះ ចុះកំណត់ហេតុ និងអប់រំណែនាំអំពីវិធានការការពារការឆ្លងជំងឺកូវី-១៩រួចរាល់ ក្រុមគ្រូពេទ្យបានធ្វើតេស្តរហ័ស និងជាលទ្ធផល គឺអវិជ្ជមានកូវីដ-១៩ ទាំងអស់។ ក្នុងនោះពលករដែលមានកាតចាក់វ៉ាក់សាំងចំនួន១៨៧នាក់ (ស្រី៦៦នាក់, ក្មេង៣៥នាក់) ចំណែកពលករចំនួន៥៧នាក់, ស្រី២១នាក់ និងក្មេង១៩នាក់ ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័កនៅមណ្ឌលគីឡូ៩ ស្រុកសំពៅលូន។ ដោយបានចាក់វ៉ាក់សាំងអោយក្មេងចាប់ពីអាយុ៥ឆ្នាំដល់២៤ឆ្នាំចំនួន២៤នាក់(ស្រី១៣នាក់)ហើយក្រុមគ្រូពេទ្យអនុញ្ញាតអោយត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ។

## មន្ត្រីច្រកព្រំដែន
## មិនប្រហែស ក្នុងការឆែកសុខភាពពលករខ្មែរវិលមកពីថៃ មុនបុណ្យចូលឆ្នាំចិន

https://btv.com.kh/ 01/26/2022 04:01 PM

បាត់ដំបង៖ ស្របពេលដែលពិធីបុណ្យចូលឆ្នាំចិនខិតជិតមកដល់ពលករខ្មែរ បាននាំវិលត្រឡប់មកពីប្រទេសថៃ តាមច្រកខេត្តបាត់ដំបង ជាបន្តបន្ទាប់ ខណៈវិធានការសុខាភិបាល ត្រូវបានរឹតបន្តឹងនៅតាមច្រកព្រំដែនដើម្បីទប់ស្កាត់ការនាំចូលមេរោគកូវីដ១៩ បំប្លែងខ្លួនថ្មីប្រភេទអូមីក្រុង។

លោក សុខ គឹមខុន អភិបាលស្រុកកំរៀង បានថ្លែងឱ្យដឹងថា មន្ត្រីប្រចាំការ និងសមត្ថកិច្ចពាក់ព័ន្ធ ទាំងអស់នៅតាមច្រកព្រំដែន កំពុងបន្តអនុវត្តវិធានការសុខាភិបាលយ៉ាងខ្ជាប់ខ្ជួន ពុំមានការធ្វេសប្រហែសឡើយ ដើម្បីទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ ចូលមកប្រទេសកម្ពុជា។ អភិបាលស្រុកកំរៀង ឱ្យដឹងបន្ថែមថា ការវិលត្រឡប់របស់ពលករ គឺមិនទៀងទាត់ឡើយ ពោលគឺថ្ងៃខ្លះមក ចំណែកថ្ងៃខ្លះអត់ ប៉ុន្តែពលករទាំងអស់ដែលចូលមកត្រូវបានរៀបចំចុះឈ្មោះ និងយកសំណាកតេស្តរហ័សរកមេរោគកូវីដ-១៩ នៅចំណុចព្រំដែន។ លោក សុខ គឹមខុន បានឱ្យដឹងថា នៅដើមឆ្នាំ២០២២នេះ ពលករខ្មែរ បានចូលទៅធ្វើការដោយ ស្របច្បាប់នៅប្រទេសថៃជាបន្តបន្ទាប់ តាមរយៈការធានាពីថៅកែជាជនជាតិថៃ និងកំណត់កាលបរិច្ឆេទធ្វើដំណើរដោយជាក់លាក់។

ពលករខ្មែរ ដែលអាចចូលទៅធ្វើការនៅប្រទេសថៃ បានត្រូវមានលិខិតធ្វើដំណើរឆ្លងដែន ដែល ចេញដោយប្រទេសកម្ពុជា ឬលិខិតផ្សេងៗ ដែលចេញដោយក្រសួងការងារ និងតម្រូវឱ្យពលករភ្ជាប់ជាមួយនូវឯកសារភស្តុតាងបញ្ជាក់ថា បានធ្វើតេស្តអវិជ្ជមានជំងឺកូវីដ-១៩ (RT-PCR/RTK) មិនឱ្យលើស ៧២ម៉ោង និងត្រូវមានប័ណ្ណចាក់វ៉ាក់សាំងយ៉ាងតិច២លើក៕អត្ថបទ៖ នឿត សុភ័ក្ត្រ

## ឆោះជាខុសច្បាប់
## ហើយប្រឈមនឹងឆ្លងកូវីដ តែប្រជាពលរដ្ឋខ្មែរ នៅតែលួចឆ្លងដែន ទៅប្រទេសថៃ!

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២៧ ខែ មករា ឆ្នាំ ២០២២ ម៉ោង ២០:៣៥

បន្ទាយមានជ័យ៖ យ៉ាងហោចណាស់ មានប្រជាពលរដ្ឋខ្មែរប្រុសស្រី ចំនួន ៧នាក់ទៀត បម្រុងលួចឆ្លងដែន ទៅប្រទេសថៃ នៅចំណុចចន្លោះបង្គោលសីមាលេខ៣០ ក្នុងភូមិប្រាសាទត្បែង ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ ជនទាំងនោះ ត្រូវបានកម្លាំងនគរបាលការពារព្រំដែនប៉ុស្តិ៍ប្រាសាទត្បែង នៃវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨០៧ សហការជាមួយកម្លាំងយោធា (គ៣) បានចាប់ឃាត់ខ្លួន នៅវេលាម៉ោង ០៩ និង ៤០នាទី យប់ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២។

លោកវរសេនីយ៍ឯក ឡុង សំណាង មេបញ្ជាការវរសេនាតូចការពារព្រំដែនគោកលេខ៨០៧ បានឲ្យដឹងថា ប្រជាពលរដ្ឋខ្មែរ ចំនួន ០៧នាក់ ដែលមានស្រី ០៣នាក់នោះ រស់នៅភូមិស៊ីរៀម ឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។ ពួកគាត់ មានបំណងលួចឆ្លងដែន ទៅប្រទេសថៃ។ តែកម្លាំងនគរបាលប៉ុស្តិ៍ប្រាសាទត្បែង សហការជាមួយកម្លាំងយោធា(គ៣) ដើរល្បាត ក៏ប្រទះឃើញជនទាំងនោះ ហើយក៏បានឃាត់ និងនាំពួកគាត់ នាំមកអប់រំអំពីផលប៉ះពាល់នៃគ្រោះថ្នាក់ផ្សេងៗ ចំពោះការលួចឆ្លងដែនខុសច្បាប់ ទៅប្រទេសជិតខាង ពិសេសបច្ចុប្បន្ននេះ ទាំងប្រទេសយើង ក៏ដូចជាប្រទេសថៃ កំពុងប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ពិសេសមេរោគបំប្លែងថ្មី អូមីក្រុង កុំឲ្យឆ្លងចូលក្នុងសហគមន៍។ បន្ទាប់ពីឃាត់ខ្លួន ប្រជាពលរដ្ឋទាំង ០៧នាក់ ត្រូវបានប្រគល់ឲ្យកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំបន្ទាយឆ្មារ ដើម្បីមានវិធានការបន្ត៕ ណុប រក្សា

## ក្នុងរយៈពេលកន្លះខែនៃខែមករា
## មានពលករចំនួន ៥៣៣ នាក់ បានវិលត្រឡប់មកពីថៃតាមស្រុកកំរៀង

https://www.postkhmer.com/ គឹម សារុំ | Publication date 27 January 2022 | 19:30 ICT

**បាត់ដំបង:** គិតចាប់ពីដើមខែមករា ដល់ពាក់កណ្ដាលខែមករា ឆ្នាំ ២០២២ មានពលករខ្មែរចំនួន ៥៣៣ នាក់ (ក្មេង ៥៩ នាក់) បានវិលត្រឡប់មកពីប្រទេសថៃ តាមស្រុកកំរៀង ក្នុងនោះមានក្មេង និងមនុស្សពេញវ័យចំនួន ១០១ នាក់ ត្រូវបានបញ្ជូនទៅមណ្ឌលចត្តាឡីស័ក។

លោក វរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការវរ ៨១៩ ការពារព្រំដែន ដែលឈរជើងនៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃក្នុងស្រុកកំរៀង និងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង បានឱ្យដឹងនៅថ្ងៃទី២៧ មករា ថា រយៈពេលប៉ុន្មានខែចុងឆ្នាំ២០២១ ដល់ខែ មករា ឆ្នាំ២០២២ ចំនួនពលករ ដែលត្រឡប់មកពីប្រទេសថៃ ដោយស័គ្រចិត្តគឺមានចំនួនខ្ទង់ពាន់នាក់ហើយ។ ប៉ុន្តែបើគិតតែស្រុកកំរៀងតែមួយស្រុក និងគិតពីដើមខែ មករា ដល់ពាក់កណ្ដាលខែ មករាឆ្នាំ ២០២២ នេះចំនួនពលករ ប្រុសស្រី និងក្មេងៗជាកូនពលករ មកពីប្រទេសថៃ មានចំនួន៥៣៣នាក់(ក្មេង៥៩នាក់)។ ក្នុងចំណោម៥៣៣នាក់នេះ មានពលករប្រុសស្រីចំនួន១០១នាក់ ត្រូវបានបញ្ជូនទៅមណ្ឌលចត្តាឡីស័ក។ លោកថ្លែងថា៖«និយាយរួមទៅ ពាក់ព័ន្ធប្រជាពលរដ្ឋយើង គាត់មកពីថៃ គឺអ្នកខ្លះ គាត់ចាក់វ៉ាក់សាំងបានតែ១ដូស និងអ្នកខ្លះទៀត បានដល់ដូសទី២។ គាត់បានចាក់វ៉ាក់ការពារជំងឺកូវីដទាំងអស់គ្នាហើយ តែមិនបានគ្រប់ដូស។ តែចំពោះបងប្អូនដែលមកដល់ព្រំដែន គឺយើងធ្វើតេស្តរហ័ស។ បើមានការសង្ស័យ គឺយើងបញ្ជូនពួកគាត់ទៅធ្វើចត្តាឡីស័ក១៤ថ្ងៃសិន មុនអនុញ្ញាតឱ្យគាត់ត្រឡប់ទៅលំនៅឋានវិញ»។

ដោយឡែកចំពោះអ្នកដែលបានចាក់វ៉ាក់សាំងដូសទី២រួចហើយ គឺត្រូវបានអនុញ្ញាតឱ្យពួកគាត់វិលត្រឡប់ទៅលំនៅឋានវិញ។ លោកបញ្ជាក់ថា៖«ចាប់តាំងពីសម័យកូវីដមកនេះ គឺកម្លាំងរបស់ខ្ញុំ មានការមមាញឹកច្រើន

ដើម្បីការពារពួកគាត់កុំឱ្យពួកគាត់ វិលត្រឡប់មកវិញសុខច្បាប់ និងម៉្យាងទប់ស្កាត់ពលករយើង លួចឆ្លងដែនចូលទៅប្រទេសថៃខុសច្បាប់ផង។ តែជំនាន់កូវីដផ្ទុះខ្លាំង គឺអត់មានអ្នកលួចឆ្លងដែនទៅថៃទេ»។ បើតាមលោក ម៉ង់ ស៊ី បញ្ហានេះដោយសារថា ប្រជាពលរដ្ឋយល់ដឹងអំពីផ្លូវច្បាប់ ពាក់ព័ន្ធនឹងការឆ្លងដែនខុសច្បាប់។ ដូច្នេះ ពួកគាត់មិនសូវលួចឆ្លងដែនទៅប្រទេសថៃទេ។ តែបើមានការលួចឆ្លងដែនខុសច្បាប់ណាមួយវិញគឺកម្លាំងសមត្ថកិច្ចរបស់លោកធ្វើការទប់ស្កាត់បានទាន់ពេល ហើយធ្វើការអប់រំដល់ពលករឱ្យត្រឡប់ទៅលំនៅឋានវិញ។ ការងារនេះគឺដោយសារមានការសហការគ្នាជាមួយភាគីថៃ ហើយថៃក៏សហការជាមួយកម្លាំងរបស់លោកដែរ។

ពាក់ព័ន្ធនឹងមេខ្យល់លួចនាំពលករឆ្លងដែនវិញ ត្រូវបានលោកស្រី រស់ ដីវី ស្នងការរង ទទួលបន្ទុកផែនការងារ ប្រឆាំងការជួញដូរមនុស្ស ខេត្ត បាត់ដំបង ប្រាប់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី២៧ មករា ថា ចំពោះបទល្មើសលួចនាំពលករឆ្លងដែនទៅប្រទេសថៃ ក្នុងរយៈពេលប៉ុន្មានខែចុងឆ្នាំ២០២១ រហូតដល់ខែមករា ឆ្នាំ ២០២២នេះ គឺមានការថយចុះ។ លោកស្រីបញ្ជាក់ថា៖«មូលហេតុមកពីកម្លាំងជំនាញពាក់ព័ន្ធ មានការទប់ស្កាត់ខ្លាំង និងមានការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ដើម្បីឱ្យពួកគាត់ បានយល់ពីផលលំបាក នៃការចំណាកស្រុកខុសច្បាប់។ ម្យ៉ាងទៀតពួកគាត់ខ្លាចអានឹងការឆ្លងជំងឺកូវីដផង»៕

## ពលករខ្មែរ៨នាក់
## លួចឆ្លងដែនចូលទឹកដីថៃទាំងកណ្ដាលយប់អធ្រាត្រត្រូវបានទាហានឈុតខ្មៅឃាត់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ២៨ ខែ មករា ឆ្នាំ ២០២២ ម៉ោង ០៩:៥២

បន្ទាយមានជ័យ ៖ ពលករខ្មែរចំនួន០៨នាក់ លួចឆ្លងដែនចូលទឹកដីថៃ ត្រូវបានទាហានឈុតខ្មៅឃាត់ទាំងកណ្ដាលយប់រំលងអធ្រាត្រចូលថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ តាមបន្ទាត់ព្រំដែន ក្នុងភូមិសាស្ត្រស្រុកអារ័ញ្ញ ខេត្តស្រះកែវ ប្រទេសថៃ ឈមភូមិក្បាលទំនប់ ឃុំ.ស្រុកម៉ាឡៃ ។

លោកវរៈសេនីយ៍ឯក សួង សៅ មេបញ្ជាការវរៈសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ បានប្រាប់ថា ៖ មានពលករខ្មែរចំនួន០៨នាក់ ស្រី០៣នាក់ កុមារ២នាក់ ត្រូវបានទាហានឈុតខ្មៅថៃឃាត់ទាំងកណ្ដាលយប់រំលងអធ្រាត្រនៅពេលដែលពលករខ្មែរបានលួចឆ្លងដែនចូលទៅក្នុងទឹកដីថៃដោយខុសច្បាប់ ។ លោកបានបញ្ជាក់ថា ៖ ក្រោយទាហានឈុតខ្មៅថៃបានឃាត់ពលករខ្មែរហើយបាននាំយកទៅសាកសួរតាមចម្លើយសារភាពពីពលករខ្មែរគឺពួកគាត់បានលួចឆ្លងដែន តាមរយៈមេខ្យល់ខ្មែរដែលបាននាំឆ្លងដែនទាំងកណ្ដាលយប់រំលងអធ្រាត្រចូលទៅក្នុងទឹកដីថៃ ដើម្បីរង់ចាំមេខ្យល់ថៃយកឡានមកទទួលនៅព្រំដែនត្រូវបានទាហានថៃឃាត់ខ្លួនដោយពួកគាត់បានលួចឆ្លងដែនចូលក្នុងទឹកដីថៃ តាមរយៈមេខ្យល់នាំទៅរកការងារធ្វើនៅក្រុងបាងកកប្រទេសថៃក្នុង១នាក់តម្លៃ៧.០០០បាត ។ លោកវរៈសេនីយ៍ឯក សួង សៅ បានបញ្ជាក់ថា៖ក្រោយពេលដែលទាហានឈុតខ្មៅថៃឃាត់ពលករខ្មែរចំនួន០៨នាក់ ត្រូវបាននាំយកទៅប្រគល់ជូនអធិការដ្ឋាននគរបាលស្រុកអារ័ញ្ញ ខេត្តស្រះកែវប្រទេសថៃ ដើម្បីអនុវត្តន៍ច្បាប់បន្តហើយកម្លាំងសមត្ថកិច្ចកម្ពុជាក៏កំពុងស្រាវជ្រាវរកចាប់ខ្លួនមេខ្យល់បោកប្រាស់ពលករនាំឆ្លងដែនដោយខុសច្បាប់ ដើម្បីចាត់ការតាមច្បាប់ ៕

## ពលករកម្ពុជាក្រោម MoU នឹងទៅដល់ថៃសប្តាហ៍ក្រោយ

https://www.khmertimeskh.com/ ខ្មែរថាមស៍ 28/01/2022

ពលករចំណាកស្រុកកម្ពុជាចំនួន ២២៦នាក់ ដែលទទួលបានការងារក្រោមអនុស្សរណៈនៃការយោគយល់គ្នាថ្មី (MoU) ស្តីពីកិច្ចសហប្រតិបត្តិការការងាររវាងរដ្ឋាភិបាលថៃ និងកម្ពុជា នឹងមកដល់ថៃនៅថ្ងៃអង្គារនេះ។

រដ្ឋមន្ត្រីក្រសួងការងារ លោក Suchart Chomklin បានបញ្ជាក់ថា រដ្ឋាភិបាលថៃបានចុះហត្ថលេខាលើ MoU ជាមួយប្រទេសកម្ពុជា ឡាវ និង មីយ៉ាន់ម៉ាកាលពីខែធ្នូ ឆ្នាំមុន ដើម្បីធានាឱ្យមានតុល្យភាពល្អ រវាងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ និង ការឆ្លើយតបទៅនឹងតម្រូវការកើនឡើងសម្រាប់ពលករចំណាកស្រុក។ លោកបានបន្តថា ពលករខ្មែរទាំងនេះ ចូលប្រទេសថៃ តាមសំណើរបស់និយោជកនៅខេត្តឈុនបុរី និង អយុធ្យា។ ក្នុងនោះ ពលករសរុបចំនួន ២២០ នាក់ នឹងត្រូវបញ្ជូនទៅខេត្តចាន់បុរី ហើយ ពលករចំនួន ៦ នាក់ទៀត នឹងត្រូវបញ្ជូនទៅខេត្តអយុធ្យា។ លោករដ្ឋមន្ត្រីបានមានប្រសាសន៍ថា នៅពេលមកដល់ប្រទេសថៃតាមរយៈច្រកត្រួតពិនិត្យអន្តោប្រវេសន៍ក្នុងខេត្តស្រះកែវ ពលករទាំងនេះ នឹងត្រូវចំណាយពេលប្រាំពីរថ្ងៃ ស្នាក់នៅក្នុងមណ្ឌលចត្តាឡីស័កតាមតម្រូវការក្រោមពិធីសារត្រួតពិនិត្យស្តង់ដារស្វែងរកវីរុសកូវីដ-១៩។

លោក Pairoj Chotikasathien អគ្គនាយកនៃនាយកដ្ឋានការងារ បានមានប្រសាសន៍ថា មណ្ឌលចត្តាឡីស័កនេះ ស្ថិតក្នុងស្រុកអារញ្ញ ខេត្តស្រះកែវ មានបន្ទប់ចំនួន ២០០ ដែលអាចទទួលមនុស្សបានដល់ទៅ ៥០០ នាក់។ លោកបានបន្តថា សេវាកម្មនេះមានតម្លៃ ៨៥០០បាតក្នុងមនុស្សម្នាក់ រួមទាំងអាហារបីពេលក្នុងមួយថ្ងៃ និងសេវាផ្ទេរប្រាក់ពីប៉ុស្តិ៍ត្រួតពិនិត្យទៅកាន់មណ្ឌលផងដែរ។ ពលករទាំងអស់នេះ ត្រូវតែទទួលវ៉ាក់សាំងបង្ការកូវីដ-១៩ ចំនួនពីរដង មុនពេលពួកគេចាកចេញពីប្រទេសកម្ពុជា។ សម្រាប់អ្នកមិនទាន់បានចាក់វ៉ាក់សាំង ពួកគេនឹងទទួលការចាក់វ៉ាក់សាំង ក្នុងពេលស្នាក់នៅមណ្ឌលនោះ។

ដោយឡែក ពលករចំណាកស្រុកថ្មីទាំងនេះ រួមជាមួយនឹងអ្នកដែលពីមុនចូលមកថៃដោយខុសច្បាប់ ហើយក្រោយមក ត្រូវបានអនុញ្ញាតឱ្យចុះឈ្មោះធ្វើការដោយស្របច្បាប់ នឹងចាប់ផ្តើមធ្វើការចាប់ពីថ្ងៃទី១៣ ខែកុម្ភៈខាងមុខនេះ៕

# ថ្ងៃទី៣១ ខែ មករា ឆ្នាំ២០២២

## កម្លាំងព្រំដែនកម្ពុជា-ថៃ ជួបពិភាក្សាគ្នាលើបញ្ហាបទល្មើសតាមព្រំដែន

https://m.postkhmer.com/ ភ្នំពេញ ប៉ុស្តិ៍28 January 2022 | 09:59 ICT

**បាត់ដំបង:** កម្លាំងនគរបាលការពារព្រំដែនកម្ពុជា និងថៃជាង ២០ នាក់ បានជួបគ្នាកាលពីថ្ងៃទី ២៧ ខែមករា នៅក្នុងភូមិទួលខ្ពស់ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ដើម្បីពិភាក្សាគ្នាលើបញ្ហាបទល្មើសផ្សេងៗ និងលើកកម្ពស់ទំនាក់ទំនងល្អជាមួយគ្នា។

ជំនួបនេះត្រូវបានធ្វើឡើងរវាងកម្លាំងប៉ុស្តិ៍ព្រំដែនភ្នំព្រឹកចំនួន ៧ នាក់ ដែលដឹកនាំដោយលោកអនុសេនីយ៍ឯក មួន លន នាយប៉ុស្តិ៍ស្តីទី សហការជាមួយកម្លាំងយោធាកងអនុសេនាធំទី៣, វរសេនាតូចលេខ ១ ចំនួន ៤ នាក់ ដឹកនាំដោយលោកវរសេនីយ៍ត្រី អ៊ួន សុខឿន មេបញ្ជាការកងអនុសេនាធំ ហើយនឹងភាគីថៃមានតម្រួតព្រំដែនថៃចំនួន ៧ នាក់ ដឹកនាំដោយលោកវរសេនីយ៍ទោ សុំដេត ស៊ិនស៊ិរិ មេបញ្ជាការរងនៃអធិការដ្ឋានប៉ូលិសព្រំដែនលេខ ១២, កម្លាំងទាហានទិសបូព៌ាចំនួន ៤ នាក់ ដែលមកប្រចាំការនៅស្រុកខ្លងហាត ដឹកនាំដោយលោកអនុសេនីយ៍ឯក ឆាក់ណុន វ៉ៃសាប់ មេបញ្ជាការផ្នែកជំនួយការនៃវរសេនាធំលេខ ២ កងកម្លាំងទិសបូព៌ា។

យោងតាមនគរបាលជាតិបានឱ្យដឹងថា ភាគីទាំង២បានធ្វើការពិភាក្សាគ្នាលើរបៀបវារៈចំនួន ៣ ដែលរួមមាន៖ «ភាគីថៃបានស្នើសុំភាគីកម្ពុជាឱ្យជួយទប់ស្កាត់ប្រជាពលរដ្ឋលួចជីកមាស, លួចកាត់ឈើយ៉ាងខុសច្បាប់ក្នុងទឹកដីថៃបន្តទៀត, ភាគីកម្ពុជាបានស្នើទៅភាគីថៃថា បើចាប់ប្រជាពលរដ្ឋខ្មែរឆ្លងខុសច្បាប់បានសុំជួយផ្តល់ដំណឹងផង និងចុងក្រោយគឺការបន្តការទំនាក់ទំនងគ្នាឱ្យកាន់តែល្អថែមទៀត»។ ភាគីទាំង២បានឯកភាពគ្នាលើរបៀបវារៈនិងសំណូមពរក្នុងជំនួបពិភាក្សានេះ។ កម្លាំងព្រំដែនកម្ពុជាក្នុងខេត្តបាត់ដំបងក៏បានទទួលពលករខ្មែរជាង ២០០នាក់ ពីប្រទេសថៃផងដែរនៅថ្ងៃដដែលនោះ៕

## កម្ពុជានឹងបញ្ជូនពលករMOUជាង២០០នាក់ ទៅធ្វើការនៅថៃនៅដើមខែក្រោយនេះ

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ២៩ មករា ២០២២ដោយ Kang Tola

ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជាបានឱ្យដឹងថា កម្ពុជានឹងចាប់ផ្តើមបញ្ជូនពលករ MOU ជាង២០០នាក់ទៅធ្វើការនៅប្រទេសថៃនៅដើមខែកុម្ភៈ ឆ្នាំ២០២២ខាងមុខនេះ បន្ទាប់ពីបានខកខានអស់រយៈពេល២ឆ្នាំដោយសារការរាតត្បាតជំងឺកូវីដ១៩។

លោក អន ប៊ុនហាក់ ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជាបានឱ្យដឹងនៅរសៀលថ្ងៃទី២៩មករានេះថា នៅថ្ងៃ០១ ខែកុម្ភៈ ឆ្នាំ២០២២ខាងមុខ កម្ពុជានឹងបញ្ជូនពលករចំនួន២២០នាក់តាមប្រព័ន្ធMOU ទៅធ្វើការនៅរោងចក្រសាច់មាន់ PANUSPOULTRY GROUP CO., LTD. នៅខេត្តឈុនបុរីប្រទេសថៃ ដោយទទួលបានប្រាក់ខែពី៥០០ទៅ៧០០ដុល្លារក្នុង១ខែ។ លោកបានបន្តថា នេះជាលើកដំបូងហើយដែលកម្ពុជាបានបញ្ជូនពលករMOUទៅធ្វើការនៅប្រទេសថៃបន្ទាប់ពីមានអាក់ខានបញ្ជូនអស់រយៈពេល២ឆ្នាំកន្លងមកនេះដោយសារវិបត្តិជំងឺកូវីដ១៩។ លោកបានបន្តទៀតថា មានតែពលករកម្ពុជាទេដែលបានទៅធ្វើការនៅប្រទេសថៃមុនពលករភូមានិងឡាវដោយសាររដ្ឋាភិបាលថៃមានទំនុកចិត្តមកលើពលករខ្មែរយើងព្រោះពួកគេបានចាក់វ៉ាក់សាំងបានគ្រប់ដូសរហូតដល់ដូសជំរុញ ឬ ដូសទី៣និងដូសទី៤ហើយវ៉ាក់សាំងដែរចាក់សុទ្ធតែវ៉ាក់សាំងមានគុណភាពដូចជាអាស្ត្រាហ្សេនេកា វ៉ាក់សាំងម៉ូដេណានិងវ៉ាក់សាំងហ្វាយហ្ស៊ីរដែលធ្វើឲ្យកម្រិតហានិភ័យនៃការឆ្លងមានកម្រិតទាបបំផុត។

លោក អន ប៊ុនហាក់បានបន្ថែមថា ពលករដែលត្រូវបញ្ជូនទៅថៃនីថ្ងៃទី០១ខែកុម្ភៈខាងមុននេះគឺបញ្ជូនតាមច្រកព្រំដែនអន្តរជាតិប៉ោយប៉ែតទល់នឹងខេត្តស្រះកែវហើយមានការទៅទទួលដោយផ្ទាល់ពីមន្ត្រីក្រសួងការបរទេសថៃ ក្រសួងការងារថៃនិងអភិបាលខេត្តស្រះកែវផងដែរ។ លោកបានបញ្ជាក់ថា ការបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃនេះ រដ្ឋាភិបាលថៃបានតម្រូវឱ្យនិយោជកថៃត្រូវទិញប័ណ្ណធានារ៉ាប់រងសម្រាប់ទុកចំណាយទៅលើការព្យាបាលពេលដែលពលករខ្មែរមានឆ្លងជំងឺកូវីដ១៩ព្រោះថា រាល់ការព្យាបាលជាបន្ទុករបស់និយោជកទាំងស្រុង។ លោកបានបន្តទៀតថា ពលករខ្មែរដែលអាចទៅធ្វើការនៅប្រទេសថៃត្រូវមានលក្ខខណ្ឌមួយចំនួនដូចជាត្រូវមានកាតចាក់វ៉ាក់សាំង ធ្វើតេស្តរកជំងឺកូវីដ១៩រយៈពេល៧២ម៉ោងតាមម៉ាស៊ីនPCRឬតេស្តរហ័សដែលធ្វើដោយគ្រូពេទ្យជំនាញដើម្បីបញ្ជាក់វិញ្ញាបនបត្រថា មិនមានឆ្លងជំងឺកូវីដ១៩។ ពេលទៅដល់ព្រំដែនពលករត្រូវធ្វើតេស្តហើយបើលទ្ធផលតេស្តអវិជ្ជមានត្រូវបន្តធ្វើចត្តាឡីស័ករយៈពេល៧ថ្ងៃ និងថ្ងៃទី៧ត្រូវធ្វើតេស្តម្តងទៀតហើយលទ្ធផលនៅអវិជ្ជមានទៀតទើបអនុញ្ញាតឱ្យទៅរោងចក្រធ្វើការតែម្តង។ គួរបញ្ជាក់ថា តាមគម្រោងកម្ពុជានឹងបញ្ជូនពលករខ្មែរMOUទៅធ្វើការនៅប្រទេសថៃនៅក្នុងកំឡុងខែមករានេះ ប៉ុន្តែត្រូវបានពន្យារពេលវិញដោយសារការរាតត្បាតជំងឺអូមីក្រុងនៅកន្លែងដែលពលករត្រូវធ្វើចត្តាឡីស័កតែម្តង៕ *ដោយ ៖ សំអឿន*

## កម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ និងយោធាកងពលលេខ៥១បានទប់ស្កាត់ប្រជាពលរដ្ឋប្រាំពីរនាក់បម្រុងលួចឆ្លងដែនទៅប្រទេសថៃនៅភូមិសាស្រ្តស្រុកម៉ាឡៃ

https://www.rasmeinews.com/ JAN 30, 2022

ដោយ : ប.ជ័យ / បន្ទាយមានជ័យ:នៅយប់រំលងអធ្រាត្រថ្ងៃអាទិត្យថ្ងៃទី៣០ ខែមករា ឆ្នាំ២០២២ ដោយមានការយកចិត្តទុកដាក់ពីលោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះស្នងការ នគរបាល ខេត្តបន្ទាយមានជ័យ និងអនុវត្តបទបញ្ជាផ្ទាល់ពី លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការ វរៈសេនាតូច នគរបាល ការពារព្រំដែនគោកលេខ៨១៥ កម្លាំងប៉ុស្តិ៍ ព្រំដែនក្បាលទំនប់នគរបាលការពារព្រំដែនគោកនៃវរសេនាតូចលេខ៨១៥ ដឹកនាំដោយលោកវរសេនីយ៍ត្រី រឿម ប៊ុនរិទ្ធ នាយប៉ុស្តិ៍ព្រំដែនក្បាលទំនប់នគរបាលការពារព្រំដែនគោកនៃវរសេនាតូចលេខ៨១៥ សហកាជាមួយកម្លាំងយោធាកងពលតូចថ្មើជើងលេខ៥១ បានទប់ស្កាត់ប្រជាពលរដ្ឋចំនួន ប្រាំពីរនាក់(ស្រី ២នាក់) បម្រុងលួចឆ្លងដែន ទៅប្រទេសថៃខុសច្បាប់ តាមភូមិសាស្រ្តប៉ុស្តិ៍ក្បាលទំនប់ ត្រង់ចំនុច គោលដៅដើមអំពិល ស្ថិតនៅក្នុងភូមិបន្ទាយទី២ ឃុំអូរសំព័រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ ប្រជាពលរដ្ឋបម្រុងលួចឆ្លងដែនទៅប្រទេសថៃប្រុសស្រីទាំប្រាំពីរនាក់មានឈ្មោះដូចខាងក្រោម៖

១/. អួត តូត ភេទប្រុស អាយុ៣០ឆ្នាំ រស់នៅភូមិថ្មី ឃុំថ្មី ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

២/.ខុល រឿ ភេទប្រុស អាយុ២៩ឆ្នាំ រស់នៅភូមិថ្មី ឃុំថ្មី ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

៣/.ហឹ ផន ភេទស្រី អាយុ៣១ឆ្នាំ រស់នៅភូមិថ្មី ឃុំថ្មី ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

៤/.ពុន ពីន ភេទប្រុស អាយុ១៦ឆ្នាំ រស់នៅភូមិត្រពាំងវែង ឃុំគោកធ្លកលើ ស្រុកជីក្រែង ខេត្តសៀមរាប

៥/.ប៉ុន បាំង ភេទស្រី អាយុ២២ឆ្នាំ រស់នៅភូមិត្រពាំងវែង ឃុំគោកធ្លកលើ ស្រុកជីក្រែង ខេត្តសៀមរាប

៦/.រិទ្ធ លី ភេទប្រុស អាយុ១៧ឆ្នាំ រស់នៅភូមិត្រពាំងវែង ឃុំគោកធ្លកលើ ស្រុកជីក្រែង ខេត្តសៀមរាប

៧/.រដ្ឋ វ៉ាក ភេទប្រុស អាយុ២២ឆ្នាំ រស់នៅភូមិស្វាយពក ឃុំគោកធ្លកលើ ស្រុកជីក្រែង ខេត្តសៀមរាប។

លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការ វរៈសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៥ បានបន្តថា៖ បន្ទាប់ពីធ្វើការសួរនាំ និងធ្វើកិច្ចសន្យារួច បានប្រគល់ពួកគាត់ជូនផ្ទៃលជំនាញអធិការដ្ឋាននគរបាលស្រុកម៉ាឡៃ ដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់ ៕

## ឱកាសបុណ្យចូលឆ្នាំចិន វៀតណាម : ពលករខ្មែរមាតុភូមិនិវត្តន៍ច្រើនតាមច្រកអូរបីជាន់និងច្រកអូរស្មាច់

https://www.rasmeinews.com/ JAN 30, 2022

*ដោយ : ប.ជ័យ / បន្ទាយមានជ័យ -ឧត្តរមានជ័យ៖ ឱកាសបុណ្យចូលឆ្នាំចិន វៀតណាមពលករខ្មែរជាច្រើនដែលចំណាកស្រុកទៅធ្វើការនៅឯប្រទេសថៃ បាននឹងកំពុងតែបន្តការឆ្លងដែនចូលមកមាតុប្រទេសវិញច្រើនជាងមុនចូលតាមច្រកព្រំដែន(របៀង)អូរបីជាន់ខេត្តបន្ទាយមានជ័យនិងច្រកព្រំដែអូរស្មាច់ខេត្តឧត្តរមានជ័យដើម្បីជួបជុំក្រុមគ្រួសារសែស្រឡាយចិន វៀតណាម ។*

លោកវេជ្ជបណ្ឌិត ឃ្លោក ហួត ប្រធានមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យបានឲ្យដឹងថ្ងៃទី២ ៩ខែមករាថា៖ ក្នុងខែមករានេះចំនួនពលករខ្មែរមាតុភូមិនិវត្តន៍តាមច្រកអូរស្មាច់ក្នុងខេត្តឧត្តរមានជ័យ បានកើនឡើងលើសពីខែមុនៗ ។ លោកវេជ្ជបណ្ឌិត បន្តថា : ទំនងជាមានសែស្រឡាយចិន វៀតណាម ទើបពលករខ្មែរទាំងនោះ បាននឹង

កំពុងបន្តការឆ្លងដែនចូលមកប្រទេសកម្ពុជាវិញពី១៥០ទៅ២០០នាក់មួយថ្ងៃៗ ។គឺហាក់លើសពីមុនៗ ដែលមានពី៨០ទៅ១៥០នាក់ក្នុងមួយថ្ងៃ ។

ចំណែកលោកអនុសេនីយ៍ម៉ាន់ ជី អធិការរងនគរបាលស្រុកអូរជ្រៅ ទទួលប្រចាំការនៅស្ថានីយ៍ទទួលពលករប្រកអូរបីជាន់ប្រាប់កាសែតរស្មីកម្ពុជានាថ្ងៃទី៣០ខែមករាថា: ជាមធ្យម មានពលករខ្មែរវិលពីប្រទេសថៃមកតាមច្រកអូរបីជាន់(ច្រករបៀង តែភាគីកម្ពុជា ថៃ ឯកភាពធ្វើជាច្រកព្រំដែនសម្រាប់បញ្ជូនមាតុភូមិនិវត្តន៍ពលករខ្មែរផ្លូវការ ដូចច្រកតំបន់ព្រំដែនបឹងត្រកួន)មានពី១៨០ទៅ២៥០នាក់/ថ្ងៃៗ ។ប៉ុន្តែ ចំនួនទាបបំផុត មានត្រឹម៨០នាក់/ថ្ងៃនិងច្រើនបំផុត មាន៣៦០នាក់ក្នុងមួយថ្ងៃៗ ។ លោកម៉ាន់ ជី បានបន្តថា :ក្នុងអំឡុងខែមករាឆ្នាំ២០២២ នេះ និងពិសេសក្នុងឱកាសបុណ្យចូលឆ្នាំចិន វៀតណាមនេះ បរិមាណពលករខ្មែរដែលអាជ្ញាធរថៃបញ្ជូនត្រឡប់តាមច្រកនេះ មានសន្ទុះកើនឡើង បន្តិចដែរ ៕សរន

## សមត្ថកិច្ចជំនាញ ទទួល ការបណ្តុះបណ្តាល ពីកិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ តាមប្រព័ន្ធអនឡាញ

https://news.btv.com.kh/ 01/28/2022 04:01 PM

ភ្នំពេញ៖ ស្នងការ ស្នងការរង និងវត្តមានរបស់មន្ត្រីជំនាញការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យា បានទទួលការបណ្តុះបណ្តាលបន្ថែម ពីកិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ តាមប្រព័ន្ធអនឡាញ។ ការបណ្តុះបណ្តាលនេះ គឺមានវត្តមានវាគ្មិនជាមន្ត្រីជាន់ខ្ពស់ តំណាងអង្គការយូនីសេហ្វ តំណាងក្រុមហ៊ុនហ្វេសប៊ុក ក៏ដូចជាវត្តមានរបស់តំណាងប៉ូលីសសហព័ន្ធអូស្ត្រាលីផងដែរ។

អគ្គស្នងការនគរបាលជាតិ នៃក្រសួងមហាផ្ទៃ និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានបន្តរៀបចំ វគ្គបណ្តុះបណ្តាលជូនមន្ត្រីជំនាញដែលធ្វើការពាក់ព័ន្ធដល់កិច្ចការពារកុមារ។ ជាក់ស្តែងសម្រាប់ថ្ងៃនេះ គឺជាការបណ្តុះបណ្តាលជូនដល់ស្នងការ ស្នងការរង ២៥រាជធានី-ខេត្ត និងមន្ត្រីជំនាញការិយាល័យប្រឆាំងបទល្មើសបច្ចេកវិទ្យា ដើម្បីឱ្យពួកគាត់ទទួលបានចំណេះដឹងបន្ថែមពីបទល្មើសដែលកើតមានឡើងក្នុងបណ្តាញសង្គមដែលមានហានិភ័យចំពោះកុមារ ជំរុញការអនុវត្តយន្តការដែលមានស្រាប់ និងកំណត់នូវវិធានការរួមដើម្បីក្នុងការជំរុញការអនុវត្តនីតិវិធីប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ក្នុងការទប់ស្កាត់បទល្មើសកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ។

សម្រាប់វគ្គបណ្តុះបណ្តាលនេះ គឺមានការចូលរួំជាវាគ្មិនពីមន្ត្រីជាន់ខ្ពស់ បណ្តាអង្គការធំៗ វត្តមានតំណាងក្រុមហ៊ុនហ្វេសប៊ុក ក៏ដូចជាវត្តមាន តំណាងប៉ូលីសសហព័ន្ធអូស្ត្រាលី។ វាគ្មិននីមួយៗ បកស្រាយពន្យល់ទៅតាមជំនាញរៀងខ្លួន។ ពាក់ព័ន្ធនឹងការទប់ស្កាត់ និងការបង្ក្រាបបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យានេះ ពុំមែនជារឿងងាយស្រួលនោះទេ។ នេះជាការបញ្ជាក់របស់ ឧត្តមសេនីយ៍ឯក ជា ពៅ ជាប្រធាននាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា។ ឯកឧត្តមថា ជាការទប់ស្កាត់និងបង្ក្រាបបទល្មើសនេះគឺទាមទារឱ្យមន្ត្រីជំនាញ ពង្រីកចំណេះដឹងជាពិសេសផ្នែកបច្ចេកវិទ្យាផ្ទាល់តែម្តង។

មន្ត្រីជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច និងតំណាងអង្គការជាដៃគូ បានលើកឡើងក្នុងឱកាសបើកវគ្គបណ្តុះបណ្តាលថា បទល្មើសការកេងប្រវ័ញ្ចផ្លូវភេទកុមារ តាមប្រព័ន្ធអនឡាញ ជារឿងស្មុគស្មាញ ដែលទាមទារគ្រប់ភាគីពាក់ព័ន្ធទាំងអស់ត្រូវចូលរួម។ បទល្មើសនេះក៏កំពុងកើតឡើងជាច្រើនផងដែរខណៈពេលដែលការបច្ចេកវិទ្យា ទូរស័ព្ទវៃឆ្លាត និងការប្រើប្រាស់បណ្តាញសង្គមកាន់តែមានកំណើន ជាពិសេសក្នុងកំឡុងពេលដែលវិបត្តិកូវីដ-១៩ ដែលកិច្ចការជាច្រើនត្រូវពឹងផ្អែកលើប្រព័ន្ធបច្ចេកវិទ្យា៕អត្ថបទ៖ គឹមហុក